**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការអនុវត្តតួនាទីរបស់មេធាវី ក្នុងរឿងក្ដីរដ្ឋប្បវេណីនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ: កញ្ញា **ហ៊ី ខួចឡេង**
កញ្ញា **ដេង មួយអៀម**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ហាប់ ផល្លី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨
ឆ្នាំសរសេរសារណា ២០២២

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំទាំងពីរឈ្មោះ **ហី ខួចឡេង** និងឈ្មោះ **ដេង មួយអៀម** ជានិស្សិតសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៨-២០២២។ ក្នុងនាមយើងខ្ញុំទាំងពីរនាក់ ជាយុវជនជំនាន់ក្រោយ ដែលជាទំពាំងស្នងឫស្សី និងជាសសរទ្រូងដ៏រឹងមាំរបស់ប្រទេសជាតិ យើងខ្ញុំក៏បានសម្រេចចិត្តស្រាវជ្រាវ និងសរសេរជាសារណាក្រោមប្រធានបទស្តីពី « **ការអនុវត្តតួនាទីរបស់មេធាវីក្នុងរឿងក្តីរដ្ឋប្បវេណីនៅកម្ពុជា**» ដើម្បីជាដើមទុន និងចំណេះដឹងបន្ថែម ដល់ប្អូនៗជំនាន់ក្រោយសម្រាប់ធ្វើជាស្ពានទៅរកភាពជោគជ័យនាថ្ងៃអនាគត។

ឆ្លៀតក្នុងឱកាសនេះផងដែរ យើងខ្ញុំសូមធ្វើការថ្លែងអំណរគុណ និងសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះ៖

**លោកឪពុក អ្នកម្តាយ ជាទីគោរព** និងស្រលាញ់នៃកូន ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ប្រៀនប្រដៅ ណែនាំប្រកបដោយកន្លងធម៌ ព្រមទាំងផ្តល់នូវក្តីអាណិតស្រលាញ់ចំពោះកូនតាំងពីតូចរហូតដល់ធំពេញវ័យ ដោយអ្នកមានគុណទាំងពីរបានលះបង់នូវកំលាំងកាយ និងកំលាំងចិត្ត ព្រមទាំងបញ្ញា និងស្មារតី មិនតែប៉ុណ្ណោះលោកអ្នកមានគុណទាំងពីរបានចំណាយថវិកាជាច្រើនដើម្បីផ្គត់ផ្គង់យើងខ្ញុំក្នុងការសិក្សារៀនសូត្រកន្លងមក។

ជាងនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណដល់ **ឯកឧត្តមសកលវិទ្យាធិការ សកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអប់រំពីសមត្ថភាពក្នុងការផ្ទេរ ចំណេះដឹង បទពិសោធន៍ ឯកសារសិក្សាស្រាវជ្រាវ ដល់យើងខ្ញុំទាំងពីរក្នុងការសិក្សារៀនសូត្រ និងជាទីកន្លែងសម្រាប់ធ្វើការស្រាវជ្រាវ។

ជាពិសេស សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ លោកសាស្ត្រាចារ្យបណ្ឌិត **ហាប់ ផល្លី** ដែលជាសាស្ត្រាចារ្យណែនាំ ដល់យើងខ្ញុំទាំងពីរ ព្រមទាំងបានចំណាយពេលវេលាដ៏មានតម្លៃសម្រាប់ធ្វើការបង្ហាត់បង្ហាញជ្រោមជ្រែង កែតម្រូវ និងផ្តល់នូវអនុសាសន៍ដ៏ល្អៗ ដែលធ្វើឲ្យការស្រាវជ្រាវមួយនេះ ដំណើរការទៅដោយរលូន និងប្រកបដោយលទ្ធផលល្អ។

ម្យ៉ាងទៀតយើងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណ ចំពោះ លោកតា លោកយាយ អ៊ំប្រុស អ៊ំស្រី លោកពូ អ្នកមីង បងប្អូន សិស្សច្បង មិត្តភក្តិទាំងអស់ដែលបានផ្តល់ជាកំលាំងចិត្ត និងផ្តល់ជាគំនិតល្អៗ ជាច្រើន ក៏ដូចជាចែករំលែកនូវបទពិសោធន៍ ដល់យើងខ្ញុំទាំងពីរនាក់ក្នុងការសរសេរសារណា។

ជាចុងបញ្ចប់ យើងខ្ញុំ សូមឲ្យវត្ថុស័ក្តសិទ្ធិទាំងអស់ ក្នុងលោកតាមថែរក្សា ការពារ និងប្រសិទ្ធិពរជ័យ សិរីសួស្តីដល់អយើងទាំងអស់គ្នា ឲ្យជៀសផុតពីជំងឺក៏កាចសាហាវ និងជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន សុខភាពល្អ កាយសម្បទារឹងមាំ អាយុ យឺនយូ ជោគជ័យគ្រប់ភារកិច្ច និងជួបតែពុទ្ធិពរ ទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

រយៈពេល ៤ឆ្នាំ ដែលយើងខ្ញុំទាំងពីរនាក់បានទទួលការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ព្រមទាំងមុខវិជ្ជាជាច្រើនរួមមានទាំងនីតិជាតិ អន្តរជាតិ ថែមទាំងនីតិឯកជន និងនីតិសាធារណៈ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចរួចមក។ ដោយក្រោមការ យកចិត្តទុកដាក់ ប្រឹងប្រែងបង្ហាត់បង្រៀនរបស់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ ទើបយើងខ្ញុំទាំងពីរមានឱកាសឈានដល់ការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី២១ និងជាចំណែកមួយក្នុងការអភិវឌ្ឍន៍វិស័យអប់រំនៅកម្ពុជា។ ជាមួយគ្នានេះដែរ ការសរសេរសារណា មិនមែនងាយស្រួលដូចជាកិច្ចការផ្ទះ ឬកិច្ចការស្រាវជ្រាវកន្លងមកនោះទេ តែបែរជាតម្រូវឲ្យយើងទាំងពីរនាក់ត្រូវមានភាពអំនត់ ស៊ូទ្រាំ បូករួមទាំងចំណេះដឹងខ្លះៗ ក្នុងការសរសេរវាឡើងមក ដោយហេតុថាអំឡុងពេលសរសេរ យើងអាចនឹងជួបប្រទះនូវការលំបាកដោយមិនបានគិតទុកជាមុន ដែលវាធ្វើឲ្យយើងទទួលបាននូវភាពរីកចម្រើនទៅមុខក្នុងការដោះស្រាយបញ្ហា។

យើងខ្ញុំទាំងពីរបានជ្រើសរើសប្រធានបទ « **ការអនុវត្តតួនាទីរបស់មេធាវីក្នុងរឿងក្ដី រដ្ឋប្បវេណីនៅកម្ពុជា** » ដើម្បីចងក្រងធ្វើជាសារណាបញ្ចប់ការសិក្សា ដោយយើងទាំងពីរសម្លឹងឃើញថាមានសិស្សច្បងភាគច្រើនបានរៀបចំសំណៅឯកសារ និងសារណាដែលពាក់ព័ន្ធទៅនឹងមេធាវី មេធាវីនៅក្នុងរឿងក្ដីព្រហ្មទណ្ឌប៉ុណ្ណោះ ទើបយើងទាំងពីរសម្រេចថានឹងសរសេរបន្ថែមអំពី តួនាទីរបស់មេធាវីនៅក្នុងព្រះរាជាណាចក្រកម្ពុជា និង ការអនុវត្តជាក់ស្តែងរបស់មេធាវីនៅក្នុងរឿងក្ដីរដ្ឋប្បវេណីក្នុងប្រទេសកម្ពុជា។ ម៉្យាងវិញទៀត ផ្នែករដ្ឋប្បវេណីគឺជាបញ្ហាមួយដែលកំពុងតែកើតឡើងច្រើននាពេលបច្ចុប្បន្ន ហើយមុខវិជ្ជារដ្ឋប្បវេណី គឺជាមុខវិជ្ជាមួយពិបាកនៅក្នុងការសិក្សារឈ្វេងយល់ ហេតុនេះហើយយើងទាំងពីរនាក់ក៏បានសម្រេចចងក្រង រៀបចំសារណានេះឡើងមក ដើម្បីជាចំណេះដឹងដល់បងប្អូនជនរួមជាតិយើង។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរនាក់សង្ឃឹមយ៉ាងមុតមាំថា ស្នាដៃដ៏តូចមួយនេះ នឹងក្លាយជាប្រយោជន៍ ដល់ការអនុវត្តតួនាទីរបស់មេធាវីនៅកម្ពុជា ជាពិសេសទុកឲ្យប្អូនៗ ជំនាន់ក្រោយបានសិក្សាស្វែងយល់បន្ថែមពីចំណុចសំខាន់ៗនៅក្នុងសារណាមួយនេះ។ ទន្ទឹមនឹងនេះ ការចងក្រងសារណានេះឡើង វាអាចនឹងមានការខ្វះចន្លោះដោយប្រការណាមួយ ដែលត្រូវការកែតម្រូវនាពេលខាងមុខ ដូចនេះយើងខ្ញុំទាំងពីរនាក់ សូមមេត្តាខន្តីអភ័យទោសចំពោះរាល់កំហុសឆ្គងក្នុងការតាក់តែងនេះ ហើយក៏សូមស្វាគមន៍នូវការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់អ្នកស្រាវជ្រាវគ្រប់រូបដើម្បីជាបច្ច័យក្នុងការកែលម្អសមិទ្ធិផលមួយនេះឲ្យកាន់តែប្រសើរឡើងថែមមួយកម្រិតទៀត។

# មាតិកា

## សេចក្ដីផ្ដើម


១ លំនាំបញ្ហា នៃការស្រាវជ្រាវ ........ ១

២ ចំណោទបញ្ហា នៃការដោះស្រាយ ........ ១

៣ គោលបំណង នៃការស្រាវជ្រាវ ........ ២

៤ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២

៥ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ២

៦ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ........ ២

៧ រចនាសម្ព័ន្ធ នៃការស្រាវជ្រាវ ........ ៣


## ជំពូកទី១

## សញ្ញាណទូទៅ នៃវិជ្ជាជីវៈមេធាវី


**១.១ ប្រវត្តិនៃការកកើតវិជ្ជាជីវៈមេធាវី**

១.១.១ ការកកើតវិជ្ជាជីវៈមេធាវីដំបូងនៅឆ្នាំ១៩៣២ ........ ៤

១.១.២ វិជ្ជាជីវៈមេធាវីក្រោយឆ្នាំ១៩៩៣ ........ ៥

**១.២ នីតិវិធីនៃការរៀបចំប្រកបវិជ្ជាជីវៈមេធាវី** ........ ៦

១.២.១ លក្ខខណ្ឌ និងនិតិវិធីនៃការប្រឡងប្រកួតប្រជែង ........ ៦

១.២.២ ការចូលប្រកបវិជ្ជាជីវៈតាមរយៈបទពិសោធន៍ក្នុងវិស័យច្បាប់ ........ ៧

**១.៣ តួនាទីទូទៅរបស់មេធាវី**

១.៣.១ ការប្រឹក្សាយោបល់ ........ ៨

១.៣.២ ការតាក់តែង ចងក្រងលិខិតស្នាមគតិយុត្ត ........ ៨

១.៣.៣ ជាអ្នកសម្របសម្រួល និងជាអាជ្ញាកណ្ដាល ........ ៩

១.៣.៤ អ្នកតំណាង ........ ៩

**១.៤ តួនាទីក្នុងវិជ្ជាជីវៈ** ........ ១០

១.៤.១ សហប្រតិបត្តិការជាមួយគណៈមេធាវី ........ ១០

១.៤.២ ការពង្រឹងនីតិរដ្ឋ ........ ១០
**១.៥ តួនាទីចំពោះកូនក្តី** ........ ១១
១.៥.១ ការទទួលការខុសត្រូវ ........ ១១
១.៥.២ ការរក្សាការសម្ងាត់នៃវិជ្ជាជីវៈ ........ ១២
១.៥.៣ ភាពស្មោះត្រង់ក្នុងការបំពេញការងារ ........ ១២
**១.៦ តួនាទីរបស់មេធាវីនៅក្នុងដំណាក់កាលជំនុំជម្រះក្តី** ........ ១៣
១.៦.១ ការដាក់ពាក្យបណ្តឹង ........ ១២
១.៦.២ ចំណុចដែលត្រូវសរសេរ ........ ១៣
ក ភាគី និងអ្នកតំណាង ........ ១៣
ខ ខ្លឹមសារនៃការទាមទារ ........ ១៤
គ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ ........ ១៤

## ជំពូកទី២

## តួនាទីមេធាវីក្នុងការអនុវត្តរឿងក្តីរដ្ឋប្បវេណី នៅសាលាជម្រះក្តីថ្នាក់ទាប

**២.១ ជនដែលត្រូវបានតំណាងដោយអាណត្តិ** ........ ១៦
២.១.១ ដើមចោទ ........ ១៦
២.១.២ ចុងចម្លើយ ........ ១៧
២.១.៣ អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ........ ១៧
**២.២. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ........ ១៧
២.២.១ ការរៀបចំ និងការដាក់ឯកសារត្រៀម ........ ១៨
២.២.២ ការផ្សះផ្សារ ........ ១៩
២.២.២.១ ការផ្សះផ្សារធ្វើឡើងដោយមេធាវី ........ ១៩
២.២.២.២ ការផ្សះផ្សាដោយតុលាការ ........ ២០
២.២.៣ ការអះអាងរបស់គូភាគី ........ ២០
២.២.៤ ការបំភ្លឺនូវចំណុចវិវាទ ........ ២១
២.២.៥ ការពិនិត្យភស្តុតាងជាឯកសារ ........ ២១

**២.៣ នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់** ............ ២២

២.៣.១ ការសាកល្បងធ្វើការផ្សះផ្សា ............ ២២

២.៣.២ ការធ្វើសេចក្ដីថ្លែងការណ៍ ............ ២២

២.៣.៣ ការអះអាងបន្ថែម ............ ២៣

**២.៤ ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់** ............ ២៣

២.៤.១ ដំណាក់កាលក្រោយនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ............ ២៤

២.៤.១.១ ការផ្ដល់យោបល់ឲ្យកូនក្ដី ............ ២៤

២.៤.១.២ ការពន្យល់ពីសិទ្ធិធ្វើបណ្ដឹងឧបាស្រ័យ ............ ២៤

២.៤.១.៣ ការចូលរួមអនុវត្តសាលក្រម ............ ២៤

## ជំពូកទី៣

## តួនាទីមេធាវីក្នុងការអនុវត្តរឿងក្ដីរដ្ឋប្បវេណី នៅសាលាជម្រះក្ដីថ្នាក់ខ្ពស់

**៣.១ បណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់** ............ ២៦

៣.១.១ ប្រភេទនៃបណ្ដឹងឧបាស្រ័យ ............ ២៦

**៣.២ បណ្ដឹងឧទ្ធរណ៍**

៣.២.១ សេចក្ដីសម្រេចដែលអាចប្ដឹងឧទ្ធរណ៍ ............ ២៧

៣.២.២ អ្នកមានសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍ ............ ២៨

៣.២.៣ អំឡុងពេលធ្វើបណ្ដឹងឧទ្ធរណ៍ ............ ២៨

៣.២.៤ របៀបធ្វើបណ្ដឹងឧទ្ធរណ៍ ............ ២៩

៣.២.៥ ការដកពាក្យបណ្ដឹងឧទ្ធរណ៍ ............ ៣០

**៣.៣ បណ្ដឹងសារទុក្ខ**

៣.៣.១ គោលការណ៍ទូទៅ ............ ៣០

៣.៣.២ សេចក្ដីសម្រេចដែលអាចប្ដឹងសាទុក្ខ ............ ៣១

៣.៣.៣ មូលហេតុនៃការធ្វើបណ្ដឹងសាទុក្ខ ............ ៣១

៣.៣.៤ របៀបធ្វើបណ្ដឹងសាទុក្ខ ............ ៣២

**៣.៤ បណ្ដឹងជំទាស់**

៣.៤.១ និយមន័យ ............ ៣២

៣.៤.២ របៀបធ្វើបណ្តឹងជំទាស់ .......... ៣៣
**សេចក្តីសន្និដ្ឋាន** .......... ៣៤
**អនុសាសន៍** .......... ៣៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១ លំនាំបញ្ហា

ព្រះរាជាណាចក្រកម្ពុជាមានការរីកចម្រើនគ្រប់វិស័យ ទើបធ្វើឲ្យវិជ្ជាជីវៈមេធាវីមានការរីឡូតឆ្លោះទៅមុខជាបន្តបន្ទាប់។ ដើម្បីធានាឲ្យមាននូវកិត្យានុភាព នៃការប្រកបវិជ្ជាជីវៈមេធាវី និងទទួលបានទំនុកចិត្តខ្ពស់ពីប្រជាពលរដ្ឋ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតច្បាប់មួយចំនួនពាក់ព័ន្ធនឹងមេធាវី អាចឲ្យមេធាវីធ្វើការអនុវត្តជួយសម្រួលដល់នីតិវិធីក្នុងការប្រកបវិជ្ជាជីវៈមេធាវី។ វិជ្ជាជីវៈនេះបានកកើតនៅក្នុងសង្គមកម្ពុជាជាច្រើនឆ្នាំមកហើយ ដើម្បីពង្រឹងយុត្តិធម៌សង្គម នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ក្នុងសង្គមបច្ចុប្បន្ន មេធាវីមិនត្រឹមដើរតួនាទីជាអ្នកតំណាង និងការពារក្តីទេ តែមេធាវីដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតវិធានច្បាប់។ ថ្វីបើវិជ្ជាជីវៈមេធាវីមានអត្ថិភាពនៅក្នុងសង្គមច្រើនឆ្នាំមែន តែការយល់ដឹងពីតួនាទី និងការអនុវត្តក្នុងវិជ្ជាជីវៈនេះនៅមិនទាន់មានភាពទូលំទូលាយនៅឡើយ។ ការដែលសំខាន់បំផុត គឺមេធាវីអាចបំពេញមុខងាររបស់ខ្លួនដោយគ្មានការកំហិត ឬការជ្រៀតជ្រែងមិនសមស្រប។ មេធាវីដើរតួយ៉ាងសកម្មក្នុងរដ្ឋបាលយុត្តធម៌ និងក្នុងការបង្កើតធម្មាធិបតេយ្យ។

ពាក្យថាមេធាវី មកពីពាក្យថា មេធា មានន័យថាអ្នកប្រាជ្ញ។ មេធាវីជាអ្នកផ្តល់យោបល់ចូលរួមជួយដល់ក្របខ័ណ្ឌគតិយុត្តិនៃ ការវិនិយោគការពារផលប្រយោជន៍របស់វិនិយោគិន ជាផ្នែកមួយនៃការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាតិ។ វិជ្ជាជីវៈមេធាវីត្រូវបានដាក់ឲ្យស្ថិតនៅក្រោមក្របខ័ណ្ឌនៃវិធានវិជ្ជាជីវៈមេធាវី ដែលរួមមានច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ក្រមសីលធម៌មេធាវី និងបទបញ្ជាផ្ទៃក្នុងគណៈមេធាវី ។ មេធាវីមិនមែនជាមន្ត្រីក្នុងក្របខ័ណ្ឌតុលាការ ឬរបស់ក្រសួងយុត្តិធម៌ និងរឹតតែមិនមែនជាបុគ្គលរដ្ឋ។ មេធាវីពុំមានប្រាក់បៀវត្សឡើយ ការប្រកបអាជីពជាមេធាវីនេះ មិនមានការកំណត់អាយុ ឬលក្ខខណ្ឌចូលនិវត្តន៍ទេ។ អ្នកប្រកបអាជីពមេធាវីអាចប្រកបបានមួយជីវិត លើកលែងតែក្នុងករណីសាមីខ្លួនសុំលាលែង ឬទទួលរងវិន័យដោយការលុបឈ្មោះដោយគណៈមេធាវី ឬទទួលការផ្តន្ទាទោសព្រហ្មទណ្ឌណាមួយ ។ ដោយសារមេធាវីមិនមែនជាមន្ត្រីរាជការ ហើយក៏មិនមានប្រាក់បៀវត្សច្បាប់បានកំណត់ឲ្យមេធាវីបំពេញការងារផ្តល់សេវាកម្មច្បាប់ដោយយកកម្រៃពីអតិថិជន ឬ កូនក្តី។ ករណីដែលមេធាវីផ្តល់សេវាមិនយកកម្រៃ ដូចជាការការពារក្តីជូនជនក្រីក្រតាមការចាត់តាំងរបស់គណៈមេធាវី ឬតាមការសម្រេចរបស់សាមីខ្លួនផ្ទាល់ ។

## ២ ចំណោទបញ្ហា នៃការដោះស្រាយ

មេធាវីសំដៅដល់អ្នកច្បាប់ ជាបុគ្គលដែលធ្វើការក្នុងវិស័យច្បាប់។ ការឈ្វេងយល់ពីតួនាទីមេធាវីនៅក្នុងរឿងក្តីរដ្ឋប្បវេណី ពិតជាសំខាន់សម្រាប់អ្នកសិក្សាស្រាវជ្រាវច្បាប់ ឬសម្រាប់អ្នកមានបំណងធ្វើជាមេធាវី។ ហេតុដូចនេះហើយ ទើបការស្រាវជ្រាវនេះ ធ្វើឡើងដោយមានចំណោទបញ្ហាសំខាន់មួយចំនួន ដូចជាៈ

- តើមេធាវីបង្កើតចាប់តាំងពីពេលណា?
- តើត្រូវមានលក្ខខណ្ឌអ្វីខ្លះដើម្បីក្លាយជាមេធាវី?
- តើមេធាវីមានសារៈសំខាន់យ៉ាងដូចម្តេចខ្លះនៅព្រះរាជាណាចក្រកម្ពុជា?
- តើលំហូរនីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណីមានលក្ខណៈយ៉ាងណាខ្លះ?
- តើមេធាវីមានតួនាទីអ្វីខ្លះ នៅក្នុងការអនុវត្តរឿងក្តីរដ្ឋប្បវេណីនៅសាលាជម្រះក្តីថ្នាក់ទាប?
- តើមេធាវីមានតួនាទីអ្វីខ្លះ នៅក្នុងការអនុវត្តរឿងក្តីរដ្ឋប្បវេណីនៅសាលាជម្រះក្តីថ្នាក់ខ្ពស់?

## ៣ គោលបំណង នៃការស្រាវជ្រាវ

គោលបំណងសំខាន់ៗ នៅក្នុងការសិក្សាស្រាវជ្រាវមួយនេះគឺ មានដូចជាៈ

- ដើម្បីឲ្យយល់ដឹងពីដំណើរដើមទងទាក់ទងនឹងប្រវត្តិនៃវិជ្ជាជីវៈមេធាវី
- ដើម្បីធ្វើការសិក្សាស្វែងយល់ឲ្យបានស៊ីជម្រៅអំពីតួនាទីរបស់មេធាវីក្នុងរឿងក្តីរដ្ឋប្បវេណី ក្នុងព្រះរាជាណាចក្រកម្ពុជា ទាំងសាលាជម្រះក្តីជាន់ទាប និងជាន់ខ្ពស់
- ដើម្បីស្វែងយល់ពីនីតិវិធីក្នុងការធ្វើជាមេធាវីចំពោះកូនក្តី នៅក្នុងនីតិវិធីរដ្ឋប្បវេណី
- ដើម្បីទុកជាឯកសារជំនួយដល់អ្នកស្រាវជ្រាវ និងសាធារណៈជនទាំងឡាយ ដើម្បីធ្វើការសិក្សាស្វែងយល់បន្ថែមពីតួនាទីរបស់មេធាវីក្នុងរឿងក្តីរដ្ឋប្បវេណី ។

## ៤ ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវនេះ ផ្តោតសំខាន់លើសញ្ញាណនៃមេធាវី និងដំណើរការរបស់មេធាវីនៅក្នុងការអនុវត្តរឿងក្តីរដ្ឋប្បវេណីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ តួនាទីមេធាវី ដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះជា-ណាចក្រកម្ពុជាឆ្នាំ១៩៩៥ និងក្រមសីលធម៌មេធាវីឆ្នាំ២០១២ និងបញ្ញត្តិស្តីពីតួនាទីមេធាវីនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី គឺជាឯកសារដ៏ចម្បងក្នុងការពិភាក្សា និងវិភាគ។

## ៥ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់ណាស់ក្នុងការចូលរួមចំណែក អភិវឌ្ឍសង្គម និងការស្រាវជ្រាវជាមូលដ្ឋានទាក់ទងនឹងវិជ្ជាជីវៈមេធាវី ក្នុងការធ្វើឲ្យមានកំហុសឆ្គងកាន់តែតិច។ សារណានេះពិតជាជួយ ពង្រីកនូវចំណេះដឹងឲ្យកាន់តែទូលំទូលាយ មានភាពសម្បូរបែប និងវឌ្ឍនភាពនៃសង្គមក្នុងវិស័យច្បាប់។ ដើម្បីការរីក

ចំរើនរបស់សង្គម ការស្រាវជ្រាវនេះគឺតម្រូវការជាចាំបាច់ ព្រោះសង្គមដែលរីកចំរើនឥតឈប់ឈរមិនអាចខ្វះបានទេនូវការស្រាវជ្រាវ វាអាចជាស្នូលមួយដ៏សំខាន់នៃការអនុវត្តវិជ្ជាជីវៈមេធាវី។

## ៦ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះកើតចេញពីការសិក្សាតាមបែបទ្រឹស្តី និងបែបវិភាគទៅលើការអនុវត្តជាក់ស្តែង។ ចំណែកប្រភពឯកសារសំខាន់ៗដែលប្រើប្រាស់ក្នុងការស្រាវជ្រាវនេះ គឺមានដូចជាក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៥ ក្រមសីលធម៌មេធាវីរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១២ បទបញ្ជាផ្ទៃក្នុងគណៈមេធាវីឆ្នាំ២០១៦ និងឯកសារពិគ្រោះផ្សេងៗទៀតដែលចងក្រងដោយសាស្ត្រាចារ្យច្បាប់។ ការស្រាវជ្រាវនេះបានសាកសួរសុំការបំភ្លឺណែនាំពីមេធាវី ដែលធ្វើការអនុវត្តផ្ទាល់ ដើម្បីធ្វើយ៉ាងណាឲ្យប្រាកដថាការសិក្សាស្រាវជ្រាវមួយនេះមានភាពត្រឹមត្រូវ និងជាប្រយោជន៍ដល់អ្នកសិក្សាស្រាវជ្រាវច្បាប់។

## ៧ រចនាសម្ព័ន្ធ នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ ចែកចេញជា៣ជំពូក។ ជំពូកទី១ ពិពណ៌នាពីការវិវត្តជាប្រវត្តិសាស្ត្រ និងគោលការគ្រឹះក្នុងការប្រកបវិជ្ជាជីវៈមេធាវី។ ចំណែកឯជំពូកទី២ ពិភាក្សាពីដំណើរការរបស់មេធាវីក្នុងការធ្វើនីតិវិធីរដ្ឋប្បវេណីនៅក្នុងសាលាជម្រះក្តីជាន់ទាប ។ ជំពូកទី៣ រៀបរាប់អំពីការអនុវត្តរបស់មេធាវីនៅសាលាជម្រះក្តីជាន់ខ្ពស់ នៅក្នុងរឿងក្តីរដ្ឋប្បវេណី។

# ជំពូកទី១
# សញ្ញាណទូទៅ នៃវិជ្ជាជីវៈមេធាវី

## ១.១ ប្រវត្តិនៃការកកើតវិជ្ជាជីវៈមេធាវី

### ១.១.១ ការកកើតវិជ្ជាជីវៈមេធាវីដំបូងនៅឆ្នាំ១៩៣២

វិជ្ជាជីវៈមេធាវី ជាវិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបម្រើវិស័យយុត្តិធម៌ និងប្រព្រឹត្តទៅបានក្នុងក្របខ័ណ្ឌនៃគណៈមេធាវី។[1] អាជីព ឬមុខរបរជាមេធាវីនេះ បានកើតមានឡើងតាំងពីសតវត្សរ៍ទី៥ មុនគ្រឹស្តសករាជមកម្លេះ នៅឯទីក្រុងអាតែន ប្រទេសក្រិច ដែលពេលនោះ មេធាវីជាអ្នកប្រកបរបរស៊ីឈ្នួលនិយាយ ឬជជែកពិភាក្សាដេញដោលដោយយកកម្រៃ។[2] ជាបន្តបន្ទាប់វិជ្ជាជីវៈនេះ ត្រូវបានវិវត្តន៍ទៅតាមចរន្តនៃការរីកចម្រើនរបស់ពិភពលោក ហើយត្រូវបានចងក្រងជាបទដ្ឋាននៃក្របខ័ណ្ឌវិជ្ជាជីវៈជាក់លាក់មួយ។ សម្រាប់សង្គមកម្ពុជាវិជ្ជាជីវៈមេធាវីទើបតែហូរចូលក្នុងរយៈពេលជាងមួយសតវត្សរ៍ចុងក្រោយនេះប៉ុណ្ណោះ។[3] នៅដើមសតវត្សរ៍ទី២០ អំឡុងទសវត្សរ៍ឆ្នាំ១៩៣០ វិជ្ជាជីវៈមេធាវីត្រូវបានលេចរូបរាងជាផ្លូវការតាមរយៈព្រះរាជប្រកាសរបស់ព្រះមហាក្សត្រ ប៉ុន្តែនាពេលនោះវិជ្ជាជីវៈមេធាវីត្រូវបានគេហៅថា **វិជ្ជាជីវៈស្នាក្តី** ហើយអ្នកអនុវត្តវិជ្ជាជីវៈនេះហៅថា **អ្នកថណាយក្តី**។[4] ដោយសារការវិវត្តន៍របស់សង្គមជាតិ ជាមួយនឹងការដាក់ចេញនូវបទបញ្ញត្តិជាច្រើនដោយរដ្ឋ ដើម្បីធ្វើការគ្រប់គ្រងនូវការវិវត្តន៍ទាំងនោះ បានធ្វើឲ្យវិជ្ជាជីវៈស្នាក្តីកាន់តែផុសអណ្តែតឡើងក្នុងសកម្មភាពសង្គមដើម្បីចូលរួមសម្របសម្រួលដល់ការប្រាស្រ័យទាក់ទង ទាំងក្នុងជីវិតឯកជន និងក្នុងវិស័យពាណិជ្ជកម្ម របស់ប្រជាពលរដ្ឋ។ បន្ទាប់មក វិជ្ជាជីវៈនេះត្រូវបានប្រែក្លាយមកជាវិជ្ជាជីវៈមេធាវី។ ប្រព័ន្ធមេធាវីនៅប្រទេសកម្ពុជា មានប្រវត្តិមិនយូរឆ្នាំដូចប្រទេសអភិវឌ្ឍន៍នោះទេ ដោយសារប្រទេសកម្ពុជាជាប្រទេសរាជានិយមមានទម្លាប់ដោះស្រាយវិវាទដោយព្រះមហាក្សត្រ មេភូមិ ព្រះសង្ឃ ឬអ្នកជិតខាង។[5] ការគ្រប់គ្រងរដ្ឋបែបទំនើប ទើបតែត្រូវបាននាំចូលក្នុងសម័យអាណានិគមបារាំងអំឡុងសតវត្សទី១៩តែប៉ុណ្ណោះ។

ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ វិជ្ជាជីវៈមេធាវីនៅកម្ពុជាពុំសូវមានការវិវឌ្ឍល្អប៉ុន្មានទេ ដោយសារការប្រែប្រួលនៃសង្គម និងរបបនយោបាយឥតឈប់ឈររហូតធ្លាក់ដល់សូន្យ។ អំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប្រព័ន្ធគ្រប់គ្រងរដ្ឋត្រូវបានផ្លាស់ប្តូរទាំងស្រុងហើយវិជ្ជាជីវៈមេធាវីពុំត្រូវបានគេ

---

[1] ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី,លេខ នស/រកម/០៨៩៥/០៦, ១៥ មិថុនា ១៩៩៥, មាត្រា១ ។

[2] ប៊ុន ហុន, *វិជ្ជាជីវៈមេធាវីនៅក្នុងសង្គមកម្ពុជា*, បោះពុម្ពលើកទី២(ភ្នំពេញ៖HBS Law, ២០១៦), ១។

[3] ប៊ុន ហុន, *វិជ្ជាជីវៈមេធាវីនៅក្នុងសង្គមកម្ពុជា*, បោះពុម្ពលើកទី២(ភ្នំពេញ៖HBS Law, ២០១៦), ១។

[4] ប៊ុន ហុន, *វិជ្ជាជីវៈមេធាវីនៅក្នុងសង្គមកម្ពុជា*, បោះពុម្ពលើកទី២(ភ្នំពេញ៖HBS Law, ២០១៦), ២។

[5] ប៊ុន ហុន, *វិជ្ជាជីវៈមេធាវីនៅក្នុងសង្គមកម្ពុជា*, បោះពុម្ពលើកទី២(ភ្នំពេញ៖HBS Law, ២០១៦), ១។

យកមកប្រើទាល់តែសោះ។[6] អ្នកច្បាប់ដែលរួមមានចៅក្រម ព្រះរាជអាជ្ញា មេធាវី សាស្ត្រាចារ្យ ដែលជាបុគ្គលសំខាន់នៅក្នុងវិស័យតុលាការភាគច្រើនត្រូវបានសម្លាប់ស្ទើរគ្មានសល់។ ក្រោយការបញ្ចប់សង្គ្រាម អ្នកច្បាប់ដែលនៅរស់ នៅសល់តែ៦នាក់តែប៉ុណ្ណោះ។[7] ការចាប់ផ្តើមជាថ្មីនៃវិជ្ជាជីវៈមេធាវី ធ្វើឡើងបន្ទាប់ពីមានការបង្កើតតុលាការខេត្ត ក្រុងបដិវត្តប្រជាជនក្នុងឆ្នាំ១៩៧៩។[8]

### ១.១.២ វិជ្ជាជីវៈមេធាវីក្រោយឆ្នាំ១៩៩៣

រហូតដល់ឆ្នាំ១៩៩៥ តាមរយៈការបង្កើតគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា វិជ្ជាជីវៈមេធាវីនៅកម្ពុជាត្រូវបានរៀបចំឡើងវិញ ដោយមានការចុះបញ្ជីនៅក្នុងបញ្ជីមេធាវីដើម្បីប្រកបវិជ្ជាជីវៈនេះ និងចាប់ផ្តើមមានការជ្រើសរើសបេក្ខជនប្រឡងចូលរៀនក្នុងវគ្គបណ្តុះបណ្តាលមេធាវី។ យោងតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ជនដែលអាចប្រកបវិជ្ជាជីវៈជាមេធាវីបានត្រូវមានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវីចេញដោយមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។ ប៉ុន្តែនៅឆ្នាំ១៩៩៥ មជ្ឈមណ្ឌលនេះ ពុំទាន់ត្រូវបានបង្កើតនៅឡើយ គណៈមេធាវីបានបង្កើតវគ្គបណ្តុះបណ្តាលរយៈពេល៨ខែ ដើម្បីបំពេញតម្រូវការមេធាវីក្នុងសង្គម។ អ្នកដែលអាចប្រឡងចូលរៀនវគ្គនេះបាន គឺអ្នកដែលមានបទពិសោធន៍ការពារក្តីរយៈពេលយ៉ាងតិច២ឆ្នាំ និងមន្ត្រីរាជការដែលបានបម្រើការងាររដ្ឋយ៉ាងតិច២ឆ្នាំ។ ចំណែក អ្នកដែលមានបរិញ្ញាបត្រច្បាប់ ពុំចាប់បាច់ឆ្លងកាត់ការប្រឡងទេ។ លើសពីនេះទៅទៀត អ្នកមានបរិញ្ញាបត្រច្បាប់ ឬសញ្ញាបត្រសមមូលដែលបានបំពេញការងារក្នុងវិស័យច្បាប់ ឬតុលាការយ៉ាងតិច២ឆ្នាំ អ្នកមានសញ្ញាបត្របណ្ឌិតច្បាប់ និងចៅក្រម ឬអតីតចៅក្រមដែលបានបំរើការងារយ៉ាងតិច០២(ពីរ)ឆ្នាំ អាចដាក់ពាក្យសុំចុះបញ្ជីជាមេធាវី ដោយពុំចាំបាច់ឆ្លងកាត់ការប្រឡង ការបណ្តុះបណ្តាល ឬកម្មសិក្សាឡើយ។ ការចុះបញ្ជីមេធាវីត្រូវបានអនុវត្តរយៈពេល២ឆ្នាំ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧។ រហូតដល់ឆ្នាំ ២០០១ ទើបមានអនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលនិងសុក្រឹតការវិជ្ជាជីវៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។ មជ្ឈមណ្ឌលមេធាវីជាក់ស្តែងពុំទាន់បានបង្កើតនៅក្នុងឆ្នាំ១៩៩៣ នៅឡើយទេ រហូតដល់ឆ្នាំ២០០២ ទើបចាប់ផ្តើមមានការប្រឡងប្រជែងជ្រើសរើសសិស្សមេធាវីអោយចូលរៀននៅមជ្ឈមណ្ឌលមេធាវី។

[6] ប៊ុន ហុន, *វិជ្ជាជីវៈមេធាវីនៅក្នុងសង្គមកម្ពុជា*, បោះពុម្ពលើកទី២(ភ្នំពេញ៖HBS Law, ២០១៦), ៣។

[7] យក់ ង៉ុយ និង អុង ចំរើន, *ប្រវត្តិសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច* (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១១), ១៥។

[8] ច្បាប់ស្តីពីការរៀបចំអង្គការ, លេខ០២, ១០ កុម្ភៈ ១៩៨២។

## ១.២ នីតិវិធីនៃការរៀបចំប្រកបវិជ្ជាជីវៈមេធាវី

ការស្នើសុំចូលប្រកបវិជ្ជាជីវៈមេធាវីនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺត្រូវបានគ្រប់គ្រង និងកំណត់លក្ខខណ្ឌដោយច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី និងបទប្បញ្ញត្តិមួយចំនួនទៀត ដែលចេញដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ អ្នកដែលមានបំណងចង់ចូលប្រកបវិជ្ជាជីវៈមេធាវី គួរគប្បីសិក្សាស្វែងយល់ពីលក្ខខណ្ឌតម្រូវ និងស្វែងយល់បន្ថែមពីវិធានវិជ្ជាជីវៈមេធាវី។ ការរៀបចំចូលប្រកបវិជ្ជាជីវៈមេធាវីមាននីតិវិធីពីររបៀប គឺទី១ តាមរយៈការប្រឡងប្រកួតប្រជែង និងទី២តាមរយៈបទពិសោធន៍ក្នុងវិស័យច្បាប់ ។

### ១.២.១ លក្ខខណ្ឌ និងនីតិវិធីនៃការប្រឡងប្រកួតប្រជែង

ដើម្បីអាចបំពេញការងារលើវិជ្ជាជីវៈមេធាវីបាន បុគ្គលដែលមានបំណងចង់ចាប់យកវិជ្ជាជីវៈនេះ ត្រូវឆ្លងកាត់ការស្នើសុំការប្រលងធ្វើតេស្តសមត្ថភាព និងវគ្គបណ្តុះបណ្តាលផ្សេងៗ។ ការប្រលងធ្វើតេស្តសមត្ថភាព ឬការចូលមេធាវីតាមរបៀបទី១ គឺតាមរយៈការប្រឡងប្រកួតប្រជែង ដែលតម្រូវឲ្យមានលក្ខណ្ឌមួយចំនួនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈមេធាវី។ កត្តាចម្បងដែលអាចប្រឡងចូលវិជ្ជាជីវៈមេធាវីបានគឺតម្រូវឲ្យមានសញ្ជាតិខ្មែរ។[9]បុគ្គលគ្រប់រូបត្រូវមានបរិញ្ញាបត្រច្បាប់ឬសញ្ញាបត្រច្បាប់ដែលបានប្រកាសថាមានតម្លៃសមមូល។ ម្យ៉ាងតម្រូវឲ្យមាននូវវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ដែលចេញដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។ ដើម្បីទទួលបានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ត្រូវធ្វើការសិក្សារយៈពេល ១ ឆ្នាំ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។ អ្នកដែលត្រៀមចូលប្រកបវិជ្ជាជីវៈនេះ ត្រូវប្រាកដថាមិនដែលបានផ្តន្ទាទោសជាបទមជ្ឈិម ឬឧក្រិដ្ឋ ឬផ្តន្ទាទោសជាបទវិន័យ ឬផ្តន្ទាទោសជាបទរដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំឡើយ ហើយមិនត្រូវមានធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ។ បុគ្គលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយមានបំណងចូលប្រកបវិជ្ជាជីវៈមេធាវី ត្រូវមកទិញពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី នៅនាយកដ្ឋានបុគ្គលិក និងរដ្ឋបាលនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (ការដាក់ពាក្យសុំ និងឯកសារតម្រូវផ្សេងៗត្រូវកំណត់ដោយគណៈមេធាវី) តាមការប្រកាសរបស់គណៈមេធាវីនៅរៀងរាល់ម៉ោងធ្វើការនៃថ្ងៃបំពេញការងារ។[10]

---

[9] ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី,លេខ នស/រកម/០៨៩៥/០៦, ១៥ មិថុនា ១៩៩៥, មាត្រា៣១ ។

[10] សេចក្តីសម្រេចស្តីពីនីតិវិធីនៃការទទួលពិនិត្យ និងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី, លេខ ១១៦/សសគម/២១, ១៥ កុម្ភៈ ២០២១, ប្រការ ៤ និងប្រការ ១៤។

### ១.២.២ ការចូលប្រកបវិជ្ជាជីវៈតាមរយៈបទពិសោធន៍ក្នុងវិស័យច្បាប់

ក្នុងករណីចូលប្រកបវិជ្ជាជីវៈតាមរយៈបទពិសោធន៍ក្នុងវិស័យច្បាប់ ឬចូលប្រកបវិជ្ជាជីវៈមេធាវីតាមរបៀបទី២ គណៈមេធាវីមិនតម្រូវឲ្យមានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងមានបរិញ្ញាបត្រច្បាប់នោះទេ។[11] ប្រសិនបើបុគ្គលនោះ គឺជាចៅក្រមដែលបានបម្រើការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ០៥ ឆ្នាំ និងអតីតចៅក្រមដែលមានសញ្ញាបត្រមធ្យមសិក្សាច្បាប់ ហើយដែលបានបម្រើក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ០២ ឆ្នាំ ក៏អាចចូលប្រកបវិជ្ជាជីវៈដោយមិនចាំបាច់មានការប្រឡងបាន។[13] ប៉ុន្តែមានករណីមួយចំនួនទៀត អ្នកស្នើសុំចូលប្រកបវិជ្ជាជីវៈមិនចាំបាច់មានវិញ្ញាបនបត្រខាងវិជ្ជាជីវៈមេធាវីនោះទេ បើបុគ្គលនោះស្ថិតក្នុងលក្ខខណ្ឌមួយចំនួនដូចជា៖ មានបរិញ្ញាបត្រច្បាប់ ហើយបានបម្រើការងារក្នុងវិស័យច្បាប់ ឬតុលាការលើសពី ២ឆ្នាំ។ មេធាវីដែលមានសញ្ជាតិដើមជាខ្មែរ ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅបរទេស។ សំរាប់បុគ្គលដែលមានសញ្ញាបត្របណ្ឌិតច្បាប់ក៏អាចចូលប្រកបវិជ្ជាជីវៈមេធាវីដោយស្វ័យប្រវត្តិបាន។[13]

ថ្វីបើចូលប្រកបវិជ្ជាជីវៈមេធាវីតាមរយៈបទពិសោធន៍ មិនត្រូវចូលប្រឡងដូចមាត្រា៣១ តែអ្នកដែលដាក់ពាក្យចូលប្រកបតាមមាត្រា៣២[13] នឹងត្រូវធ្វើអធិការកិច្ចដើម្បីត្រួតពិនិត្យអំពីភាពត្រឹមត្រូវនៃឯកសារ និងត្រូវឆ្លងកាត់ការប្រលងធ្វើតេស្តសមត្ថភាពលើវិញ្ញាសាសរសេរ និងវិញ្ញាសាសួរផ្ទាល់មាត់ផងដែរ។ ការយល់ព្រមឱ្យប្រកបវិជ្ជាជីវៈមេធាវីត្រូវសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី ក្រោយពីបានពិនិត្យលើការបំពេញលក្ខ ខណ្ឌសព្វគ្រប់ដែលមានកំណត់ក្នុងច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ។[12] ក្រោយពីមានយោបល់របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ។ ក្នុងករណីដែលសាមុីខ្លួន មិនយល់ស្របតាមសេចក្ដីសម្រេចរបស់គណៈមេធាវី សាមុីខ្លួនអាចប្ដឹងតវ៉ាទៅសាលាឧទ្ធរណ៍ភ្នំពេញបាន ក្នុងរយៈពេល ០២ខែ ចាប់ពីថ្ងៃទទួលដំណឹង។

សម្រាប់មេធាវីដែលត្រូវបានទទួលឱ្យប្រកបវិជ្ជាជីវៈមេធាវី ត្រូវធ្វើសច្ចាប្រណិធានជាមុននៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញ ដោយមានវត្តមានរបស់ប្រធានគណៈមេធាវី ឬតំណាងដែលចាត់តាំងដោយប្រធានគណៈមេធាវី។ ដើម្បីធានាឱ្យបាននូវគុណភាព និងប្រសិទ្ធភាពក្នុងការបំពេញការងាររបស់មេធាវី មេធាវីដែលទើបបានចុះឈ្មោះត្រូវធ្វើកម្មសិក្សារយៈពេល ០១ឆ្នាំ តាមបែបបទដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវីលើកលែងតែមេធាវីណាដែលមានការអនុញ្ញាតឱ្យរួចពីកម្មសិក្សា។[13] ក្នុងរយៈពេលនៃកម្មសិក្សា មេធាវីត្រូវទទួលការបំប៉នបន្ថែមដែលរៀបចំឡើងដោយគណៈមេធាវី និងត្រូវចូលរួមបម្រើការងារឲ្យពិតប្រាកដ

[11] ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី,លេខ នស/រកម/០៨៩៥/០៦, ១៥ មិថុនា ១៩៩៥, មាត្រា៣២ ។

[12] សេចក្ដីសម្រេចស្ដីពីនីតិវិធីនៃការទទួលពិនិត្យ និងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី, លេខ ១១៦/សសគម/២១, ១៥ កុម្ភៈ ២០២១,គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[13] បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, លេខ២២០/គ.ម/១៦, ១៣ តុលា ២០១៦, ប្រការ២៨។

ក្នុងនាមជាសហការីក្នុងការិយាល័យមេធាវីណាមួយ។ នៅអំឡុងពេលនោះ ក្រុមប្រឹក្សាគណៈមេធាវីនឹងចាត់មេធាវីម្នាក់ ជាមេធាវីពេញសិទ្ធិដែលប្រកបវិជ្ជាជីវៈមេធាវីយ៉ាងតិច ០៣ ឆ្នាំ ដើម្បីធ្វើជាគ្រូកម្មសិក្សា[14] ដែលត្រូវបានជ្រើសរើសដោយស្ម័គ្រចិត្ត និងតាមការព្រមព្រៀងរវាងគ្រូកម្មសិក្សា និងកម្មសិក្សាការី ដោយត្រូវមានកិច្ចសន្យាសហការរវាងគ្រូកម្មសិក្សា និងកម្មសិក្សាការី។ គ្រូកម្មសិក្សា បានដើរតួនាទីយ៉ាងសំខាន់ត្រូវទទួលខុសត្រូវក្នុងការបង្ហាត់បង្រៀន និងផ្តល់ចំណេះដឹងដល់កម្មសិក្សាការីចំពោះការប្រកបវិជ្ជាជីវៈមេធាវី និងការធ្វើរបាយការណ៍បញ្ចប់កម្មសិក្សា។

ក្នុងអំឡុងពេលកម្មសិក្សា ចំពោះកម្មសិក្សាការីដែលចូលប្រកបតាមមាត្រា៣២ ត្រូវចូលរួមក្នុងវគ្គសុក្រិត្យការវិជ្ជាជីវៈមេធាវី និងការបណ្តុះបណ្តាលនានាតាមការកំណត់របស់គណៈមេធាវី។ ក្រោយពេលបញ្ចប់កម្មសិក្សា និងផ្អែកលើរបាយការណ៍មានលក្ខណៈត្រឹមត្រូវតាមការកំណត់នៃលក្ខខណ្ឌ ទម្រង់ និងខ្លឹមសារហើយក្រុមប្រឹក្សាគណៈមេធាវីនឹងសម្រេចចុះឈ្មោះរបស់កម្មសិក្សាការីក្នុងបញ្ជីគណៈមេធាវី។

## ១.៣ តួនាទីទូទៅរបស់មេធាវី

### ១.៣.១ ការប្រឹក្សាយោបល់

ការប្រឹក្សាយោបល់ មេធាវីទៅកាន់អតិថិជន ឬកូនក្តី គឺជាការណែនាំបង្ហាញអំពីប្រភេទ និងទម្រង់នៃបញ្ហា ឬវិវាទផ្សេងៗដែលអតិថិជនកំពុងតែជួបប្រទះ។ មេធាវី មានតួនាទីជាផ្តល់យោបល់ វិភាគ និងឆ្លុះបញ្ចាំងអំពីឫសគល់នៃបញ្ហា រួមទាំងតម្រង់ទិសដល់អតិថិជនក្នុងការរកដំណោះស្រាយនៃបញ្ហាផងដែរ។ អំឡុងពេលប្រឹក្សាយោបល់ មេធាវីមានភារកិច្ចប្រមូលនូវព័ត៌មាន អំពីអង្គហេតុ និងភស្តុតាងដែលពាក់ព័ន្ធនឹងវិវាទដែលអតិថិជនមាន រួមទាំងការទាមទាររបស់អតិថិនដែលតម្រូវឱ្យមេធាវីជួយរកដំណោះស្រាយ។ មេធាវីត្រូវផ្តល់ជូនអតិថិជននូវជម្រើសនៃវិធីដោះស្រាយ និងលទ្ធផលដែលអាចរំពឹងទុកបាន ដោយកំណត់បង្ហាញអំពីចំណុចវិជ្ជមាន និងចំណុចអវិជ្ជមាន ស្របតាមវិធីដោះស្រាយដែលអតិថិជនបានជ្រើស។ លើសពីនេះទៀត មេធាវីត្រូវពន្យល់បង្ហាញដល់អតិថិជននៅក្នុងការដោះស្រាយបញ្ហាតាមរយៈយន្តការ នៃការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ ឬដំណើរការនីតិវិធីក្នុងដំណាក់កាលនីមួយៗតាមរយៈយន្តការរបស់តុលាការ។

### ១.៣.២ ការតាក់តែង និងចងក្រងលិខិតស្នាមគតិយុត្ត

ការតាក់តែង ឬចងក្រងលិខិតគតិយុត្តនានាដែលមេធាវីតាក់តែងឡើងសម្រាប់តំណាងឱ្យកូនក្តីរបស់ខ្លួនត្រូវបានធ្វើឡើងតាមរយៈលិខិតប្រគល់សិទ្ធិរបស់កូនក្តីទៅកាន់មេធាវី។ ក្នុងការតាក់តែងលិខិតគតិយុត្តផ្សេងៗមេធាវីមានកាតព្វកិច្ចដូចជា៖ រៀបចំតាក់តែង កិច្ចសន្យាគ្រប់ប្រភេទ និងគ្រប់ទម្រង់ដូចជា កិច្ចសន្យាលក់-

[14] បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, លេខ២២០/គ.ម/១៦, ១៣ តុលា ២០១៦, ប្រការ៣០។

ទិញ[15] កិច្ចសន្យាខ្ចីបរិភោគ[16] កិច្ចសន្យាការងារ កិច្ចសន្យាបញ្ញើ កិច្ចសន្យាម៉ៅការ[17] កិច្ចសន្យាប្រវាស់ កិច្ចសន្យាប្រទានកម្ម កិច្ចសន្យាភតិសន្យា កិច្ចសន្យាខ្ចីចងការប្រាក់[18] កិច្ចសន្យាអាណត្តិ កិច្ចសន្យាក្រុមហ៊ុន កិច្ចសន្យាសះជា កិច្ចសន្យាធនលាភ និងកិច្ចសន្យាដទៃជាច្រើនទៀត ដែលមានលក្ខណៈគតិយុត្ត និងស្រប តាមច្បាប់ទៅតាមតម្រូវការរបស់អតិថិជន ដោយឈរលើផលប្រយោជន៍របស់អតិថិជនជាធំ ។ ក្រៅពីកិច្ចសន្យា មេធាវីមានកាតព្វកិច្ចរៀបចំតាក់តែង កិច្ចព្រមព្រៀងលក្ខន្តិកៈក្រុមហ៊ុន និងឯកសារគតិយុត្តផ្សេងៗទៀត ស្រប តាមតម្រូវការរបស់អតិថិជន ដោយស្ថិតនៅក្នុងលក្ខខណ្ឌច្បាប់ដែលអាចធានាឱ្យបាននូវផលប្រយោជន៍ និង បញ្ចៀសនូវការរំលោភបំពានសិទ្ធិរបស់អតិថិជន ដែលអាចកើតចេញពីឯកសារគតិយុត្តទាំងនោះ ។ មេធាវីមាន សិទ្ធិចុះហត្ថលេខា និងប្រថាប់ត្រា ដោយមានការបញ្ជាក់អំពីភាពត្រឹមត្រូវលើកិច្ចសន្យា ឬកិច្ចព្រមព្រៀង និង លិខិតស្នាមគតិយុត្តផ្សេងៗដែលអនុលោមទៅតាមច្បាប់ ។ ការរៀបចំលិខិតជូនដំណឹងទៅកាន់ភាគីពាក់ព័ន្ធ តាមរយៈការជូនដំណឹងឱ្យធ្វើ ឬហាមឃាត់ការធ្វើសកម្មភាពណាមួយ ដាស់តឿន ឬព្រមានដោយមានការចាត់ វិធានការតាមផ្លូវច្បាប់ ចំពោះសកម្មភាពរំលោភបំពានផ្សេងៗ ស្របតាមអង្គហេតុ និងតាមការចង់បានរបស់ អតិថិជន និងមានលក្ខណៈស្របតាមក្របខណ្ឌច្បាប់ សុទ្ធតែជាកាតព្វកិច្ចរបស់មេធាវី។

### ១.៣.៣ ជាអ្នកសម្របសម្រួល និងជាអាជ្ញាកណ្ដាល

នៅក្នុងវិវាទនានា ជាពិសេសនៅក្នុងវិវាទរដ្ឋប្បវេណី មេធាវីមានតួនាទីតំណាងឱ្យភាគីក្នុងការចូលរួមដំណើរ ការផ្សះផ្សា ចរចា និងសម្របសម្រួល លើគ្រប់វិវាទ។ មេធាវីត្រូវបំពេញតួនាទីជា អាជ្ញាកណ្ដាលដោយរៀបចំដំណើរ ការផ្សះផ្សាលើវិវាទ ក្នុងករណីមានការស្នើសុំ និងការតែងតាំងដោយគូភាគីវិវាទ។

### ១.៣.៤ អ្នកតំណាង

មេធាវី អាចធ្វើជាតំណាងដោយអាណត្តិឱ្យកូនក្ដី តាមរយៈលិខិតពឹងពាក់មេធាវី និងលិខិតប្រគល់សិទ្ធិ របស់កូនក្ដី។ នៅក្នុងរឿងរដ្ឋប្បវេណី មេធាវីធ្វើជាតំណាងឱ្យកូនក្ដីនៅក្នុងសំណុំរឿងមួយចំនួនដូចជា៖ សំណុំ រឿងអង្គសេចក្ដី សំណុំរឿងរក្សាការពារ សំណុំរឿងអនុវត្តដោយបង្ខំ សំណុំរឿងសុំឱ្យជំនុំជម្រះសាជាថ្មី សំណុំរឿង ទាក់ទងនឹងឋានៈបុគ្គល សំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្ដឹង និងសំណុំរឿងដែលពាក់ព័ន្ធនឹងពាក្យសុំ ផ្សេងៗនៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ។

---

[15] ឧបសម្ព័ន្ធទី៨។

[16] ឧបសម្ព័ន្ធទី៩។

[17] ឧបសម្ព័ន្ធទី១០។

[18] ឧបសម្ព័ន្ធទី១១។

## ១.៤ តួនាទីក្នុងវិជ្ជាជីវៈមេធាវី

ក្នុងវិជ្ជាជីវៈជាមេធាវី ការការពារ រក្សាកិត្យានុភាពរបស់ខ្លួន និងគិតពីផលប្រយោជន៍សាធារណៈជាជាងខ្លួនឯងជាកាតព្វកិច្ចដែលមេធាវីត្រូវប្រណិបត្ត។ មេធាវីត្រូវប្រាកដថាសេវាផ្នែកច្បាប់នេះនឹងផ្ដល់ជូនដល់ប្រជាពលរដ្ឋគ្រប់រូប មិនប្រកាន់វណ្ណៈ។ ក្នុងកម្មវិធីជំនួយផ្នែកច្បាប់ មេធាវីត្រូវទទួលរ៉ាប់រងដោយវៀសវាងម៉ត់ចត់នូវបេសកកម្ម និងសេវារបស់ខ្លួន ព្រមទាំងការការពារក្ដីជូនជនក្រីក្រ គណៈមេធាវីប្រគល់ឲ្យដោយមិនយកម្រៃ។[19]

### ១.៤.១ សហប្រតិបត្តិការជាមួយគណៈមេធាវី

មេធាវី មានកាតព្វកិច្ចត្រូវគោរពឱ្យបាននូវបម្រាម នៃការផ្សាយពាណិជ្ជកម្មពីព្រោះ ការផ្សាយពាណិជ្ជកម្មជ្រុលហួសហេតុពេក អាចបណ្ដាលឱ្យមានការយល់ខុស ហើយអាចប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរនៃវិជ្ជាជីវៈដែលមិនមែនជាពាណិជ្ជកម្ម ឬអាជីវកម្មណាមួយឡើយ។ ដោយឡែក នេះជាសេវាមួយដែលជួយបម្រើដល់វិស័យយុត្តិធម៌ ហើយដែលជាកត្តាសំខាន់នោះគឺ សមាគមវិជ្ជាជីវៈមេធាវី និងមេធាវីទាំងអស់ត្រូវតែជាសមាជិកនៃគណៈមេធាវី។[20]

### ១.៤.៣ ការពង្រឹងនីតិរដ្ឋ

មេធាវីត្រូវធានាថា បុគ្គលគ្រប់រូបមានលទ្ធភាពទទួលបានសេវាផ្លូវច្បាប់។[21] បច្ចុប្បន្ននេះ ថវិកាជាតិនៃរដ្ឋាភិបាលកម្ពុជាមិនបានផ្ដល់ការគាំទ្រផ្នែកស្ថាប័ន និងហិរញ្ញវត្ថុដល់ជនទាំងឡាយដែលមិនអាចការពារសិទ្ធិរបស់ពួកគេដោយខ្លួនឯងបាននោះឡើយ។ រដ្ឋាភិបាលកម្ពុជាមានអង្គការតែបីប៉ុណ្ណោះដែលជួយដល់ជនក្រីក្រ និងជនដែលបាត់បង់ឱកាសនានា ដូចជាកុមារ ជនជាតិភាគតិច ជនភៀសខ្លួន ឬជនពិការ ក្នុងការការពារសិទ្ធិរបស់ពួកគេនៅចំពោះមុខតុលាការដែលអង្គការទាំងបីនោះរួមមាន៖ អង្គការជំនួយផ្លូវច្បាប់កម្ពុជា (LAC) ជាអង្គការក្រៅរដ្ឋាភិបាល បង្កើតឡើងក្នុងឆ្នាំ១៩៩៥[22], ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) ដំណើរការឲ្យប្រើប្រាស់ឡើងក្នុងឆ្នាំ១៩៩៥[23]ជាអង្គការក្រៅរដ្ឋាភិបាល និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា[24]។

គណៈមេធាវី មានកាតព្វកិច្ចបង្កើតមជ្ឈមណ្ឌលច្បាប់ដោយបើកចំហនៅទូទាំងប្រទេស ដោយផ្អែកលើការចំណាយផ្ទាល់ខ្លួន ដើម្បីដោះស្រាយបញ្ហានៃការបែងចែកមេធាវីមិនស្មើគ្នា និងការប្រមូលផ្ដុំនៅក្នុងទីក្រុងភ្នំពេញ។ យ៉ាងណាមិញ ដោយការបរាជ័យរបស់រាជរដ្ឋាភិបាលក្នុងការផ្ដល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ឬក្នុងការ

---

[19] ក្រមសីលធម៌មេធាវីរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាគ្មានលេខ, ២១ កញ្ញា ២០១២, មាត្រា៥២។

[20] ក្រមសីលធម៌មេធាវីរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាគ្មានលេខ, ២១ កញ្ញា ២០១២, មាត្រា៥០។

[21] សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្សគ្មានលេខ, ១០ ធ្នូ ១៩៤៨, មាត្រា៧។

[22] www.lac.org.kh(ថតចម្លងថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២) ។

[23] www.cdpcambodia.org.(ថតចម្លងថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២)។

[24] ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី,លេខ នស/រកម/០៨៩៥/០៦, ១៥ មិថុនា ១៩៩៥, មាត្រា២៩ ។

បំពេញតួនាទីផ្នែកស្ថាប័ន របស់ខ្លួននោះ គឺមិនបានធ្វើឱ្យមេធាវី ឬគណៈមេធាវី បោះបង់ចោលនូវកាតព្វកិច្ចវិជ្ជាជីវៈរបស់ពួកគេនោះឡើយ។ គណៈមេធាវី ត្រូវតែផ្តល់សេវាផ្លូវច្បាប់ស្មើគ្នាដល់ជនគ្រប់ៗរូប រួមទាំងជនដែលជួបប្រទះបញ្ហាលំបាកដោយសាររស់នៅតំបន់ឆ្ងាយផងដែរ។ ហេតុដូច្នេះ មេធាវីត្រូវធានាថា បុគ្គលគ្រប់រូបមានលទ្ធភាពទទួលបាននូវសេវាផ្លូវច្បាប់។

## ១.៥ តួនាទីចំពោះកូនក្តី

មេធាវី ត្រូវតែបំពេញតួនាទី ដើម្បីជាប្រយោជន៍កូនក្តីដោយសេចក្តីស្មោះត្រង់ និងបញ្ចេញឲ្យអស់នូវចំណេះដឹង និងសមត្ថភាពខ្លួនស្របតាមច្បាប់។ មេធាវី ត្រូវបំពេញកាតព្វកិច្ចជូនកូនក្តីប្រកបដោយសេចក្តីព្យាយាម អំពីរឿងក្តីដែលកូនក្តីបានពឹងពាក់។ នៅពេលជំនុំជម្រះមេធាវីត្រូវរៀបចំ និងបង្ហាញការទាមទារ ឬការការពារសម្រាប់កូនក្តី។ ការកសាងជំនឿ និងទំនុកចិត្តដល់កូនក្តី រក្សាការសម្ងាត់ជាដាច់ខាត[25]ដើម្បីការពារផលប្រយោជន៍របស់កូនក្តីជាភារកិច្ចដែលមេធាវីគួរធ្វើ។

មេធាវី កំណត់តាមសតិសម្បជញ្ញៈរបស់ខ្លួន និងដោយមានការយល់ព្រមពីកូនក្តី នូវអ្វីដែលខ្លួនត្រូវលើកឡើងដើម្បីការពារផលប្រយោជន៍របស់កូនក្តីដែលខ្លួនទទួលបន្ទុក។ មេធាវី ពុំអាចបំពានលើការសម្ងាត់វិជ្ជាជីវៈបានឡើយ ហើយក៏មិនអាចត្រូវបានបង្ខំឱ្យបំពារបំពានលើការសម្ងាត់នៃវិជ្ជាជីវៈរបស់ខ្លួន ទោះបីជានៅមុខតុលាការក៏ដោយ។ មេធាវីត្រូវទុកជាការសម្ងាត់នៃវិជ្ជាជីវៈ ការពិគ្រោះយោបល់ និងការផ្តល់យោបល់ឯកសារក្រៅផ្លូវការទាំងឡាយ ដែលមេធាវីតាក់តែងឡើងសម្រាប់កូនក្តីរបស់ខ្លួន លិខិតស្នាមទាំងឡាយដែលមេធាវី និងអតិថិជនរបស់ខ្លួនបានផ្ញើទាក់គ្នា។ លើសពីនេះទៅទៀត មេធាវីត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់ដាច់ខាត។[26] ដោយឡែកនៅពេលដែលមេធាវី ត្រូវឆ្លើយតបចំពោះវិធានការច្បាប់ នៅក្នុងកម្រិតចាំបាច់សម្រាប់ការពារកូនក្តី ពុំមានកាតព្វកិច្ចក្នុងការរក្សាការសម្ងាត់នោះឡើយ។

### ១.៥.១ ការទទួលខុសត្រូវ

នៅក្នុងរឿងក្តីរដ្ឋប្បវេណី មេធាវីជាអ្នកទទួលខុសត្រូវទាមទារសំណងទាំងផ្លូវកាយ ផ្លូវចិត្ត ខាងសម្ភារៈពីជនជាប់ចោទ ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី។ វត្តមានរបស់មេធាវីនៅក្នុងរឿងក្តីរដ្ឋប្បវេណី មិនចាំបាច់ដូចនៅក្នុងរឿងក្តីព្រហ្មទណ្ឌនោះទេ។[27] ដើមចោទ ឬចុងចម្លើយអាចចូលខ្លួនមកតុលាការដោយខ្លួនឯងក៏បាន ឬផ្ទេរសិទ្ធិជូនមេធាវីឱ្យធ្វើជាអ្នកតំណាងដោយអាណត្តិជំនួសខ្លួនក៏បានដែរ។[21] ដោយហេតុថាច្បាប់ទុកសិទ្ធិឱ្យបុគ្គលម្នាក់ៗអាចជ្រើសរើសមេធាវី ដែលជាផ្នែកមួយអាចជួយជម្រុញដល់ដំណើរការកាត់សេចក្តីបានត្រឹមត្រូវ។

---

[25] ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី,លេខ នស/រកម/០៨៩៥/០៦, ១៥ មិថុនា ១៩៩៥, មាត្រា៥៨ ។

[26] ក្រមសីលធម៌មេធាវីរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាគ្មានលេខ, ២១ កញ្ញា ២០១២, មាត្រា៧។

[27] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ២៦ ឧសភា ២០០៦, មាត្រា៥២។

ម្យ៉ាងវត្តមានមេធាវីតែតែធ្វើឱ្យដំណើរការនីតិវិធីកាន់តែឆាប់រហ័ស។ គ្រប់ការទទួលភារកិច្ចជាមេធាវីត្រូវមើលឲ្យគ្រប់ជ្រុងជ្រោយ តាំងពីពេលចាប់ផ្ដើមចំណាត់ការបណ្ដឹង រហូតបញ្ចប់សវនាការ។ មេធាវីត្រូវមានទំនួលខុសត្រូវរៀបចំបណ្ដឹង ភស្តុតាងជាឯកសារ សេចក្ដីថ្លែងការណ៍ សំណួរដែលត្រូវឆ្លើយ ជារួមគឺរៀបចំចំណុចសំខាន់ដែលជាផលប្រយោជន៍សម្រាប់កូនក្ដី។

### ១.៥.២ ការរក្សាការសម្ងាត់នៃវិជ្ជាជីវៈ

មេធាវី ត្រូវប្រកាន់ភ្ជាប់ឱ្យបានជាដាច់ខាតនូវការរក្សាអាថ៌កំបាំងវិជ្ជាជីវៈ។ ការរក្សាការសម្ងាត់ មេធាវីមិនអាចត្រូវឱ្យជនណាមួយអាចយក ឬដកស្រង់នូវព័ត៌មានទាំងអស់នោះបានឡើយ។ មេធាវីត្រូវចេញលាក់បាំងដើម្បីជៀសវាងនូវការធ្លាយចេញពីអាថ៌កំបាំងទាំងឡាយរបស់កូនក្ដី ដែលនាំឱ្យបាត់បង់ផលប្រយោជន៍របស់ពួកគេ។ មេធាវី មានកាតព្វកិច្ចត្រូវទុកជាការសម្ងាត់វិជ្ជាជីវៈរាល់ការពិគ្រោះយោបល់ ការផ្ដល់យោបល់លើឯកសារផ្លូវការទាំងឡាយដែលមេធាវីតាក់តែងឡើងសម្រាប់អតិថិជនរបស់ខ្លួន លិខិតស្នាមផ្សេងៗជាមួយអតិថិជនធ្វើការទាក់ទងគ្នាត្រូវរក្សាទុកជាការសម្ងាត់។ មេធាវីដែលទទួលពិគ្រោះច្បាប់ ឬតំណាងឲ្យកូនក្ដីរួចហើយមិនអាចនិយាយ ឬទម្លាយរឿងហេតុដែលខ្លួនបានដឹងនោះទៅប្រាប់ជនណាម្នាក់ ឬច្រើននាក់ឲ្យបានដឹងឡើយ លើកលែងតែមានការអនុញ្ញាតពីកូនក្ដីរបស់ខ្លួនជាមុនសិន។[28] ការលាក់លៀមដែលជាប្រយោជន៍ស្របច្បាប់របស់កូនក្ដីមេធាវីមិនគួរធ្វើឡើយ។ មេធាវី រឹតតែមិនត្រូវប្រើល្បិចកេងបន្លំទាញយកផលប្រយោជន៍ពីកូនក្ដីនោះទេ តម្រូវឲ្យប្រកាន់ខ្ជាប់នូវអត្តចរិកថ្លៃថ្នូរ មានទំនួលខុសត្រូវ និងមានការគោរពច្បាប់ឲ្យបានល្អ។

### ១.៥.៣ ភាពស្មោះត្រង់ក្នុងការបំពេញការងារ

មេធាវីត្រូវកសាងជំនឿទំនុកចិត្តរបស់អតិថិជន។ មេធាវីត្រូវគោរពប្រតិបត្តិ នូវគោលការណ៍សុចរិតភាព និងភាពស្មោះត្រង់។[29]មេធាវី មិនអាចក្បត់កូនក្ដីដោយលួចលាក់នូវឯកសាររបស់កូនក្ដី ឬបញ្ចេញព័ត៌មានសំខាន់ៗរបស់កូនក្ដីឱ្យទៅភាគីម្ខាងទៀតទេ។ ម្យ៉ាងវិញទៀត មេធាវីមិនត្រូវលាក់បាំងកូនក្ដីនូវអ្វីដែលខ្លួនយល់ថាគួរប្រាប់ដល់កូនក្ដីដែលជាផលប្រយោជន៍ស្របច្បាប់របស់កូនក្ដី ឬប្រើល្បិចកេងបន្លំទាញយកផលប្រយោជន៍ពីកូនក្ដីបាននោះទេ។ មេធាវី ត្រូវមានសីលធម៌ខ្ពស់ក្នុងការងារ មានសេចក្ដីថ្លៃថ្នូរក្នុងការប្រកបវិជ្ជាជីវៈ។ លើសពីនេះទៅទៀត មេធាវីដែលមានកូនក្ដីច្រើននាក់ពឹងពាក់ក្នុងរឿងតែមួយ មិនត្រូវកាន់ជើងផ្ដល់ប្រយោជន៍ឱ្យតែកូនក្ដីណាមួយទេ។ មេធាវី តំណាងឱ្យភាគីណាមួយ អាចទំនាក់ទំនងនឹងភាគីម្ខាងទៀតបាន តែត្រូវមានការយល់ព្រមពីកូនក្ដី។

[28] ក្រមសីលធម៌មេធាវីរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាគ្មានលេខ, ២១ កញ្ញា ២០១២, មាត្រា១៩។

[29] ក្រមសីលធម៌មេធាវីរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាគ្មានលេខ, ២១ កញ្ញា ២០១២, មាត្រា៧។

ប្រសិនបើ មេធាវីយល់ព្រមទទួលជួយការពារក្តីណាមួយហើយ គឺត្រូវបំពេញបេសកកម្មរបស់ខ្លួនឱ្យអស់ពីសមត្ថភាព និងត្រូវការពារផលប្រយោជន៍កូនក្តីឱ្យដូចជា ការពារផលប្រយោជន៍របស់ខ្លួនឯងដែរ។ ករណីដែលមានការប៉ះពាល់ដល់សម្បជញ្ញៈ មេធាវីអាចសម្រេចបញ្ឈប់បេសកកម្មរបស់ខ្លួនបាន ប៉ុន្តែត្រូវជូនដំណឹងទៅកូនក្តីឱ្យបានដឹងក្នុងរយៈពេលមួយសមរម្យ ដែលអាចផ្តល់លទ្ធភាពដល់កូនក្តី អាចការពារផលប្រយោជន៍របស់ខ្លួនបាន។ មេធាវីដែលឈប់ការពារកូនក្តីដោយប្រការណាមួយនោះ ត្រូវប្រគល់គ្រប់ឯកសារច្បាប់ដើមទាំងឡាយណា ដែលអតិថិជនបានប្រគល់ឱ្យជូនទៅកូនក្តីវិញ។

## ១.៦ តួនាទីរបស់មេធាវីនៅក្នុងដំណាក់កាលជំនុំជម្រះក្តី

### ១.៦.១ ការដាក់ពាក្យបណ្តឹង

ក្នុងដំណើររឿងក្តីរដ្ឋប្បវេណីការដាក់ពាក្យបណ្តឹងជាជំហានដំបូង នៃនីតិវិធីនៅក្នុងតុលាការ។ មេធាវីត្រូវសួរកូនក្តី ដើម្បីកំណត់ពីកម្មវត្ថុនៃការដាក់ពាក្យបណ្តឹង។ នៅមុនពេលដាក់ពាក្យបណ្តឹងមេធាវី អាចធ្វើជាអ្នកតំណាងឲ្យកូនក្តីតាមរយៈកិច្ចព្រមព្រៀង នៅគ្រប់ដំណាក់កាលនៃនីតិវិធី។ នៅក្នុងនីតិវិធីរឿងក្តីរដ្ឋប្បវេណី បើពាក្យបណ្តឹងនោះមានលក្ខណៈផ្ទុយពីច្បាប់បានកំណត់ និងមានចំណុចខ្វះខាត ដែលមិនអាចកែតម្រូវបានតុលាការអាចសម្រេចលើកបណ្តឹងនោះចោល។ ដូច្នេះក្នុងនាមជាមេធាវី ត្រូវរៀបចំពាក្យបណ្តឹងឲ្យបានត្រឹមត្រូវតាមច្បាប់ដែលបានកំណត់ និងត្រូវពន្យល់កូនក្តីរបស់ខ្លួនទាក់ទងនីតិវិធីតុលាការឲ្យបានស៊ីជម្រៅជៀសវាងមានការស្រពិចស្រពិល។ មុនពេលដំណើរការរឿងក្តី អំឡុងពេលធ្វើពាក្យបណ្តឹងមេធាវីត្រូវពន្យល់ពីគុណវិបត្តិនិងគុណសម្បត្តិរបស់រឿងក្តីនោះទៅអតិថិជន។ ដើម្បីសរសេរពាក្យបណ្តឹងទៅតុលាកា មេធាវីគួរកំណត់ពីអង្គហេតុ និងអង្គច្បាប់ នៅក្នុងគោលបំណងនៃខ្លឹមសារក្នុងពាក្យបណ្តឹងនោះ។

#### ១.៦.១.១ ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង

**ក. ភាគី និងអ្នកតំណាង**

ចំណុចដែលត្រូវសរសេរដើម្បីឲ្យពាក្យបណ្តឹងមានសុពលភាព ហៅថាចំណុចចាំបាច់ត្រូវសរសេរបញ្ជាក់នៃពាក្យបណ្តឹង។ នៅពេលដែលមានកង្វះខាតនូវចំណុចណាមួយ នោះពាក្យបណ្តឹងគ្មានសុពលភាពឡើយ។ ពេលនោះ តុលាការត្រូវបង្គាប់ឲ្យកែតម្រូវនូវចំណុចខ្វះខាត ហើយប្រសិនបើមិនធ្វើការកែតម្រូវទេ តុលាការត្រូវលើកបណ្តឹងនោះចោល។ ដូច្នេះ នៅក្នុងពាក្យបណ្តឹងមេធាវីដែលតំណាងដោយអាណត្តិឲ្យកូនក្តី ត្រូវសរសេរបញ្ជាក់ឱ្យច្បាស់លាស់ ថាដើមចោទជាអ្នកណា ចុងចម្លើយជាអ្នកណា ត្រូវបញ្ជាក់ឲ្យបានច្បាស់។ ម្យ៉ាងវិញទៀត មេធាវីត្រូវសរសេរអំពីអត្តសញ្ញាណរបស់ភាគីឲ្យច្បាស់លាស់ដូចជា នាមករណ៍ ភេទ អាយុ លេខអត្ត-សញ្ញាណប័ណ្ណ និងអាសយដ្ឋាន ជាអាទិ៍។

ក្នុងពាក្យបណ្តឹង[30] ការសរសេរបញ្ជាក់អំពីអ្នកតំណាងដោយអាណត្តិ មិនមែនជាចំណុចដែលចាំបាច់ត្រូវសរសេរបញ្ជាក់នៅក្នុងបណ្តឹងទេ។ ហេតុដូច្នេះ ទោះបីជាមានកង្វះខាតអំពីការសរសេរបញ្ជាក់ពីអ្នកតំណាងដោយអាណត្តិនៅក្នុងពាក្យបណ្តឹងក៏ដោយ មិនមែនជាកម្មវត្ថុនៃការបង្គាប់ឱ្យកែតម្រូវពាក្យបណ្តឹង។[31] ម្យ៉ាងក្នុងករណីដែលមេធាវីត្រូវបានជ្រើសតាំងជាអ្នកតំណាងដោយអាណត្តិ គួរតែសរសេរបញ្ជាក់អំពីឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងនោះជាការល្អ។ ការបញ្ជាក់បែបនេះ ដើម្បីបង្ហាញឲ្យដឹងថា អ្នកណាធ្វើជាអ្នកតាមដានបណ្តឹងនោះពិតប្រាកដ ព្រមទាំងមានការងាយស្រួលក្នុងការបញ្ជូនពាក្យបណ្តឹង។

**ខ. ខ្លឹមសារនៃការការទាមទារ**

ភាគី ឬមេធាវី ត្រូវសរសេរបញ្ជាក់ឲ្យច្បាស់លាស់អំពីខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់នៃសាលក្រមដែលខ្លួនបានទាមទារ។ ការសរសេរបញ្ជាក់អំពីសាលក្រមដែលចង់ឲ្យតុលាការចេញ ជាចំណុចមួយចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង។ ការទាមទារនេះ ដើម្បីបញ្ជាក់ឲ្យច្បាស់លាស់អំពីសិទ្ធិអះអាងនៅក្នុងការទាមទារតាមផ្លូវបណ្តឹង ដែលជាកម្មវត្ថុនៃការជំនុំជម្រះក្នុងបណ្តឹងរដ្ឋប្បវេណី ព្រមទាំងកម្រិតនូវវិសាលភាពនៃការជំនុំជម្រះរបស់តុលាការ។ ប្រសិនបើក្នុងករណីដែលទាមទារឲ្យបង់ជាប្រាក់ ភាគី ឬមេធាវី ចាំបាច់ត្រូវបញ្ជាក់ច្បាស់លាស់អំពីចំនួនទឹកប្រាក់ដែលខ្លួនទាមទារនោះ។ ជាឧទាហរណ៍ នៅក្នុងពាក្យបណ្តឹងទាមទារសំណងនៃការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល ការសរសេរបញ្ជាក់អំពីសាលក្រមដែលទាមទារឲ្យតុលាការចេញសាលក្រមបង្គាប់ឲ្យចុងចម្លើយបង់ប្រាក់១០លានរៀល ទៅឲ្យដើមចោទ។

ម្យ៉ាងវិញទៀត ចំណុចដែលទាមទារឲ្យតុលាការចេញ មិនត្រូវភ្ជាប់នូវលក្ខខ័ណ្ឌ ឬកំណត់ពេលទេ។ ជាឧទាហរណ៍ នៅក្នុងពាក្យបណ្តឹងសរសេរថា ប្រសិនបើចុងចោទចាញ់ក្តី ត្រូវប្រគល់ផ្ទះដែលរស់នៅសព្វថ្ងៃមកឱ្យដើមចោទ ដែលប្រការនេះគឺមិនស្របច្បាប់ទេ។ យ៉ាងណាមិញ ក្នុងករណីដែលការបំពេញលក្ខខ័ណ្ឌ បានបញ្ជាក់ច្បាស់លាស់នៅក្នុងដំណើរការនៃការជំនុំជម្រះបណ្តឹងនោះ ពុំបានធ្វើឱ្យប៉ះពាល់ដល់នីតិវិធីបណ្តឹងទេ ហេតុនេះ ការទាមទារអាចអនុញ្ញាតឱ្យមានភ្ជាប់នូវលក្ខខ័ណ្ឌបាន។

**គ. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ**

ក្នុងការទាមទារតាមផ្លូវបណ្តឹង ភាគី ឬមេធាវីតំណាងដោយអាណត្តិត្រូវអះអាងអំពីអត្ថិភាពនៃសិទ្ធិតាមផ្លូវច្បាប់របស់ខ្លួន។ ជាឧទាហរណ៍ កម្មសិទ្ធិរបស់ដើមចោទលើដីធ្លីណាមួយ។ តាមរយៈការសរសេរនូវចំណុចនេះ ភាគី ឬមេធាវីត្រូវអះអាងអំពីសិទ្ធិរបស់ខ្លួនឲ្យបានច្បាស់លាស់។ ដើម្បីដឹងច្បាស់ថា ជាការអះអាងនូវសិទ្ធិណាមួយ កុំឲ្យមានការភ័ន្តច្រឡំ ហើយចាំបាច់ត្រូវសរសេរអំពីអង្គហេតុបញ្ជាក់នូវការអះអាងសិទ្ធិ ដែលត្រូវមាន

[30] ឧបសម្ព័ន្ធទី១ ។

[31] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ២៦ ឧសភា ២០០៦, មាត្រា៧៨។

ភស្តុតាងបញ្ជាក់ ដែលអាចអះអាងបានចំពោះការទាមទារនោះ។ ជាឧទាហរណ៍ ដើមចោទទាមទារឲ្យចុងចម្លើយបង់ប្រាក់មកឲ្យខ្លួន១០លានរៀល ខណៈដែលដើមចោទបានអះអាងថាបានបង្កើតកិច្ចសន្យាខ្ចីបរិភោគជាមួយចុងចម្លើយនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១០ ដោយមានទឹកប្រាក់១០លានរៀល។ ហេតុដូច្នេះ ការទាមទារដែលជាកម្មវត្ថុនៃការជំនុំជម្រះ និងការសម្រេចសេចក្តីក្នុងរឿងក្តីនោះ ត្រូវបានកំណត់ច្បាស់លាស់។

# ជំពូកទី២

# តួនាទីមេធាវីក្នុងការអនុវត្តរឿងក្ដីរដ្ឋប្បវេណី នៅសាលាដំបូងរះក្ដីថ្នាក់ទាប

## ២.១ ជនដែលត្រូវបានតំណាងដោយអាណត្តិ

មេធាវី អាចធ្វើជាអ្នកតំណាងដោយអាណត្តិតាមការពឹងពាក់ពីជនមួយចំនួនដូចជា ដើមចោទ ចុងចម្លើយ និងអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី។ មេធាវីអាចការពារក្ដីឱ្យគ្រប់ជនទាំងឡាយណា ដែលមកពឹងពាក់ខ្លួន ប៉ុន្តែ មេធាវីមានសេរីភាពក្នុងការទទួល ឬមិនទទួលជួយបាន។ ប្រសិនបើមេធាវីយល់ឃើញថា មានការប៉ះពាល់ដល់សតិសម្បជញ្ញៈរបស់ខ្លួន។

ទំនាក់ទំនងរវាងមេធាវី និងកូនក្ដី គឺមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធដែលត្រូវមាននូវកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក។ មេធាវីមានតួនាទីពិគ្រោះយោបល់ និងជាអ្នកតំណាងឱ្យកូនក្ដីនៅក្នុងដំណើររឿងរដ្ឋប្បវេណី។ មេធាវីតម្រូវឱ្យមានលិខិតប្រគល់សិទ្ធិជាអ្នកតំណាងដោយអាណត្តិ[32] លិខិតប្រគល់សិទ្ធតំណាងដោយអាណត្តិ[33] ដែលលិខិតនេះត្រូវទទួលបានដោយផ្ទាល់ពីកូនក្ដី។ ប្រសិនបើមេធាវីទទួលបានការពឹងពាក់ពីកូនក្ដី និងមានយល់ព្រមពីមេធាវីរួចហើយ មេធាវីគប្បីបំពេញកាតព្វកិច្ចឱ្យបានល្អប្រសើរ។ ចំណែកឯការសម្រេចចិត្តទាំងឡាយដែលទាក់ទងនឹងផលប្រយោជន៍ក្នុងរឿងក្ដី ត្រូវមានការយល់ព្រមពីកូនក្ដីរបស់ខ្លួនជាមុនសិន។[34] គួរកត់សម្គាល់ផងដែរថា ភាគីអាចជ្រើសរើសអ្នកតំណាងដោយអាណត្តិបាន តែការជ្រើសតាំងនេះ មិនមែនជាកាតព្វកិច្ចតម្រូវចំពោះភាគីទេ។ ភាគី អាចធ្វើសកម្មភាពបណ្ដឹងដោយខ្លួនឯងក៏បាន។ ទោះបីជា ភាគីបានជ្រើសតាំងអ្នកតំណាងអាណត្តិហើយក៏ដោយ ក៏ភាគីនៅតែអាចចូលរួមនៅក្នុងតុលាការ និងឆ្លើយទាញហេតុផលដោយខ្លួនឯងបាន។ ដោយឡែក សកម្មភាពបណ្ដឹងដែលអ្នកតំណាងដោយអាណត្តិបានធ្វើ ត្រូវបង្កើតអានុភាពដូចគ្នាជាមួយសកម្មភាពបណ្ដឹងដែលភាគីធ្វើដោយផ្ទាល់ខ្លួន។

### ២.១.១ ដើមចោទ

ដើមចោទ គឺជាបុគ្គលទាំងឡាយណា ដែលមានសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់ ហើយត្រូវបានបុគ្គលម្នាក់ទៀតបំពារបំពានសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ដែលនាំឱ្យមានវិវាទនឹងគ្នា។ ជាឧទាហរណ៍ ភាគីម្ខាងបានដាក់ពាក្យបណ្ដឹងទៅតុលាការរដ្ឋប្បវេណីដើម្បីប្ដឹងទាមទារ ដី មួយកន្លែងពីភាគីម្ខាងទៀត។ ដូច្នេះ ភាគីដែលបានដាក់ពាក្យបណ្ដឹងមុនគេមកសាលាដំបូង គឺជាដើមចោទ។ ដើមចោទ ដាក់ពាក្យបណ្ដឹងទៅតុលាការរដ្ឋប្បវេណី ដើម្បីទាមទារឱ្យតុលាការចេញសាលក្រម ដោយកំណត់អំពីសំណងខូចខាត

---

[32] ឧបសម្ព័ន្ធទី២ ។

[33] ឧបសម្ព័ន្ធទី៣។

[34] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៥៣ និងមាត្រា៥៤។

ដែលបង្កឡើងដោយភាគីម្ខាងទៀត។[35] គួរកត់សម្គាល់ថា ពាក្យដើមចោទ ដើមបណ្ដឹងឧទ្ធរណ៍ និងដើមបណ្ដឹងសាទុក្ខ មានន័យប្រហាក់ប្រហែលគ្នា។ ពាក្យនីមួយៗ ត្រូវបានប្រើប្រាស់ទៅតាមកម្រិតនៃសាលាជំនុំជម្រះក្ដីប៉ុណ្ណោះ។ ដើមចោទត្រូវបានប្រើប្រាស់ជាទូទៅ សម្រាប់ការជំនុំជម្រះក្ដីលើកទី១នៅសាលាដំបូង។ ដើមបណ្ដឹងឧទ្ធរណ៍ ត្រូវបានប្រើប្រាស់សម្រាប់ការជម្រះក្ដីនៅសាលាឧទ្ធរណ៍។ ចំណែក ដើមបណ្ដឹងសាទុក្ខត្រូវបានប្រើប្រាស់ក្នុងការជម្រះក្ដីនៅតុលាការកំពូល។ មេធាវី អាចធ្វើជាអ្នកតំណាងដោយអាណត្តិឱ្យជនទាំងនោះបាននូវគ្រប់ដំណាក់កាលនីតិវិធីទាំងអស់។

**២.១.២ ចុងចម្លើយ**

ចុងចម្លើយ គឺជាបុគ្គលដែលត្រូវបានភាគីម្ខាងទៀតប្ដឹងទៅតុលាការរដ្ឋប្បវេណី។ ជាឧទាហរណ៍ ភាគីម្ខាងបានដាក់ពាក្យបណ្ដឹងទៅតុលាការរដ្ឋប្បវេណី ដើម្បីប្ដឹងទាមទារដីមួយកន្លែងពីភាគីម្ខាងទៀត។ ហេតុនេះ ភាគីដែលត្រូវបានគេប្ដឹង គឺជាចុងចម្លើយ។ ចុងចម្លើយអាចត្រូវបានចាត់ទុកថា ជាបុគ្គលដែលបានបំពារបំពានសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ដើមចោទ ប៉ុន្តែពុំមានន័យថា ចុងចម្លើយសុទ្ធតែជាអ្នកបំពារបំពានទាំងអស់នោះទេ។ ដូច្នេះហើយ នៅពេលដែលដើមចោទ បានដាក់ពាក្យបណ្ដឹងប្ដឹងទៅចុងចម្លើយ ចុងចម្លើយអាចចូលឆ្លើយបំភ្លឺ និងឆ្លើយដោះសាររាល់ការទាមទាររបស់ដើមចោទមកលើខ្លួន នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់។ ចុងចម្លើយ ក៏អាចធ្វើការពឹងពាក់មេធាវីដោយផ្ទេរសិទ្ធិឱ្យមេធាវីធ្វើជាអ្នកតំណាងដោយអាណត្តិឱ្យខ្លួន ដើម្បីការពារផលប្រយោជន៍តាមផ្លូវច្បាប់។[36]

**២.១.៣ អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី**

អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី គឺជាជនទាំងឡាយណា ដែលត្រូវទទួលបន្ទុកសងរាល់ការខូចខាតទាំងផ្លូវកាយ និងផ្លូវចិត្ត ដល់អ្នកដែលទទួលរងនូវព្យសនកម្ម។ ជាឧទាហរណ៍ កាលណាមានបញ្ហាកើតឡើងដែលបណ្ដាលមកពីអនីតិជន ភាគច្រើនមានឪពុកម្ដាយ ឬសាច់ញាតិ ជាអ្នកទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីជំនួសឱ្យអនីតិជននោះ ដោយសារតែជននោះស្ថិតនៅក្រោមអំណាចមេបារបស់ខ្លួន។ មេធាវីដែលយល់ព្រមតំណាងដោយអាណត្តិឱ្យដើមចោទ ចុងចម្លើយ និងអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី តម្រូវឱ្យមានភាពស្មោះត្រង់ចំពោះកូនក្ដី។ ចំណែកឯកូនក្ដីគប្បីមានការជឿជាក់ និងភាពស្មោះត្រង់ចំពោះមេធាវីដូចគ្នាវិញ។ ម្យ៉ាងវិញទៀត មេធាវីគួរស្វះស្វែងផ្ដល់ព័ត៌មាន និងភស្តុតាង ដើម្បីជូនសំអាងទៅតុលាការ។

**២.២ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

[35] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៣២ និងមាត្រា៥២។

[36] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៣២ និងមាត្រា៥២។

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជាដំណាក់កាលដើមមួយដែលធ្វើឡើងដោយតុលាការ ដើម្បីរៀបចំសេចក្តីអះអាងរបស់ភាគី និងបំភ្លឺនូវចំណុចវិវាទនៃរឿងក្តី។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបានធ្វើឡើងបន្ទាប់ពីភាគីដើមចោទបានដាក់បណ្តឹងមកកាន់តុលាការ។ នីតិវិធីនេះ គឺជានីតិវិធីមួយដែលតុលាការ ធ្វើការពិគ្រោះយោបល់ជាមួយគូភាគីជាមុនសិន ដើម្បីរៀបចំសេចក្តីអះអាងរបស់ភាគី និងបំភ្លឺនូវចំណុចវិវាទ។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនបានកំណត់ថាអាចធ្វើបានប៉ុន្មានដងនោះទេ។ តុលាការ ធ្វើការកំណត់កាលបរិច្ឆេទនៃនីតិត្រៀមសម្រាប់ការទាញហេតុផល ក្នុងអំឡុងពេល៣០ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់។ម្យ៉ាងវិញទៀត កាលកំណត់កាលបរិច្ឆេទត្រូវធ្វើឡើងនៅរយៈពេលដែលគូភាគីអាចចូលរួមបាន ពីព្រោះក្នុងករណីណាក៏ដោយ តុលាការត្រូវគោរពគោលការណ៍ចំពោះមុខ។[37] នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល បែងចែកជាដំណាក់កាលផ្សេងៗដូចជា: ការសាកល្បងផ្សះផ្សា ការអះអាងរបស់គូភាគី និងការពិនិត្យភស្តុតាងជាឯកសារ ដែលដំណាក់កាលនីមួយនេះ សុទ្ធតែអាចតំណាងដោយមេធាវីបានដើម្បីការពារផលប្រយោជន៍កូនក្តី លើកលែងតែករណីលែងលះ។[38]

ជាគោលការណ៍ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនចាំបាច់បើកជាសាធារណៈទេ។ ផ្ទុយទៅវិញ តុលាការអាចអនុញ្ញាតឱ្យអ្នកដែលតុលាការយល់ឃើញថា សមរម្យអាចចូលជាអ្នកអង្កេតការណ៍បានដូចជា: មេធាវី សាច់ញាតិ ឬសហព័ន្ធជាដើម។ តុលាការអាចសាកសួរភាគី និងបង្គាប់ឱ្យភាគីបញ្ជាក់ភស្តុតាងចំពោះចំណុចណាមួយនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន។ ភាពច្បាស់លាស់នៃអង្គហេតុ និងអង្គច្បាប់ នៅក្នុងពាក្យបណ្តឹងមានភាពសំខាន់ ពីព្រោះថា ការអះអាងអំពីអង្គហេតុនោះនឹងក្លាយទៅជាមូលដ្ឋានរបស់តុលាការនៅក្នុងការចេញសាលក្រម។ ជាងនេះទៅទៀត នៅក្នុងរឿងរដ្ឋប្បវេណី ការធ្វើការអះអាង និងបញ្ជាក់នូវភស្តុតាងឱ្យបានត្រឹមត្រូវ ជាកាតព្វកិច្ចរបស់មេធាវីដែលត្រូវធ្វើជំនួសឱ្យកូនក្តី។[39]

### ២.២.១ ការរៀបចំ និងការដាក់ឯកសារត្រៀម

នៅក្នុងដំណាក់កាលដំបូង នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការអាចបង្គាប់ឱ្យភាគី ដាក់ឯកសារត្រៀមបាន។ ឯកសារត្រៀម គឺជាឯកសារដែលភាគីនីមួយៗដាក់ជូនទៅតុលាការ និងភាគីម្ខាងទៀតក្នុងគោលបំណងជូនដំណឹងអំពីចំណុច ដែលខ្លួននឹងធ្វើសេចក្តីថ្លែងការណ៍នៅពេលកាលបរិច្ឆេទបន្ទាប់។ ឯកសារត្រៀម តម្រូវឱ្យមានសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួន និងសេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់

---

[37] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៣ខ។

[38] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១០៣។

[39] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៩៦។

ឬការពារខ្លួនរបស់ភាគីម្ខាងទៀត។[40] មធ្យោបាយតទល់ ធ្វើឡើងដោយដើមចោទ។ ចំណែកមធ្យោបាយការពារខ្លួន ធ្វើឡើយដោយចុងចម្លើយ។ ជាញឹកញាប់ ត្រូវបានធ្វើឡើងដោយមេធាវីតំណាងដោយអាណត្តិឱ្យគូភាគី។

មធ្យោបាយតទល់ គឺជាការសរសេរនៅក្នុងពាក្យបណ្ដឹងនូវចំណុចចាំបាច់នានា ចំពោះអង្គហេតុដែលជាមូលហេតុនៃការទាមទារ ព្រមទាំងអង្គហេតុសំខាន់ៗដែលទាមទារឱ្យមានការបញ្ជាក់ភស្តុតាង។ ចំណែកមធ្យោបាយការពារខ្លួន គឺជាការសរសេរអំពីការឆ្លើយតប ដែលដើមចោទទាមទារឱ្យតុលាការចេញ ថាតើទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុ ដែលមាននៅក្នុងពាក្យបណ្ដឹងរបស់ដើមចោទ។ មេធាវី គប្បីរៀបចំឯកសារទាំងនេះ ដាក់ជូនទៅតុលាការឱ្យបានត្រឹមត្រូវ និងទៅតាមអំឡុងពេលដែលតុលាការបានកំណត់។

**២.២.២ ការផ្សះផ្សា**

ការផ្សះផ្សា ធ្វើបានគ្រប់ដំណាក់កាលនៃនីតិវិធីទាំងអស់ទាំងក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។ ទោះបីជា បណ្ដឹងស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ ការផ្សះផ្សា នៅតែអាចធ្វើបានតាមរយៈឆន្ទៈរបស់ភាគី ឬតុលាការ មុនពេលដែលសាលក្រមចូលជាស្ថាពរ។

**២.២.២.១ ការផ្សះផ្សាធ្វើឡើងដោយមេធាវី**

ក្នុងនាមជាអ្នកតំណាងដោយអាណត្តិ មេធាវីអាចចូលរួមធ្វើការសាកល្បងផ្សះផ្សាជាមួយភាគីម្ខាងទៀតបាន ប្រសិនបើមានការព្រមព្រៀងពីកូនក្ដីរបស់ខ្លួន។ មេធាវីក៏អាចដើរតួនាទី ជាអ្នកផ្សះផ្សាបានផងដែរ។ ម្យ៉ាងវិញទៀត មេធាវីអាចពន្យល់ណែនាំដល់កូនក្ដី និងបង្ហាញនូវលទ្ធផលល្អ ឬមិនល្អ និងការខាតបង់នានាដែលអាចកើតមានឡើង ប្រសិនបើរឿងក្ដីនេះ នៅតែបន្តដោះស្រាយតាមនីតិវិធីរបស់តុលាការ។ មេធាវី គប្បីសិក្សាទៅលើសំណុំរឿងឱ្យបានច្បាស់លាស់ និងប្រឹងប្រែងស្វែងរកភស្តុតាង និងសាក្សីសម្រាប់ធ្វើការបំភ្លឺនូវចំណុចវិវាទដែលអាចជាផលប្រយោជន៍ដល់កូនក្ដីរបស់ខ្លួន។ ម្យ៉ាងវិញទៀត មេធាវីអាចធ្វើការណាត់ជួបភាគីម្ខាងទៀត ឬរៀបចំការការជួបគ្នារវាងភាគីទាំងពីរ ដើម្បីជជែកពិភាក្សារកដំណោះស្រាយសមស្របណាមួយ ដែលគូភាគីអាចទទួលយកបាន។ ក្នុងករណីដែលការផ្សះផ្សារបស់មេធាវីមិនទទួលបានលទ្ធផលវិជ្ជមានទេ ការផ្សះផ្សានឹងធ្លាក់ទៅលើតុលាការវិញ ទៅតាមគោលការណ៍ចំពោះមុខនៃបណ្ដឹងក្នុងរឿងរដ្ឋប្បវេណី។

ដោយឡែក មេធាវីអាចចូលរួមធ្វើនីតិវិធីផ្សះផ្សាបាន ដោយអនុវត្តទៅតាមទំហំនៃការចង់បានរបស់កូនក្ដី លើកលែងតែក្នុងរឿងក្ដីលែងលះ ដែលច្បាប់មិនបានអនុញ្ញាត។[41] នៅក្នុងរឿងលែងលះ មេធាវីមិនអាចធ្វើការតំណាងបានទេ ដោយសារ គឺជាមនោសញ្ចេតនាផ្ទាល់រវាងប្ដីប្រពន្ធ ការសម្រេចអំពីជោគវាសនា និងអនាគតរបស់កូន។ យ៉ាងណាមិញ មេធាវីអាចចូលរួមស្ដាប់នៅក្នុងដំណាក់កាលផ្សះផ្សាបាន។ មេធាវីអាចការពារកូនក្ដី

[40] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១០១។

[41] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៩៧ មាត្រា១០៤ និងមាត្រា២២០។

ទាក់ទងនឹងការគ្រប់គ្រងថែរក្សាចាត់ចែង និងបែងចែកទ្រព្យសម្បត្តិ ព្រមទាំងសិទ្ធិគ្រប់គ្រងលើកូន និងកាតព្វកិច្ចបង់អាហារកិច្ច ប្រសិនបើមាន។

**២.២.២.២ ការផ្សះផ្សាធ្វើឡើងដោយតុលាការ**

ការផ្សះផ្សាដោយតុលាការ មិនត្រឹមតែធ្វើឡើងនៅក្នុងដំណាក់កាល នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលប៉ុណ្ណោះទេ គឺតុលាការអាចធ្វើការផ្សះផ្សានៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធី។ តុលាការអាចធ្វើការផ្សះផ្សាគូភាគី ដោយមិនមានវត្តមានរបស់មេធាវី។ ជាគោលការណ៍ ការផ្សះផ្សាត្រូវធ្វើឡើងដោយមានវត្តមានរបស់គូភាគីទាំងសងខាង ហើយត្រូវមានឆន្ទៈព្រមព្រៀងរបស់គូភាគី។ ការផ្សះផ្សាដែលឈានទៅរកការព្រមព្រៀងគ្នា ភាគច្រើនជាការផ្សះផ្សា ដែលគូភាគីមានវត្តមាននៅទីនោះ។ មេធាវី គ្រាន់តែចូលរួមផ្តល់យោបល់បន្ថែមទៅលើការផ្សះផ្សា និងការពារផលប្រយោជន៍របស់កូនក្តី។

ក្នុងករណីដែលតុលាការ មិនបានកោះហៅគូភាគីមកផ្សះផ្សាទេ មេធាវីអាចស្នើសុំឱ្យតុលាការចាត់ការតាមនីតិវិធីភ្លាម។ ដោយហេតុថា ការពន្យាពេលជាហេតុធ្វើឱ្យមានការខាតបង់ផលប្រយោជន៍ដល់កូនក្តី ទាំងពេលវេលា និងប្រាក់កាស។ ប្រសិនបើការផ្សះផ្សាបានសម្រេច តុលាការធ្វើការកត់ត្រាទុកនៅក្នុងកំណត់ហេតុ និងចេញកំណត់ហេតុសះជា ដែលកំណត់ហេតុនេះ មានអានុភាពដូចគ្នាទៅនឹងសាលក្រមស្ថាពរដែរ។ ផ្ទុយទៅវិញ បើការផ្សះផ្សាមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ តុលាការនឹងបង្គាប់ឱ្យ ភាគីឬមេធាវីទាំងសងខាងជូនសំអាងហេតុផ្សេងៗដាក់ជូនទៅកាន់តុលាការ ដើម្បីចាត់ការទៅតាមនីតិវិធីបន្តទៀត។ ការផ្សះផ្សាអាចធ្វើបានផងដែរ នៅក្នុងដំណាក់កាលសវនាការជំនុំជម្រះ។ មេធាវីក៏អាចមានសិទ្ធិស្នើសុំចៅក្រមធ្វើការផ្សះផ្សាជាមុន។

**២.២.៣ ការអះអាងរបស់គូភាគី**

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការឱ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍ ដោយផ្ទាល់មាត់អំពីសាលក្រមដែលទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនៅក្នុងបណ្តឹងរដ្ឋប្បវេណី។ បន្ទាប់មក ចុងចម្លើយតម្រូវឲ្យធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់តបចំពោះខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ។ នេះគឺជាដំណាក់កាលដែលតុលាការពិនិត្យទៅលើចំណុចវិវាទរបស់គូភាគី ដែលមាននៅក្នុងមធ្យោបាយតទល់របស់ដើមចោទ និងមធ្យោបាយការពារខ្លួនរបស់ចុងចម្លើយ។ ដូច្នេះ មេធាវីមានតួនាទីប្រមូលភស្តុតាងសំខាន់ៗ យកព័ត៌មានពីសាក្សី សិក្សាអំពីកម្មវត្ថុ និងបកស្រាយភស្តុតាងទាំងនោះ ឱ្យបានគ្រប់ជ្រុងជ្រោយដើម្បីយកទៅប្រើនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់។[42] ម្យ៉ាងវិញទៀត មេធាវីគួរគប្បីធ្វើការកត់សម្គាល់ថា ភស្តុតាងដែលមាន ឬដែលបានប្រមូលមានលក្ខណៈគ្រប់គ្រាន់ ដើម្បីធ្វើការបកស្រាយបំភ្លឺឱ្យបានត្រឹមត្រូវស្របទៅតាមច្បាប់។

[42] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១០៣។

### ២.២.៤ ការបំភ្លឺនូវចំណុចវិវាទ

ចំណុចវិវាទ គឺជាចំណុចទាំងឡាយណា ដែលភាគីទាំងសងខាងប្រកែកគ្នាអំពីអង្គហេតុ។ នៅពេលការអះអាងរបស់គូភាគីមានភាពមិនច្បាស់លាស់ ឬការបញ្ជាក់ភស្តុតាងមិនគ្រប់គ្រាន់ តុលាការអាចសាកសួរភាគី ឬបង្គាប់ឱ្យមេធាវីដែលតំណាងឱ្យភាគី ធ្វើការបំភ្លឺអះអាង និងបញ្ជាក់ភស្តុតាងបាន។ ការប្រើប្រាស់សិទ្ធិបំភ្លឺនេះ គឺដើម្បីឱ្យចំណុចនៃអង្គហេតុដែលទាក់ទងនឹងបណ្តឹង មានភាពច្បាស់លាស់។ ការបំភ្លឺនូវចំណុចវិវាទ មានភាពសំខាន់ ដែលអនុញ្ញាតឱ្យតុលាការអាចដឹងបានថា ភាគីទទួលស្គាល់ ឬមិនទទួលស្គាល់អំពីអង្គហេតុដែលបានលើកឡើង។[43] អាស្រ័យហេតុនេះ មេធាវីគួររៀបចំការបំភ្លឺឱ្យបានច្បាស់លាស់ ដើម្បីការពារផលប្រយោជន៍របស់កូនក្តី ដាក់ជូនទៅតុលាការពិនិត្យក្នុងអំឡុងពេលដែលបានកំណត់។ ប្រសិនបើការឆ្លើយតប មានការយឺតយ៉ាវ អាចនឹងធ្វើឱ្យកូនក្តីខូចខាតផលប្រយោជន៍បាន។ បន្ទាប់ពីកំណត់ចំណុចវិវាទរួចហើយ តុលាការបញ្ជាក់ជាមួយភាគីអំពីភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទ ដែលត្រូវពិនិត្យក្នុងដំណាក់កាលបន្ទាប់។

### ២.២.៥ ការពិនិត្យភស្តុតាងជាឯកសារ

ភស្តុតាង ដែលអាចទទួលយកមកពិនិត្យបាននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺមានតែភស្តុតាងជាឯកសារក្នុងកម្រិតចាំបាច់ ដើម្បីរៀបចំនូវចំណុចវិវាទតែប៉ុណ្ណោះ។[44] ចំពោះភស្តុតាងជាសាក្សី ភាគី ឬមេធាវីអាចស្នើសុំដាក់ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ប៉ុន្តែច្បាប់មិនអនុញ្ញាតឱ្យមានការសាកសួរសាក្សីនៅក្នុងដំណាក់កាលនេះឡើយ។ នៅក្នុងរឿងក្តីរដ្ឋប្បវេណី មេធាវីតំណាងដោយអាណត្តិឱ្យកូនក្តីមានភារកិច្ចប្រមូលភស្តុតាង និងរៀបចំឯកសារភស្តុតាង ដាក់ជូនតុលាការដោយខ្លួនឯង។[45] នៅក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ភាគី ឬមេធាវីអាចស្នើសុំឱ្យតុលាការពិនិត្យលើភស្តុតាងបាន។ ការស្នើសុំឱ្យពិនិត្យភស្តុតាង[46] អាចធ្វើឡើងនៅមុនពេលកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬនីតិវិធីនៃការទាញហេតុដោយផ្ទាល់មាត់។ ជាគោលការណ៍ ការពិនិត្យភស្តុតាងអាចធ្វើឡើងតាមការស្នើសុំរបស់ភាគី ឬមេធាវី ដែលការស្នើសុំនេះ អាចធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។[47] ដូច្នេះ មេធាវីគប្បីធ្វើការប្រឹងប្រែងប្រមូលនូវភស្តុតាង ដែលមានប្រយោជន៍ទាំងអស់ដែលទាក់ទងនឹងរឿងក្តី ព្រមទាំងស្នើសុំឱ្យតុលាការធ្វើការពិនិត្យភស្តុតាងចាំបាច់ទាំងនេះ។ ប្រសិនបើមេធាវីប្រមូលបានភស្តុតាង ឬសាក្សីបានហើយ ប៉ុន្តែមិនបានស្នើសុំដល់តុលាការឱ្យពិនិត្យលើភស្តុតាងទាំងនោះទេ ជាគោលការណ៍តុលាការនឹងមិនពិនិ

---

[43] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១០៣។

[44] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១៣១។

[45] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១២៣ និងមាត្រា១២៤។

[46] ឧបសម្ព័ន្ធទី៥។

[47] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១២៥។

ត្យភស្តុតាងទាំងនោះទេ។ ហេតុដូច្នេះ ប្រសិនបើមេធាវីខកខានមិនបានស្នើសុំដាក់បញ្ចូលភស្តុតាងជូនតុលាការឱ្យបានមុននីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបញ្ចប់ទេ ភស្តុតាងទាំងនេះ មិនអាចប្រើប្រាស់បានឡើយ។ ជាងនេះទៅទៀត ភាគីក៏មិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនជាថ្មីទៀតបានទេ នៅក្រោយពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល លើកលែងតែមានករណីពិសេស។[48]

## ២.៣ នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ គឺជានីតិវិធីមួយទៀតរបស់តុលាការ បន្ទាប់ពីការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ នីតិវិធីនេះ តុលាការកំណត់កាលបរិច្ឆេទ ដើម្បីធ្វើការទាញយកហេតុផលដោយផ្ទាល់មាត់ និងកោះហៅភាគីមកចូលរួម។[49] ការទាញហេតុផលដោយផ្ទាល់មាត់ ធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីអាចចូលរួមបាន និងនៅសាលសវនាការជាសាធារណៈ។ លើកលែងតែភាពជាសាធារណៈនេះអាចបណ្តាលឱ្យប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ឬដែលមានបញ្ញត្តិច្បាប់ពិសេសចែង។ នេះគឺជាគោលការណ៍ចំពោះមុខភាគី និងគោលការណ៍សមភាពរវាងគូភាគី។ នៅដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអនុញ្ញាតឱ្យគូភាគីបញ្ចេញមតិ ឆ្លើយតបទៅនឹងមតិដែលថ្លែងដោយភាគីម្ខាងទៀត មុនពេលតុលាការសម្រេចសេចក្តី។[50]

### ២.៣.១ ការសាកល្បងធ្វើការផ្សះផ្សា

នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចធ្វើការសាកល្បងផ្សះផ្សាភាគីសាជាថ្មីម្តងទៀត។ ទោះបីជាការផ្សះផ្សា មិនបានសះជានឹងគ្នា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក៏ដោយ។[51]

### ២.៣.២ ការធ្វើសេចក្តីថ្លែងការណ៍

នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ភាគី ឬមេធាវីតំណាងតម្រូវឱ្យធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិត្រៀមសម្រាប់ការទាញហេតុផល។ ខ្លឹមសារនៃសេចក្តីថ្លែងការណ៍មានដូចជា ការអះអាងអំពីអង្គហេតុដែលឆ្លើយតបទៅនឹងការស្នើសុំឱ្យពិនិត្យភស្តុតាង និងលទ្ធផលនៃការពិនិត្យភស្តុតាងជាឯកសារ។ ក្នុងពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ភាគី ឬមេធាវីអាចធ្វើការអះអាងអង្គហេតុ និងដាក់ភស្តុតាងថ្មីបន្ថែមទៀតបាន កុំឱ្យតែអង្គហេតុ ឬភស្តុតាងទាំងនោះ មានលក្ខណៈផ្ទុយច្បាប់។[52] នៅក្នុងរឿងក្តីរដ្ឋប្បវេណី ការរៀបចំសរសេរសេចក្តីថ្លែងការណ៍ គឺជាភារកិច្ចរបស់មេធាវីតំណាងដោយអាណត្តិ ពីព្រោះនេះជាសេចក្តី

[48] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១០៨។
[49] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១១៣។
[50] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៣ និងមាត្រា១១៥។
[51] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៩៧ និងមាត្រា២២០។
[52] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១០៨។

អះអាងចាំបាច់ ដែលអាចធ្វើឱ្យតុលាការពិចារណាទាំងអង្គហេតុ និងអង្គច្បាប់បាន។[53] ម្យ៉ាងវិញទៀត នីតិវិធីនេះធ្វើឡើងដើម្បីយកសកម្មភាពដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មកដាក់ជជែកពិភាក្សាដេញដោល ក្នុងគោលបំណងយកមកធ្វើជាមូលដ្ឋានក្នុងការចេញសាលក្រម។

### ២.៣.៣ ការអះអាងបន្ថែម

នៅពេលធ្វើការទាញយកហេតុផលដោយផ្ទាល់មាត់ មេធាវីអាចអះអាងអំពីអង្គហេតុ ឬដាក់ភស្តុតាងបន្ថែមទៀតបាន។[54] ផ្ទុយទៅវិញ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការអះអាងអង្គហេតុនោះ ផ្ទុយទៅនឹងច្បាប់។ ចំណុចទាំងនោះមានដូចជា ជាមធ្យោបាយដែលទាក់ទងនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និងមិនធ្វើឱ្យមានការយឺតយ៉ាវដល់នីតិវិធិបណ្តឹង។ ។ ម្យ៉ាងវិញទៀត ករណីដែលមេធាវីធ្វើសេចក្តីបញ្ជាក់ដំបូងថា ខ្លួនមិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនមុនពេលបញ្ចប់នីតិត្រៀមសម្រាប់ការទាញហេតុផលដោយគ្មានកំហុសធ្ងន់ធ្ងរឡើយ។

មេធាវីអាចស្នើសុំឱ្យតុលាការចេញដីកាសម្រេច ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលសាជាថ្មីម្តងទៀតបាន បើសិនជាតុលាការយល់ឃើញថា ត្រូវការជាចាំបាច់។ នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការនឹងធ្វើការពិនិត្យភស្តុតាងដោយសមូហវិធី ដោយសាកសួរទៅលើសាក្សី ប្រសិនបើមានការស្នើសុំ។[55] មុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអនុញ្ញាតឱ្យមេធាវីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ចុងក្រោយ។

## ២.៤ ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

នៅគ្រប់ដំណាក់កាលនីមួយៗ នៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការបង្គាប់ឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុ ដែលកំណត់ហេតុនេះ នឹងត្រូវយកមកធ្វើជាលិខិតសាលក្រម។[56] ប្រសិនបើ ការវិនិច្ឆ័យអាចធ្វើទៅបាន ដោយផ្អែកលើការពិនិត្យភស្តុតាង និងលទ្ធផលនៃការទាញយកហេតុផលដោយផ្ទាល់មាត់ តុលាការនឹងបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ហើយចេញសាលក្រមតែម្តង។ សាលក្រម គឺជាសេចក្តីសម្រេចរបស់តុលាការ ដែលមានអានុភាពចងភាគីទាំងសងខាង និងតតិយជន ដែលមានការពាក់ព័ន្ធឱ្យអនុវត្តតាម។ យ៉ាងណាមិញ ប្រសិនបើភាគីណាមួយមិនព្រមអនុវត្តតាមសាលក្រម មេធាវីអាចស្នើសុំទៅតុលាការ ឬអាជ្ញាសាលាឱ្យអនុវត្ត។

---

[53] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១១៦។

[54] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១១៦។

[55] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១៤៣។

[56] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១១៧ មាត្រា១១៨ និងមាត្រា១១៩។

### ២.៤.១ ដំណាក់កាលក្រោយនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

បន្ទាប់ពីបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ មេធាវីគប្បីពន្យល់អំពីអនុភាពនៃសាលក្រម ដែលនាំឱ្យគូភាគីកើតមាននូវសិទ្ធិ និងកាតព្វកិច្ចដល់កូនក្តី។ ជាងនេះទៅទៀត មេធាវីមានតួនាទី៣យ៉ាង ចំពោះកូនក្តីគឺៈ ការផ្តល់យោបល់ឱ្យកូនក្តី ការពន្យល់ពីសិទ្ធិធ្វើបណ្តឹងឧបាស្រ័យ និងការចូលរួមអនុវត្តសាលក្រម។

#### ២.៤.១.១ ការផ្តល់យោបល់ឱ្យកូនក្តី

មេធាវី គប្បីផ្តល់យោបល់ឱ្យកូនក្តីរបស់ខ្លួន បន្ទាប់ពីតុលាការចេញសាលក្រម ឬសាលដីកា។ ការផ្តល់យោបល់មានសារៈសំខាន់សម្រាប់កូនក្តី ទោះបីជាលទ្ធផលចាញ់ ឬឈ្នះក៏ដោយ។ ដោយហេតុថា ជួនកាលកូនក្តីមិនមែនជាអ្នកមានការយល់ដឹងអំពីច្បាប់នោះទេ។ ដូច្នេះ មេធាវីគួរគប្បីប៉ាន់ប្រមាណឱ្យបានល្អិតល្អន់ថាតើ កូនក្តីរបស់ខ្លួនអាចយល់ដឹងពីអត្ថន័យនៃសាលក្រមបានកម្រិតណា។ ប្រសិនបើ ក្នុងករណីកូនក្តីអាចយល់ដឹងពីអត្ថន័យនៃសាលក្រមក៏ដោយ មេធាវីនៅតែមានកាតព្វកិច្ចបញ្ជាក់ឱ្យច្បាស់ដដែល។ ការធ្វើបែបនេះ គឺជាកាតព្វកិច្ចដែលមេធាវីគួរធ្វើពុំអាចខកខានបានឡើយ។ ម្យ៉ាងវិញទៀត នេះក៏ជាករណីចាំបាច់មួយសម្រាប់មេធាវីដើម្បីជៀសវាងនូវការបាត់បង់ផលប្រយោជន៍ ដោយថាហេតុរបស់កូនក្តី ដែលមិនអាចធ្វើបណ្តឹងឧបាស្រ័យនៅតុលាការជាន់ខ្ពស់។

#### ២.៤.១.២ ការពន្យល់ពីសិទ្ធិធ្វើបណ្តឹងឧបាស្រ័យ

បណ្តឹងឧបាស្រ័យ គឺជានីតិវិធីមួយដែលច្បាប់អនុញ្ញាតឱ្យភាគី ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចនៅក្នុងការជំនុំជម្រះក្តីលើកទី១ មានសិទ្ធិប្តឹងទៅនឹងសេចក្តីសម្រេចនោះ។ មេធាវីតំណាងដោយអាណត្តិឱ្យកូនក្តីតម្រូវឱ្យចងចាំអំពីរយៈពេលដែលច្បាប់បានកំណត់ ក្នុងការធ្វើបណ្តឹងឧបាស្រ័យទៅកាន់តុលាការជាន់ខ្ពស់។ ម្យ៉ាងវិញទៀត មេធាវីគប្បីពន្យល់អំពីសាលក្រម ឬសាលដីកា ដែលបានសម្រេចដោយតុលាការ។ ទោះបីជាកូនក្តីរបស់ខ្លួនជាអ្នកឈ្នះក្តី ឬជាអ្នកចាញ់ក្តីក៏ដោយ ពីព្រោះពេលខ្លះមិនមែនសុទ្ធតែអ្នកដែលឈ្នះក្តីសុខចិត្តនឹងសេចក្តីសម្រេចនោះទេ។ ហេតុនេះហើយ ច្បាប់បើកសិទ្ធិឱ្យអ្នកដែលមិនសុខចិត្តមានសិទ្ធិប្តឹងឧបាស្រ័យទៅនឹងសាលក្រម ឬសាលដីកាដែលខ្លួនមិនពេញចិត្តនោះ។

មេធាវី មានតួនាទីការពារក្តីជូនកូនក្តីដូចជា ការធានាពីភាពអាចទទួលយកបាននៃបណ្តឹងឧបាស្រ័យ ការរៀបចំ និងការដាក់ឯកសារត្រៀម ដែលតុលាការបង្គាប់ឱ្យចូលរួមនៅក្នុងសវនាការ។ ប្រសិនបើ ពាក្យបណ្តឹងឧបាស្រ័យមិនបានធ្វើឡើងដោយបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់នោះទេ អាចនឹងត្រូវបានតុលាការសម្រេចលើកចោលដោយសាលដីកា ឬដីកាសម្រេចបាន ដូច្នេះផលប្រយោជន៍របស់ភាគីក៏នឹងត្រូវបាត់បង់។[57]

#### ២.៤.១.៣ ការចូលរួមអនុវត្តសាលក្រម

[57] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦៦ មាត្រា២៦៨ និងមាត្រា២៩០។

នៅពេលផុតរយៈពេលប្ដឹងតវ៉ាតាមការកំណត់របស់ច្បាប់ហើយ ភាគីឈ្នះក្ដីតម្រូវឱ្យដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរស្នើសុំអនុវត្តដោយបង្ខំ។ ការអនុវត្តដោយបង្ខំ ធ្វើឡើងដោយស្ថាប័នអនុវត្តដែលរួមមានតុលាការអនុវត្ត ឬអាជ្ញាសាលា។ នៅពេលដែលសាលក្រមចូលជាស្ថាពរ មេធាវីអាចសុំលិខិតសាលក្រមចូលជាស្ថាពរនោះដើម្បីយកទៅអនុវត្ត។

នីតិវិធីមុនពេលទទួលបានសាលក្រម គឺតម្រូវឱ្យបង់ពន្ធសមាមាត្រ ជូនដល់ក្រឡាបញ្ជីមុននឹងទទួលបានសាលក្រម ប្រសិនបើរឿងក្ដីនោះត្រូវបានតុលាការសម្រេចឱ្យបង់ពន្ធ។ ហេតុនេះ មេធាវីគួរពន្យល់ដល់កូនក្ដីអំពីការបង់ពន្ធសមាមាត្រនេះ។ ជានិច្ចជាកាល អ្នកឈ្នះក្ដីត្រូវតែជាអ្នកបង់មុន បន្ទាប់មកទើបបង្គាប់ឱ្យអ្នកចាញ់ក្ដីសងប្រាក់នេះទៅអ្នកដែលឈ្នះក្ដីវិញ។ នៅពេលពាក្យសុំអនុវត្តសាលក្រម[58]ត្រូវបានដាក់ ប្រធានតុលាការពិនិត្យមើលទៅលើពាក្យសុំនោះ បើឃើញថាមានភ្ជាប់សម្រង់សាលក្រម និងបង្កាន់ដៃបង់ពន្ធសមាមាត្រ មកជាមួយត្រឹមត្រូវហើយ ប្រធានតុលាការនឹងចាត់ឱ្យអនុវត្តតាមនីតិវិធី ដោយចាត់បញ្ជូនពាក្យនោះទៅព្រះរាជអាជ្ញាដើម្បីអនុវត្ត។ តួនាទីរបស់ព្រះរាជអាជ្ញាពេលនេះ គឺជាអ្នកដឹកនាំការអនុវត្តសាលក្រម តាមការស្នើសុំរបស់ភាគី ឬមេធាវីតំណាងដោយអាណត្តិ។

[58] ឧបសម្ព័ន្ធទី៦។

# ជំពូកទី៣

# តួនាទីមេធាវីក្នុងការអនុវត្តរឿងក្តីរដ្ឋប្បវេណី នៅសាលាជម្រះក្តីជាន់ខ្ពស់

## ៣.១ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាវិធីធ្វើឧបាស្រ័យទាមទារដោយភាគីទៅតុលាការជាន់ខ្ពស់ ដើម្បីឱ្យលុបចោល ឬផ្លាស់ប្តូរនូវសេចក្តីសម្រេច។ សេចក្តីសម្រេចមានប្រភេទដូចជា សាលក្រម សាលដីកា ឬ ដីកាសម្រេច ចេញដោយតុលាការថ្នាក់ក្រោម នៅមុនពេលដែលសេចក្តីសម្រេចចូលជាស្ថាពរ។[59] បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់អាចធ្វើទៅបាន តែមុនពេលដែលសេចក្តីសម្រេចនោះចូលជាស្ថាពរតែប៉ុណ្ណោះ។ នៅពេលដែលមានបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ សេចក្តីសម្រេចដើមមិនត្រូវបានចូលជាស្ថាពរហូតដល់ដំណើរការឧបាស្រ័យទៅតុលាការជាន់ខ្ពស់បានបញ្ចប់។[60] ផ្ទុយទៅវិញ ការចូលស្ថាពរនៃសេចក្តីសម្រេចទាំងមូល គឺជាស្ថានភាពមួយដែលសេចក្តីសម្រេចនោះ មិនអាចធ្វើឧបាស្រ័យទៅតុលាការជាន់ខ្ពស់បានទេ។

ដោយឡែក បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី[61] គឺជាបណ្តឹងឧបាស្រ័យ ចំពោះសាលក្រមដែលបានចូលជាស្ថាពរហើយ ហេតុដូច្នេះមិនមែនជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ទេ។[62] បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាប្រព័ន្ធមួយដែលតុលាការជាន់ខ្ពស់កែតម្រូវនូវសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម ដោយរង់ចាំពាក្យសុំឧបាស្រ័យ។ បណ្តឹងនេះ គឺជាយន្តការមួយសម្រាប់ធ្វើការសង្គ្រោះសិទ្ធិរបស់ភាគីឱ្យរួចផុតពីការវិនិច្ឆ័យខុស ឬកំហុសក្នុងនីតិវិធីនៃការជំនុំជម្រះលើកទី១។ ម្យ៉ាងវិញទៀត តាមរយៈការអនុញ្ញាតឱ្យធ្វើបណ្តឹងឧបាស្រ័យ មានរឿងក្តីជាច្រើនដែលត្រូវបានពិនិត្យ និងធ្វើការជំនុំជម្រះសារឡើងវិញ។ ចុងក្រោយ គឺត្រូវជម្រះដោយតុលាការជាន់ខ្ពស់ដែលមានតែមួយចុងក្រោយគេ គឺតុលាការកំពូល។ អាស្រ័យហេតុនេះ ភាគីដែលបានបាត់បង់ផលប្រយោជន៍ដោយសារសាលក្រមរបស់សាលាដំបូង ឬមេធាវីតំណាងដោយអាណត្តិឱ្យកូនក្តី អាចមានសិទ្ធិប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាននៅក្នុងអំឡុងពេលសម្រាប់ប្តឹងឧបាស្រ័យ ដែលច្បាប់បានកំណត់។

### ៣.១.១ ប្រភេទនៃបណ្តឹងឧបាស្រ័យ

[59] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៥៨ ។

[60] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១៩៣ (២ក)។

[61] ឧបសម្ព័ន្ធទី៧។

[62] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៣០៧ និងមាត្រា៣១៧។

បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់មានបីប្រភេទគឺៈ បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់។[63] បណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះសាលក្រម ឬសាលដីកា។[64] ចំណែកបណ្តឹងជំទាស់ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះដីកាសម្រេច។[65] បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មានប្រភេទផ្សេងៗ ដោយបែងចែកទៅតាមប្រភេទនៃសេចក្តីសម្រេចដើម។ ហេតុដូច្នេះ មេធាវីដែលជាអ្នកតំណាងដោយអាណត្តិឱ្យកូនក្តី គប្បីពន្យល់ណែនាំដល់កូនក្តី និងជ្រើសរើសប្រភេទនៃបណ្តឹងឧបាស្រ័យឱ្យបានត្រឹមត្រូវ ដោយស្របតាមប្រភេទនៃសេចក្តីសម្រេចដើម។ ម្យ៉ាងវិញទៀត នៅក្នុងនីតិវិធីនៃការប្តឹងទៅតុលាការជាន់ខ្ពស់ មេធាវីមានតួនាទីពន្យល់កូនក្តីពីសិទ្ធិដែលកូនក្តីមាននៅក្នុងការធ្វើបណ្តឹងឧបាស្រ័យ។ មិនត្រឹមតែប៉ុណ្ណោះ មេធាវីតម្រូវឱ្យដាក់បញ្ចូលនូវភស្តុតាងបន្ថែម និងឯកសារត្រៀមទាំងឡាយដែលជាប្រយោជន៍ដល់កូនក្តីនៅក្នុងការជម្រះក្តីនៅតុលាការថ្នាក់ខ្ពស់។

## ៣.២ បណ្តឹងឧទ្ធរណ៍

### ៣.២.១ សេចក្តីសម្រេចដែលអាចប្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ របស់សាលាដំបូង។ ចំពោះសាលក្រមរបៀប មិនអាចប្តឹងឧទ្ធរណ៍បានឡើយ។[66] បណ្តឹងឧទ្ធរណ៍មិនត្រូវបានអនុញ្ញាតឱ្យធ្វើ ប្រសិនបើក្រោយពេលចេញសាលក្រមចុងក្រោយនោះ ភាគីទាំងសងខាងបានព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរថា មិនធ្វើការប្តឹងឧទ្ធរណ៍ទេ។ ម្យ៉ាងវិញទៀត មិនអាចប្តឹងឧទ្ធរណ៍បានទេ ប្រសិនបើសាលក្រមនៃរឿងក្តីរដ្ឋប្បវេណីនោះ មានតម្លៃកម្មវត្ថុនៃបណ្តឹងមិនលើសពី៥លានរៀល។[67] នៅក្នុងករណីដែលតុលាការនៃការជំនុំជម្រះលើកទី១ ចេញសាលក្រមកំបាំងមុខ ទោះបីជាល័ក្ខខ័ណ្ឌបែបណាក៏ដោយ[68] ភាគីអាចលះបង់ផលប្រយោជន៍ក្នុងការបន្តឱ្យវិនិច្ឆ័យនៅថ្នាក់ដដែលដោយដាក់បណ្តឹងជំទាស់ចំពោះសាលក្រមកំបាំងមុខនោះ ហើយអាចប្តឹងឧទ្ធរណ៍បាន។

អាស្រ័យហេតុនេះ មេធាវីមានភារកិច្ចចាំបាច់ក្នុងការស្វែងយល់ឱ្យបានច្បាស់ពីប្រភេទនៃសេចក្តីសម្រេចផ្សេងៗនៃការជំនុំជម្រះលើកទី១ឱ្យបានច្បាស់លាស់ ថាតើសេចក្តីសម្រេចបែបណាដែលអាចប្តឹងឧទ្ធរណ៍បាន ឬមិនបាន ដើម្បីកុំឱ្យមានការភ័ន្តច្រឡំដែលជាហេតុនាំឱ្យមានផលវិបាកដល់កូនក្តី។

---

[63] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៥៩(១ក)។

[64] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៥៩(១ក-ខ)។

[65] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៥៩(១ក-ខ)។

[66] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១៨១។

[67] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦០(១ក)។

[68] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២០៤(១ក)។

### ៣.២.២ អ្នកមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍

ភាគីដែលបាត់បង់ផលប្រយោជន៍ គឺជាភាគីដែលចាញ់ក្តីទាំងស្រុង ឬមួយផ្នែក។ ភាគីនោះ មានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍។ ឯភាគីឈ្នះក្តីគ្មានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ទេ។ ក្នុងករណីដែលភាគីឈ្នះក្តីទាំងស្រុងធ្វើបណ្តឹងឧទ្ធរណ៍ នោះបណ្តឹងឧទ្ធរណ៍នឹងត្រូវបានតុលាការលើកចោលដោយមូលហេតុផ្ទុយនឹងច្បាប់។ ដូច្នេះ ជាគោលការណ៍ ភាគីដែលឈ្នះក្តីទាំងស្រុងនៅក្នុងការជំនុំជម្រះលើកទី១ គ្មានសិទ្ធិ ឬផលប្រយោជន៍ក្នុងការប្តឹងឧទ្ធរណ៍នោះឡើយ។

សិទ្ធិប្តឹងឧទ្ធរណ៍ មិនអាចកើតឡើងបានក្នុងករណីដែលមានការព្រមព្រៀងជាមុនរវាងភាគីទាំងសងខាងថា មិនប្តឹងឧទ្ធរណ៍ទេ។ ប្រសិនបើ ការព្រមព្រៀងមិនប្តឹងឧទ្ធរណ៍ត្រូវបានបង្កើតឡើងដោយមានសុពលភាព នោះសាលក្រមនៃការជំនុំជម្រះលើកទី១ ត្រូវចូលជាស្ថាពរ នៅពេលដែលប្រកាសសាលក្រម។ ម្យ៉ាងវិញទៀត សិទ្ធិប្តឹងឧទ្ធរណ៍នឹងកើតឡើងចំពោះបុគ្គលដែលរៀបរាប់ខាងលើ ដោយសារការប្រកាសសាលក្រមនៃការជំនុំជម្រះក្តីលើកទី១។ ផ្ទុយទៅវិញ ក្រោយពេលសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍បានកើតឡើង ភាគីដែលមានសិទ្ធិប្តឹងឧទ្ធរណ៍ អាចលះបង់នូវសិទ្ធិនេះបានផងដែរ។[69] ហេតុនេះ បើភាគីមានបំណងលះបង់សិទ្ធិប្តឹងឧទ្ធរណ៍ មេធាវីតំណាងដោយអាណត្តិតម្រូវឱ្យធ្វើសេចក្តីថ្លែងការណ៍។ ក្រោយពេលដាក់ពាក្យបណ្តឹងឧទ្ធរណ៍ សេចក្តីថ្លែងការណ៍អំពីការលះបង់សិទ្ធិប្តឹងឧទ្ធរណ៍នោះ ត្រូវធ្វើឡើងជាមួយគ្នានឹងការដកពាក្យបណ្តឹងឧទ្ធរណ៍ដែរ។[70] អាស្រ័យហេតុនេះ មេធាវី គប្បីពន្យល់កូនក្តីពីសិទ្ធិស្របច្បាប់របស់ខ្លួនដែលអាចប្តឹងឧទ្ធរណ៍បាន។ ដោយហេតុថា នៅពេលដែលភាគីបាត់បង់ផលប្រយោជន៍ដោយសារតែសាលក្រមនៃការជំនុំជម្រះលើកទី១ អាចមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍។

### ៣.២.៣ អំឡុងពេលធ្វើបណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ ធ្វើឡើងក្នុងអំឡុងពេល១ខែ ដោយគិតចាប់ពីថ្ងៃទទួលបានលិខិតសាលក្រម នៃការជំនុំជម្រះលើកទី១ ឬពីថ្ងៃដែលដីកាសម្រេចច្រានចោល[71] ឬលើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខត្រូវបានជូនដំណឹង។[72] ប្រសិនបើ ភាគីធ្វើការប្តឹងឧទ្ធរណ៍ដោយហួសរយៈពេល១ខែបន្ទាប់ពីទទួលបានលិខិតសាលក្រម នោះតុលាការនឹងលើកចោល ឬច្រានចោលពាក្យបណ្តឹងនោះ។ ម្យ៉ាងទៀត អំឡុងពេល១ខែនេះ មិនអាចពន្យាពេលបានឡើយ។[73] យ៉ាងណាមិញ ក្នុងករណីដែលភាគីមិនអាចប្តឹងឧទ្ធរណ៍បានក្នុងអំឡុងពេលនោះ

---

[69] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦៣(១ក)។

[70] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦៣(២ក)។

[71] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២០៧(២ក)។

[72] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦៤ (១ក)។

[73] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦៤(២ក)។

ដោយមូលហេតុដែលមិនមែនជាកំហុសរបស់ខ្លួន ភាគីអាចបំពេញសកម្មភាពបណ្តឹងពេលក្រោយបាន ក្នុងអំឡុងពេល១សប្តាហ៍ ក្រោយពីមូលហេតុនោះបានរលត់ហើយ។[74] ដើម្បីធ្វើបណ្តឹងឧទ្ធរណ៍ក្នុងករណីនេះបាន មេធាវីគ្រាន់តែដាក់ពាក្យបណ្តឹងឧទ្ធរណ៍ជាធម្មតា ក្នុងអំឡុងពេល១សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលហេតុនាំឱ្យខកខាននោះបានរលត់។ បន្ទាប់មក មេធាវីតម្រូវឱ្យធ្វើការអះអាង និងបញ្ជាក់ដោយមានភស្តុតាងថា ការមិនអាចធ្វើបណ្តឹងឧទ្ធរណ៍ក្នុងអំឡុងពេលកំណត់នោះបាន មិនមែនដោយសារកំហុសរបស់ខ្លួនទេ ជាការគ្រប់គ្រាន់។

ក្នុងករណីអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍កន្លងហួស ភាគីដែលមានសិទ្ធិប្តឹងឧទ្ធរណ៍ អាចនឹងបាត់បង់សិទ្ធិនោះ។ ហេតុដូច្នេះ ប្រសិនបើពាក្យបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ ក្រោយអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍កន្លងហួស នោះបណ្តឹងឧទ្ធរណ៍ ត្រូវបានលើកចោលដោយសាលដីកា ដោយសារមានលក្ខណៈផ្ទុយពីច្បាប់។[75] ដោយឡែក ក្រោយពេលសាលក្រមនៃការជំនុំជម្រះលើកទី១ ត្រូវបានប្រកាស ទោះបីជាមិនទាន់ទទួលបានការបញ្ជូនសាលក្រមក៏ដោយ ក៏ភាគីអាចប្តឹងឧទ្ធរណ៍ដោយស្របច្បាប់បានដែរ។ ក្នុងករណីនេះ មេធាវីគប្បីរៀបចំឯកសារ ឬលិខិតគតិយុត្តផ្សេងៗសម្រាប់ធ្វើបណ្តឹងឧទ្ធរណ៍ឱ្យបានទាន់ពេលវេលាកំណត់ ជៀសវាងហួសពេលវេលាដែលជាហេតុនាំឱ្យមានការខាតបង់ផលប្រយោជន៍ដល់កូនក្តី។ ដោយហេតុថា ការពន្យាពេលណាមួយនៃបណ្តឹងជាមូលហេតុនៃការបាត់បង់ផលប្រយោជន៍របស់ភាគី។

### ៣.២.៤ របៀបធ្វើបណ្តឹងឧទ្ធរណ៍

នៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍ ក្រៅពីឈ្មោះ និងអាសយដ្ឋានរបស់ភាគី និងអ្នកតំណាងដោយអាណត្តិ ចាំបាច់ត្រូវសរសេរនូវសញ្ញាណសាលក្រមនៃការជំនុំជម្រះលើកទី១ និងសេចក្តីប្តឹងឧបាស្រ័យចំពោះសាលក្រមនោះ។[76] ជាការល្អនៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍ គួរតែសរសេរឱ្យបានក្បោះក្បាយអំពីមូលហេតុដែលទាមទារឱ្យតុលាការលុបចោល ឬផ្លាស់ប្តូរនូវសាលក្រមនៃការជំនុំជម្រះលើកទី១។ ប្រសិនបើមិនបានសរសេរច្បាស់លាស់អំពីមូលហេតុនៃការទាមទារទេ អ្នកធ្វើបណ្តឹងគប្បីដាក់លិខិតជាលាយលក្ខណ៍អក្សរដែលសរសេរអំពីមូលហេតុនោះ ក្នុងអំឡុងពេល៣០ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍។ មេធាវី មានតួនាទីរៀបចំលិខិតគតិយុត្តផ្សេងៗជំនួសឱ្យកូនក្តី នៅក្នុងរបៀបនៃការប្តឹងឧទ្ធរណ៍ ពីព្រោះ កូនក្តីអាចជាជនដែលមិនសូវយល់ដឹងពាក់ព័ន្ធនឹងរបៀបប្តឹងឧទ្ធរណ៍បាន។

ពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវបានដាក់ទៅតុលាការដើមដែលបានធ្វើការជំនុំជម្រះលើកទី១។ នៅពេលដែលទទួលបានពាក្យបណ្តឹងឧទ្ធរណ៍នោះ តុលាការនៃការជំនុំជម្រះលើកទី១ នឹងផ្ញើពាក្យបណ្តឹងឧទ្ធរណ៍នោះ រួមទាំង

[74] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៥៤។

[75] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦៨។

[76] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦៥(២ក)។

សំណុំរឿងទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ឱ្យបានឆាប់រហ័ស។ បន្ទាប់មក តុលាការនៃបណ្ដឹងឧទ្ធរណ៍នឹងពិនិត្យពាក្យបណ្ដឹងឧទ្ធរណ៍នោះ។ ប្រសិនបើពិនិត្យទៅឃើញថា មានចំណុចខ្វះខាត តុលាការនឹងបង្គាប់ឱ្យភាគីធ្វើការកែតម្រូវ។[77] ហេតុនេះ មេធាវីគប្បីធ្វើការកែតម្រូវភ្លាមទៅតាមអ្វីដែលតុលាការបានបង្គាប់ ពីព្រោះប្រសិនបើមិនព្រមកែតម្រូវទេ ពាក្យបណ្ដឹងឧទ្ធរណ៍នឹងត្រូវលើកចោល ដោយដីកាសម្រេច។ ចំណុចនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលដើមបណ្ដឹងឧទ្ធរណ៍មិនបានបង់ពន្ធសម្រាប់ដាក់ពាក្យបណ្ដឹងឧទ្ធរណ៍។ ម្យ៉ាងវិញទៀត ប្រសិនបើពាក្យបណ្ដឹងឧទ្ធរណ៍ត្រឹមត្រូវតាមទម្រង់ច្បាប់ហើយ ក្រឡាបញ្ជើបញ្ជូនពាក្យបណ្ដឹងឧទ្ធរណ៍នោះទៅឱ្យចុងបណ្ដឹងឧទ្ធរណ៍។[78] ដូច្នេះ មេធាវីគួររៀបចំពាក្យបណ្ដឹងឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ដោយរាប់បញ្ចូលតាំងពីខ្លឹមសារនានាដែលត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង និងការបង់ប្រដាប់ក្ដីផងដែរ។

### ៣.២.៥ ការដកពាក្យបណ្ដឹងឧទ្ធរណ៍

ពាក្យបណ្ដឹង អាចដកវិញបានរហូតដល់ពេលដែលសាលដីកាចុងក្រោយរបស់តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវបានចេញ។[79] ការដកពាក្យបណ្ដឹងឧទ្ធរណ៍ តម្រូវឱ្យធ្វើជាលាយល័ក្ខណ៍អក្សរ។ ផ្ទុយទៅវិញ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ការទាញហេតុផលដោយផ្ទាល់មាត់ និងការផ្សះផ្សា ការដកពាក្យបណ្ដឹងឧទ្ធរណ៍ អាចធ្វើដោយផ្ទាល់មាត់បាន។ ការដកពាក្យបណ្ដឹងឧទ្ធរណ៍ ត្រូវចាត់ទុកថា មិនបានចាត់ការនៅតុលាការនៃបណ្ដឹងឧទ្ធរណ៍តាំងពីដំបូង។ ម្យ៉ាងវិញទៀត បើមានការដកពាក្យបណ្ដឹងឧទ្ធរណ៍ នោះសាលក្រមដើមនៃការជំនុំជម្រះលើកទី១ ត្រូវចូលជាស្ថាពរ នៅអំឡុងពេលសម្រាប់ប្ដឹងឧទ្ធរណ៍កន្លងហួស។

ការដកពាក្យបណ្ដឹងឧទ្ធរណ៍មិនមានឥទ្ធិពលអ្វីលើសាលក្រមដើមទេ ហើយក៏មិនមានការខូចប្រយោជន៍ដល់ចុងបណ្ដឹងឧទ្ធរណ៍ដែរ។ ហេតុដូច្នេះ មិនចាំបាច់មានការយល់ព្រមពីចុងបណ្ដឹងឧទ្ធរណ៍ឡើយ។ ជាងនេះទៅទៀត នីតិវិធីនៃការប្ដឹងឧទ្ធរណ៍ ចាំបាច់ត្រូវតែមានវត្តមានរបស់ភាគី ឬមេធាវីតំណាងដោយអាណត្តិ។ ដោយហេតុថា ប្រសិនបើភាគីទាំងសងខាងមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ទេ ត្រូវចាត់ទុកថា ការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ត្រូវបានដកពាក្យបណ្ដឹង ដោយអនុលោមទៅតាមករណីនៃការដកពាក្យបណ្ដឹង។[80]

## ៣.៣ បណ្ដឹងសាទុក្ខ

### ៣.៣.១ គោលការណ៍ទូទៅ

[77] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦៦(១ក)។

[78] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦៧(១ក)។

[79] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រ២៦៩(១ក)។

[80] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២១៩។

បណ្តឹងសាទុក្ខ គឺជាប្រភេទមួយនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលប្រឆាំងនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ឬសាលាដំបូង។ បណ្តឹងសាទុក្ខ អាចធ្វើបានចំពោះសាលដីកាចុងក្រោយនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍។[81] ដោយឡែក បណ្តឹងសាទុក្ខក៏អាចធ្វើបានដែរក្នុងករណីដែលមានការព្រមព្រៀងរបស់ភាគីស្តីពីការប្តឹងសាទុក្ខផ្លោះទៅតុលាការកំពូលតែម្តង។[82] ម្យ៉ាងវិញទៀត តុលាការនៃបណ្តឹងសាទុក្ខ មិនធ្វើការទទួលស្គាល់លើអង្គហេតុឡើងវិញទេ។ តុលាការគ្រាន់តែវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវក្នុងការអនុវត្តច្បាប់ ដោយផ្អែកលើការទទួលស្គាល់នូវអង្គហេតុដោយតុលាការដើមតែប៉ុណ្ណោះ។ ជាគោលការណ៍ តុលាការនៃបណ្តឹងសាទុក្ខ ត្រូវបានចងដោយអង្គហេតុដែលទទួលស្គាល់ជាស្ថាពរដោយស្របច្បាប់ ក្នុងសាលក្រម ឬសាលដីកាដើម។[83]

### ៣.៣.២ សេចក្តីសម្រេចដែលអាចប្តឹងសាទុក្ខ

សេចក្តីសម្រេចដែលអាចប្តឹងសាទុក្ខបានមានដូចជា សាលដីកាចុងក្រោយដែលត្រូវបានជំនុំជម្រះដោយសាលាឧទ្ធរណ៍។ នេះជាសាលដីកាដែលសាលាឧទ្ធរណ៍បានចេញបន្ទាប់ពីការពិនិត្យលើភស្តុតាង និងការទាញហេតុផលដោយផ្ទាល់មាត់។ ម្យ៉ាងវិញទៀត ចំពោះសាលក្រមចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី១ ដោយសាលាដំបូង នៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ និងរក្សាសិទ្ធិក្នុងការប្តឹងសាទុក្ខទៅតុលាការកំពូលតែម្តង។ លើសពីនេះទៅទៀត ចំពោះសាលដីកាចុងក្រោយដែលសាលាឧទ្ធរណ៍បានជំនុំជម្រះលើកទី១ ដូចជាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។ បន្ទាប់ពីសាលាឧទ្ធរណ៍បានជំនុំជម្រះលើកទី១ សាលដីកាចុងក្រោយនេះអាចធ្វើការប្តឹងសាទុក្ខបាន។

### ៣.៣.៣ មូលហេតុនៃការធ្វើបណ្តឹងសាទុក្ខ

មូលហេតុនៃការប្តឹងសាទុក្ខបែងចែកជាពីរ។ ទី១ គឺជាមូលហេតុទូទៅនៃបណ្តឹងសាទុក្ខ ដែលសំដៅដល់ការចេញសាលក្រម ឬសាលដីកា របស់តុលាការមានអត្ថន័យផ្ទុយពីរដ្ឋធម្មនុញ្ញ ច្បាប់ បទដ្ឋានគតិយុត្តជាដើម។ ចំណែកឯទី២ គឺជាមូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ។ ក្នុងករណីដែលចៅក្រមចេញសាលដីកា ឬសាលក្រមមិនត្រូវបានចាត់តាំងដោយស្របច្បាប់ ចៅក្រមដែលច្បាប់មិនអនុញ្ញាតឱ្យចូលរួមក្នុងការចេញសាលក្រម ឬសាលដីកាតែបានចូលរួម ភាពផ្ទុយនឹងសមត្ថកិច្ចផ្តាច់មុខ ការខ្វះសិទ្ធិតំណាងដែលកំណត់ដោយច្បាប់ ខ្វះសិទ្ធិតំណាងដោយអាណត្តិ ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់អ្នកតំណាងដើម្បីធ្វើសកម្មភាពបណ្តឹង ភាព

[81] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៨៣(១វ.១) ។

[82] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៦០ និងមាត្រា២៨៣។

[83] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៩៦។

ផ្ទុយពីការបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ សាលក្រមឬសាលដីកាគ្មានសំអាងហេតុ ឬមានសំអាងហេតុដែលមានភាពផ្ទុយគ្នានឹងសេចក្ដីសម្រេចបញ្ចប់។

តុលាការនៃបណ្ដឹងសាទុក្ខ វិនិច្ឆ័យទៅលើតែបញ្ហាដែលមានភាពផ្ទុយនឹងច្បាប់តែប៉ុណ្ណោះ។ ភាគី ឬមេធាវីមិនអាចធ្វើបណ្ដឹងសាទុក្ខដោយផ្អែកទៅលើមូលហេតុថា ខ្លួនទទួលរងនូវការខាតបង់ផលប្រយោជន៍ពីសាលដីកានោះទេ។ មេធាវីតំណាងដោយអាណត្តិឱ្យកូនក្ដី គប្បីធ្វើការអះអាងមូលហេតុនៃបណ្ដឹងសាទុក្ខថាមានភាពផ្ទុយនឹងច្បាប់ ដែលជះឥទ្ធិពលដល់សាលក្រម ឬសាលដីកា។[84] បើសិនតុលាការទទួលស្គាល់ថាមានកំហុស ដែលជះឥទ្ធិពលទៅលើការវិនិច្ឆ័យលើសាលដីកាពិតមែន ទើបបណ្ដឹងសាទុក្ខមានមូលហេតុត្រឹមត្រូវ។ ហេតុនេះមេធាវី គួរសរសេរអំពីមូលហេតុនៃការធ្វើបណ្ដឹងសាទុក្ខនៅក្នុងពាក្យបណ្ដឹងឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។ ប្រសិនបើមិនបានសរសេរនូវមូលហេតុនៃបណ្ដឹងសាទុក្ខក្នុងពាក្យបណ្ដឹងទេ មេធាវីគប្បីដាក់លិខិតបញ្ជាក់អំពីមូលហេតុ ក្នុងអំឡុងពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតទទួលពាក្យបណ្ដឹងសាទុក្ខ។

### ៣.៣.៤ របៀបធ្វើបណ្ដឹងសាទុក្ខ

ដើម្បីធ្វើបណ្ដឹងសាទុក្ខ ភាគីត្រូវដាក់ពាក្យបណ្ដឹងទៅតុលាការដើម។[85] នៅពេលទទួលបានបណ្ដឹងសាទុក្ខ តុលាការដើមនឹងផ្ញើពាក្យបណ្ដឹងសាទុក្ខ និងសំណុំរឿងទៅកាន់តុលាការនៃបណ្ដឹងសាទុក្ខ។ ជាគោលការណ៍ អំឡុងពេលសម្រាប់ធ្វើបណ្ដឹងសាទុក្ខ គឺមានរយៈពេល១ខែ ដោយគិតពីថ្ងៃដែលបានទទួលលិខិតសាលក្រម ឬសាលដីកា ដូចអំឡុងពេលសម្រាប់ប្ដឹងឧទ្ធរណ៍ដែរ។[86] ប្រសិនបើ មានចំណុចខ្វះខាតនៅក្នុងពាក្យបណ្ដឹងសាទុក្ខ ឬក្នុងលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹង នោះតុលាការនឹងបង្គាប់ឱ្យធ្វើការកែតម្រូវ។ ក្នុងករណីដែលដើមបណ្ដឹងសាទុក្ខ ឬមេធាវីមិនបានកែតម្រូវនៅក្នុងអំឡុងពេលកំណត់ទេ បណ្ដឹងសាទុក្ខនឹងត្រូវតុលាការលើកចោលដោយដីកាសម្រេច។[87]

## ៣.៤ បណ្ដឹងជំទាស់

### ៣.៤.១ និយមន័យ

[84] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៨៥។

[85] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៨៧(វា.១)។

[86] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៨៦ និងមាត្រា២៦៥។

[87] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៩១(២ក)។

បណ្ដឹងជំទាស់ គឺជាបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលធ្វើឡើងចំពោះដីកាសម្រេចដែលមិនមែនជាសាលក្រម ឬសាលដីកា។ នីតិវិធីនៃបណ្ដឹងជំទាស់ មានលក្ខណៈងាយស្រួល និងឆាប់រហ័ស បើប្រៀបធៀបជាមួយនឹងការប្ដឹងឧទ្ធរណ៍ ឬប្ដឹងសាទុក្ខ ហើយត្រូវបញ្ចប់ដោយដីកាសម្រេច។

**៣.៤.២ របៀបធ្វើបណ្ដឹងជំទាស់**

ដើម្បីធ្វើបណ្ដឹងជំទាស់ មេធាវីគប្បីដាក់ពាក្យបណ្ដឹងជំទាស់ទៅតុលាការដើម។ នៅក្នុងពាក្យបណ្ដឹងជំទាស់ មេធាវីគួរតែសរសេរអំពីមូលហេតុច្បាស់លាស់នៃការសុំលុបចោល ឬផ្លាស់ប្ដូរនូវដីកាសម្រេចដើម។ ផ្ទុយទៅវិញ ប្រសិនបើមិនសរសេរអំពីមូលហេតុ ក៏បណ្ដឹងជំទាស់មិនបែជាគ្មានសុពលភាពដែរ។ ក្នុងករណីដែលពាក្យបណ្ដឹងជំទាស់មិនមានសរសេរអំពីមូលហេតុនោះទេ មេធាវីគប្បីដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងជំទាស់ទៅតុលាការនៃបណ្ដឹងជំទាស់ ក្នុងអំឡុងពេល២សប្ដាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្ដឹងជំទាស់។[88] បណ្ដឹងជំទាស់ ធ្វើឡើងក្នុងអំឡុងពេលមួយសប្ដាហ៍ ដោយគិតចាប់ពីថ្ងៃដែលទទួលបានដំណឹងអំពីដីកាសម្រេច។[89] អំឡុងពេលនេះ មេធាវីមិនអាចពន្យារពេលបានទេ វៀសវាងការយឺតយ៉ាវ។

នៅពេលទទួលបានពាក្យបណ្ដឹងជំទាស់ តុលាការដើមនឹងផ្ញើពាក្យបណ្ដឹងជំទាស់ និងសំណុំរឿងទៅតុលាការនៃបណ្ដឹងជំទាស់ភ្លាម។ បន្ទាប់មក នៅពេលដែលទទួលបានការផ្ញើពាក្យបណ្ដឹងជំទាស់ហើយ តុលាការនៃបណ្ដឹងជំទាស់ នឹងពិនិត្យពាក្យបណ្ដឹងជំទាស់នោះ។ ប្រសិនបើមានចំណុចណាដែលមិនស្របនឹងទម្រង់ តុលាការបង្គាប់ឱ្យដើមបណ្ដឹងជំទាស់ធ្វើការកែតម្រូវ។ ហេតុដូច្នេះ មេធាវីតំណាងដោយអាណត្តិឱ្យកូនក្ដីគប្បីធ្វើការកែតម្រូវទៅតាមការបង្គាប់របស់តុលាការ។ បើមិនដូច្នេះទេ តុលាការនឹងលើកចោលពាក្យបណ្ដឹងជំទាស់នោះ ដោយដីកាសម្រេច។[90]

[88] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៣០១(២ក)។

[89] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៣០៣(១ក)។

[90] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៣០៤(១ក) និងមាត្រា២៦៦(២ក)។

# សេចក្តីសន្និដ្ឋាន

មេធាវី ដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំនីតិរដ្ឋ ពង្រឹងយុត្តិធម៌សង្គម និងការពារសិទ្ធិមនុស្ស។ ក្នុងប្រព័ន្ធតុលាការ មេធាវីជួយដោះស្រាយវិវាទរវាងគូភាគី នៅក្នុងរឿងរដ្ឋប្បវេណី។ បច្ចុប្បន្ននេះ មេធាវីតែតែដើរតួនាទីយ៉ាងសំខាន់ ក្នុងការការពារផលប្រយោជន៍ស្របច្បាប់ជូនកូនក្តី ក្នុងដំណើរការនីតិវិធីរបស់តុលាការ។

នៅក្នុងដំណើររឿងរដ្ឋប្បវេណី មេធាវីមានតួនាទីប្រឹក្សាយោបល់ផ្នែកច្បាប់ និងតំណាងឱ្យកូនក្តី។ មេធាវីមានតួនាទីស្វែងរកភស្តុតាង ដាក់ឯកសារត្រៀម និងធ្វើសេចក្តីថ្លែងការណ៍ផ្សេងៗ ក្នុងគោលបំណងការពារផលប្រយោជន៍ជូនកូនក្តីនៅក្នុងនីតិវិធីរបស់តុលាការ។ ដោយឡែក ភាគីអាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងផ្ទាល់ ដោយមិនចាំបាច់មានមេធាវី។ ផ្ទុយទៅវិញ ភាគីក៏អាចមានសិទ្ធិជ្រើសតាំងមេធាវី ដែលជាអ្នកតំណាងដោយអាណត្តិធ្វើការបំពេញការងារជំនួសខ្លួន។ ដោយហេតុថា ភាគីគឺជាប្រជាពលរដ្ឋធម្មតាដោយពួកគាត់មិនសូវមានចំណេះដឹងខាងផ្លូវច្បាប់ និងយល់ដឹងពីនីតិវិធីនៃបណ្តឹងឱ្យបានស៊ីជម្រៅ។ បញ្ហានេះ អាចធ្វើឱ្យមានការយឺតយ៉ាវដល់នីតិវិធីបណ្តឹង និងឈានទៅដល់ការខាតបង់ផលប្រយោជន៍របស់ភាគីទាំងប្រាក់កាស និងពេលវេលា ព្រមទាំងបង្កជាលក្ខណៈស្មុគស្មាញទៅដល់តុលាការផងដែរ។ ម្យ៉ាងវិញទៀត មេធាវីត្រូវបានតំណាងដោយអាណត្តិឱ្យកូនក្តី តាមរយៈលិខិតពឹងពឹងមេធាវី និងលិខិតប្រគល់សិទ្ធិឱ្យធ្វើជាមេធាវីតំណាងដោយអាណត្តិ ដោយមានការព្រមព្រៀងរវាងគ្នាទៅវិញទៅមក។ បន្ទាប់ពីមេធាវីទទួលបានលិខិតប្រគល់សិទ្ធិរួចហើយ មេធាវីអាចមានសិទ្ធិចាត់ចែងរឿងក្តីដែលកូនក្តីបានពឹងពាក់ដោយសេរី។ មិនត្រឹមតែប៉ុណ្ណោះ នៅគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការទាំងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដោយមិនចាំបាច់មានវត្តមានរបស់កូនក្តីចូលរួមឡើយ លើកលែងតែរឿងលែងលះ។ លើសពីនេះទៅទៀត បន្ទាប់ពីបញ្ចប់នីតិវិធីទាំងពីរ មេធាវីនៅតែមានតួនាទី នៅក្នុងការពន្យល់ពីខ្លឹមសារ និងអត្ថន័យរបស់សាលក្រមជូនទៅកាន់កូនក្តី។ ជាងនេះទៀត មេធាវីនឹងផ្តល់យោបល់ដល់កូនក្តីនៅក្នុងការធ្វើបណ្តឹងឧបាស្រ័យផងដែរ នៅក្នុងករណីដែលកូនក្តីរបស់ខ្លួនមិនពេញចិត្តនឹងសេចក្តីសម្រេចនៅក្នុងការជំនុំជម្រះលើកទី១។

មេធាវីមានតួនាទីសំខាន់នៅក្នុងការអនុវត្តរឿងក្តីរដ្ឋប្បវេណី។ ការផ្តល់សេវាកម្មផ្នែកច្បាប់ និងជាអ្នកតំណាងដោយស្របច្បាប់ ក្នុងការការពារផលប្រយោជន៍ជូនកូនក្តីជាកាតព្វកិច្ចរបស់មេធាវី។ ទោះជាយ៉ាងណាក៏ដោយនៅតែមានបញ្ហាប្រឈមមួយចំនួនចំពោះមេធាវី ដើម្បីបំពេញភារកិច្ចរបស់ខ្លួនឱ្យបានកាន់តែល្អប្រសើរទាមទារឲ្យមានការផ្តល់ជាជំនួយថវិកា និងជំនួយផ្នែកច្បាប់បន្ថែមទៀត។ ម្យ៉ាងវិញទៀត គួរគប្បីជម្រុញឲ្យមានការបង្កើតសមាគមន៍គណៈមេធាវីគ្រប់ខេត្តក្រុង ដើម្បីលើកកម្ពស់ដល់ការយល់ដឹងជាសាធារណៈ ក្នុងការបម្រើវិស័យយុត្តិធម៌ លើសិទ្ធិក្នុងតុលាការ និងការទទួលបានសេវាវិជ្ជាជីវៈផ្នែកច្បាប់បានយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធិភាពផងដែរ។

# អនុសាសន៍

ការប្រឡងជ្រើសរើសមេធាវីត្រូវកើតចេញពីភាពត្រឹមត្រូវ និង យុត្តិធម៌ ដើម្បីធ្វើយ៉ាងណាអាចរើសបាននូវអ្នកដែលមានសមត្ថភាពពិតប្រាកដ។ ដូចនេះដែរ ការអនុញ្ញាតឲ្យចូលប្រកបវិជ្ជាជីវៈមេធាវីតាមស្នើសុំ ត្រូវធ្វើឡើងដោយភាពត្រឹមត្រូវ និងបំពេញតាមលក្ខខណ្ឌដែលបានកំណត់។

ក្នុងនាមជាមេធាវីត្រូវយល់ដឹងឲ្យបានស៊ីជម្រៅពីនីតិវិធីតុលាការនៅក្នុងរឿងក្តីរដ្ឋប្បវេណី។ នៅ ក្នុងពេលដំណើរការរឿងក្តី មេធាវីត្រូវយកចិត្តទុកដាក់សហការ និងបំពេញតួនាទីរបស់ខ្លួនទៅតាមដំណាក់កាលនៃនីតិវិធីនីមួយៗឲ្យបានច្បាស់លាស់។ មេធាវីមិនត្រូវបង្អាក់ ឬធ្វើឲ្យមានកំហុសណាមួយកើតឡើង ដែលនាំឲ្យនីតិវិធីតុលាការមានការយឺតយ៉ាវ និងពិសេសដែលធ្វើឲ្យខាតប្រយោជន៍នៃកូនក្តីខ្លួននោះឡើយ។ នៅពេលធ្វើការផ្សះផ្សារដៃគូទាំងពីរ ទាំងការផ្សះផ្សារដោយមេធាវី និងផ្សះផ្សារដោយតុលាការ មេធាវីគួរខិតខំឲ្យអស់លទ្ធភាពក្នុងកាតពន្យល់ណែនាំ និងសម្របសម្រួលឲ្យគូភាគីសងខាងមានការសះជានឹងគ្នា ដើម្បីអាចរក្សាបាននូវផលប្រយោជន៍នៃគីភាគីទាំងសងខាង។

មេធាវីត្រូវខិតខំឲ្យអស់ពីសមត្ថភាពក្នុងការស្វែងរក និងប្រមូលភស្តុតាងដាក់ទៅតុលាការដើម្បីគាំទ្រលើអំណះអំណាងរបស់ខ្លួនបានលើកឡើង។ មេធាវីត្រូវធ្វើយ៉ាងណាដើម្បីអាចការពារបាន នូវផលប្រយោជន៍នៃកូនក្តីខ្លួន។ មេធាវីមិនត្រូវប្រើមធ្យោបាយទុច្ចរិត ឬខុសច្បាប់ណាមួយដើម្បីបានឈ្នះក្តីឡើយ។

# ឯកសារយោង

# ឯកសារយោង

www.cdpcambodia.org.(ថតចម្លងថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២)។

www.lac.org.kh(ថតចម្លងថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២) ។

ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាគ្មានលេខ, លេខនស/រកម/០៧០៦/០២១, ០៦ ខែកក្កដា ឆ្នាំ ២០០៦។

ក្រមសីលធម៌មេធាវីរបស់គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាគ្មានលេខ, ២១ កញ្ញា ២០១២។

ច្បាប់ស្តីពីការរៀបចំអង្គការ, លេខ០២, ១០ កុម្ភៈ ១៩៨២។

ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី,លេខ នស/រកម/០៨៩៥/០៦, ១៥ មិថុនា ១៩៩៥។

បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, លេខ២២០/គ.ម/១៦, ១៣ តុលា ២០១៦។

ប៊ុន ហុន, *វិជ្ជាជីវៈមេធាវីនៅក្នុងសង្គមកម្ពុជា*, បោះពុម្ពលើកទី២(ភ្នំពេញ៖HBS Law, ២០១៦)។

យក់ ង៉ុយ និង អ៊ុង ចំរើន, *ប្រវត្តិសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច* (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១១)។

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សគ្មានលេខ, ១០ ធ្នូ ១៩៤៨, មាត្រា៧។

សេចក្តីសម្រេចស្តីពីនីតិវិធីនៃការទទួលពិនិត្យ និងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី, លេខ ១១៦/សសគម/២១, ១៥ កុម្ភៈ ២០២១។

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្ដឹង

**ដើមចោទ៖** ឈ្មោះ.......................ភេទ..........កើតឆ្នាំ............កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ៖ .........................ចុះថ្ងៃទី.........ខែ..........ឆ្នាំ...........មានអាសយដ្ឋានបច្ចុប្បន្ននៅផ្ទះ..........ផ្លូវ .............ភូមិ...............ឃុំ/សង្កាត់.................ស្រុក/ខណ្ឌ.................រាជធានី/ខេត្ត .........................។

**អ្នកតំណាងដោយអាណត្តិ៖** មេធាវី...........................អត្តលេខ......... ជាមេធាវីនៃ .......................... មានការិយាល័យតាំងនៅអគារ......................................................បន្ទប់លេខ១៩០៥ ផ្លូវលេខ១៨២ កែងផ្លូវ១៦១ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**ចុងចម្លើយ៖** ឈ្មោះ.......................ភេទ..........កើតឆ្នាំ............កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ៖ .............................ចុះថ្ងៃទី.........ខែ..........ឆ្នាំ...........មានអាសយដ្ឋានបច្ចុប្បន្ននៅផ្ទះ......... ផ្លូវ.............ភូមិ...............ឃុំ/សង្កាត់.................ស្រុក/ខណ្ឌ.................រាជធានី/ខេត្ត .........................។

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាដំបូង**......................

ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..........................................................................................

ខ. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ៖

..................................................................................................................................

..................................................................................................................................

..................................................................................................

..................................................................................................................................

..............................................................................................................

<u>គ. អង្គហេតុដែលជាមូលហេតុនៃការទាមទារ៖</u>

..................................................................................................................................

..................................................................................................................................

....................................................................................................

អាស្រ័យដូចបានរៀបរាប់ជូនខាងលើនេះ.....................................................................

..................................................................................................................................................

.....................................................................................................................................

...............................................................................................................................។

សូម ឯកឧត្តមប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី.......ខែ........ឆ្នាំ២០២២

ហត្ថលេខា និងត្រា

ឧបសម្ព័ន្ធទី២

# **លិខិតតំណាងដោយអាណត្តិ**

ខ្ញុំបាទមេធាវី...........................អត្តលេខ..................ជាមេធាវីនៃ...........................................មាន ការិយាល័យតាំងនៅអគារ........................................................................ ។

ទូរស័ព្ទទំនាក់ទំនងលេខៈ ...................................................................

## **សូមគោរពចូលមក**
## **ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ:** ស្តីពីការតំណាងដោយអាណត្តិ ឲ្យឈ្មោះ...........................នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ .................... ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង:** -មាត្រា២ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

-ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ។

-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ របស់ឈ្មោះ ............................ចុះថ្ងៃទី...... ខែមិថុនា ឆ្នាំ ២០២២ ។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថាៈ ឈ្មោះ ............................ បានប្រគល់សិទ្ធិឲ្យខ្ញុំបាទធ្វើជាមេធាវីតំណាងដោយអាណត្តិ នៅក្នុងសំណុំរឿងរដ្ឋប្បវេណី ដូចមានចែងក្នុងកម្មវត្ថុខាងលើ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន**មេត្តាជ្រាបដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ថ្ងៃ............................. ខែ................ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ.ថ្ងៃទី....... ខែកក្កដា ឆ្នាំ២០២២

**ហត្ថលេខា និង ត្រា**

ឧបសម្ព័ន្ធទី៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ</u>**

នាងខ្ញុំឈ្មោះ.................... ភេទស្រី កើតឆ្នាំ........... ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ......................... មានអាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ........... ផ្លូវ......... ភូមិបន្លាស្អិត សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ តំណាងក្រុមហ៊ុនចំរើន ខេអេច ឌីវេឡុបមេន។

**<u>សូមធ្វើការប្រគល់សិទ្ធិជូន</u>**

លោកមេធាវី .................. អត្តលេខ .............. ជាមេធាវីនៃ ....................... មានការិយាល័យតាំងនៅអគារ .........................................................ដើម្បីធ្វើជា **អ្នកតំណាងដោយអាណត្តិ** ឲ្យនាងខ្ញុំនៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ៖ ..................... ចុះថ្ងៃទី......... ខែ........ ឆ្នាំ........... របស់សាលាដំបូងរាជធានីភ្នំពេញ។

ចាប់ពីថ្ងៃផ្តិតមេដៃនេះតទៅ លោកមេធាវី .......................នឹងត្រូវបានផ្តល់សិទ្ធិដើម្បីរៀបចំបណ្តឹង ដាក់ពាក្យបណ្តឹងតប ធ្វើការផ្សះផ្សា ទទួលស្គាល់ការទាមទារ លះបង់ការទាមទារ ការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ការប្តឹងតវ៉ា បង្កើត ឯកសារចាំបាច់ ចុះហត្ថលេខាលើសំណុំរឿង ដាក់ឬដកសំណុំឯកសារណាមួយ និង គ្រប់សកម្មភាពចាំបាច់ សំរាប់ការការពារ ក៏ដូចជាការចរចារ ដោយគោរព ឬ តំណាងផលប្រយោជន៍ស្របច្បាប់ និង មានសិទ្ធិតំណាងដោះស្រាយបញ្ហានេះជាមួយអាជ្ញាធរ និង តុលាការគ្រប់ជាន់ថ្នាក់។

**<u>បញ្ជាក់</u>៖** សោហ៊ុយចំណាយលើការបង់ពន្ធផ្សេងៗ នៅក្នុងបណ្តឹងនេះ ជាបន្ទុករបស់យើងខ្ញុំជាអាណត្តិទាយក។ ក្នុងករណីមិនបានគោរពតាមកាតព្វកិច្ចនេះ នាងខ្ញុំសុខចិត្តទទួលខុសត្រូវ នូវរាល់ការបាត់បង់ផលប្រយោជន៍នានា ដោយខ្លួនឯងផ្ទាល់។

ចាប់ពីថ្ងៃផ្តិតមេដៃនេះតទៅលោកមេធាវី...........មានសិទ្ធិអំណាចពេញលេញនៅក្នុងការតំណាងដោយអាណត្តិឲ្យនាងខ្ញុំតាមផ្លូវច្បាប់។

ថ្ងៃសុក្រ ៣រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២

**បានឃើញ និង យល់ព្រម**
ធ្វើជាមេធាវីតំណាងឲ្យឈ្មោះ ....................... តាមនីតិវិធីច្បាប់។
ថ្ងៃសុក្រ ៣រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២
**ហត្ថលេខា និងត្រា**

ឧបសម្ព័ន្ធទី៤

# ពាក្យស្នើសុំថតសំណុំរឿង

ខ្ញុំបាទមេធាវី ..................... អត្តលេខ ............... ជាមេធាវីនៃ ............................................. មានការិយាល័យតាំងនៅអគារ.....................................................................................................................
ផ្លូវលេខ ១៨២ កែងលេខ ១៦១ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ជាមេធាវីតំណាងដោយអាណត្តិឲ្យ ឈ្មោះ ..................... នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ៖................................ ចុះថ្ងៃទី..........
ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

ទូរស័ព្ទទំនាក់ទំនងលេខ៖ ..............................................................

## សូមគោរពចូលមក

## ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

**កម្មវត្ថុ:** ស្នើសុំពិនិត្យ និង ថតចម្លងសំណុំរឿងរដ្ឋប្បវេណីលេខ៖...................... ចុះថ្ងៃទី....... ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង:** ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមការអនុញ្ញាតអំពី **ឯកឧត្តមប្រធាន** ធ្វើការពិនិត្យ និងថតចម្លងសំណុំរឿងដូចបានជម្រាបជូនខាងលើ ដើម្បីឲ្យខ្ញុំបាទមានលទ្ធភាពបានសិក្សាស្រាវជ្រាវ ការពារផលប្រយោជន៍ស្របច្បាប់ឲ្យកូនក្តីខ្ញុំបាទ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាតតាមការស្នើសុំដោយក្តីអនុគ្រោះ។

សូម**ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ................................ ខែ............... ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ. ថ្ងៃទី....... ខែកក្កដា ឆ្នាំ២០២២

**ហត្ថលេខា និង ត្រា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

| ឧបសម្ព័ន្ធទី៥ |
|---|

## <u>ពាក្យស្នើសុំឲ្យពិនិត្យភស្តុតាង</u>

ខ្ញុំបាទមេធាវី................. អត្តលេខ....................ជាមេធាវីនៃ....................................... មាន ការិយាល័យតាំងនៅ.................................................. ផ្លូវលេខ១៨២ កែងផ្លូវ១៦១ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

ទូរស័ព្ទទំនាក់ទំនងលេខ........................................................................

**<u>សូមគោរពចូលមក</u>**

.............................................................................................

<u>កម្មវត្ថុ៖</u> ស្នើសុំឲ្យសាកសួរសាក្សីចំនួន........(......) នាក់ ...........................ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ៖ .............ចុះថ្ងៃទី........ខែ........ឆ្នាំ..........របស់.............។

<u>យោង៖</u> -ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា

-សំណុំរឿងរដ្ឋប្បវេណីលេខ៖.............ចុះថ្ងៃទី........ខែ........ឆ្នាំ..........របស់.............។

-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ.....................ចុះថ្ងៃទី.......ខែ...........ឆ្នាំ ...........របស់ឈ្មោះ......................។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំស្នើសុំ............មេត្តាពិនិត្យនូវភស្តុតាងខាងក្រោម។

**<u>មូលហេតុនៃការបញ្ជូនភស្តុតាង</u>**

តាមពាក្យបណ្ដឹង ចុះថ្ងៃទី.........ខែ.........ឆ្នាំ..........របស់កូនក្ដីខ្ញុំបាទ/នាងខ្ញុំឈ្មោះ................ដែលប្ដឹងចុងចម្លើយឈ្មោះ...............................................................................................................។

អាស្រ័យដូចបានរៀបរាប់ខាងលើ សូម........................មេត្តាពិនិត្យដោយក្ដីអនុគ្រោះ។

សូម.................................។ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

............................................................

រាជធានីភ្នំពេញ ថ្ងៃទី.......ខែ...........ឆ្នាំ២០២២

**ហត្ថលេខា និងត្រា**

ឧបសម្ព័ន្ធទី៦

# ពាក្យសុំអនុវត្តសាលក្រម

ខ្ញុំបាទមេធាវី ........................... អត្តលេខ: ៧៥៨ ជាមេធាវីនៃ................................... មានទីតាំងការិយាល័យស្ថិតនៅអគារ..................................................ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ និងជាមេធាវីតំណាងដោយអាណត្តិអោយឈ្មោះ........................ តំណាងឱ្យសហគមន៍ពលករកម្ពុជាតាមរយៈលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចុះថ្ងៃទី..... ខែ .......... ឆ្នាំ ............។

ទូរស័ព្ទទំនាក់ទំនងលេខ: ..............................................

## សូមគោរពចូលមក

## លោកប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង

**កម្មវត្ថុ:** ស្នើសុំអនុវត្តសាលក្រមរដ្ឋប្បវេណីលេខ: ................ ចុះថ្ងៃទី**១៩** ខែ**ឧសភា** ឆ្នាំ**២០១៥** របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ត្រង់ចំណុចទី១ នៃសេចក្តីសម្រេចបញ្ចប់។

**យោង:** -សំណុំរឿងរដ្ឋប្បវេណីលេខ:.......... ចុះថ្ងៃទី១៨ ខែ**ធ្នូ** ឆ្នាំ**២០១៤** របស់សាលាដំបូងខេត្តកំពង់ឆ្នាំង

-សាលក្រមរដ្ឋប្បវេណីលេខ:...........ចុះថ្ងៃទី**១៩** ខែ**ឧសភា** ឆ្នាំ**២០១៥** របស់សាលាដំបូងខេត្តកំពង់ឆ្នាំង។

-រូបមន្តអនុវត្តសាលក្រមលេខ ............ ចុះថ្ងៃទី ...... ខែ........... ឆ្នាំ**២០១៥** របស់សាលាដំបូងខេត្តកំពង់ឆ្នាំង។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជំរាបជូន **លោកប្រធាន** មេត្តាជ្រាបថា: កាលពីថ្ងៃទី**០៥** ខែ**ឧសភា** ឆ្នាំ**២០១** សាលាដំបូងខេត្តកំពង់ឆ្នាំង បានបញ្ចប់ការទាញហេតុផលដោយ

ផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខៈ ........... ចុះថ្ងៃទី**១៨** ខែ**ធ្នូ** ឆ្នាំ**២០១៤** ដែលបានសម្រេចសេចក្តីតាមរយៈសាលក្រមរដ្ឋប្បវេណីលេខៈ ........... ចុះថ្ងៃទី**១៩** ខែ**ឧសភា** ឆ្នាំ**២០១៥** ដោយសម្រេចថាៈ

១-បង្គាប់ឱ្យចុងចម្លើយឈ្មោះ .................. និងឈ្មោះ .....................សងប្រាក់ដើមទៅដើមចោទ ឈ្មោះ .................. តំណាងសហគមន៍ពលករកម្ពុជាចំនួន **១១.៤០០$ (ដប់មួយពាន់បួនរយ) ដុល្លាអាមេរិក**។

២-បង្គាប់ឱ្យចុងចម្លើយឈ្មោះ .................. និងឈ្មោះ ..................សងការប្រាក់ចំនួន **០២% ភាគរយ** គិតចាប់ពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៤ រហូតដល់ពេលសងប្រាក់គ្រប់ចំនួនទៅឱ្យដើមចោទឈ្មោះ **ហេង រចនា** តំណាងសហគមន៍ពលករកម្ពុជា។

៣-បង្គាប់ឱ្យចុងចម្លើយឈ្មោះ .................. ឈ្មោះ .................. បង់ប្រាក់ពិន័យចំនួន **១០ ភាគរយ**លើទឹកប្រាក់ដែលត្រូវបង់ទាំងដើមទាំងការទៅឲ្យដើមចោទ ................តំណាងសហគមន៍ពលករកម្ពុជា។

៤-សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នលើចំណុច ១ នៃសេចក្តីសម្រេចបញ្ចប់ទោះបីមានការប្តឹងទាស់ និងឧទ្ធរណ៍ក៏ដោយ។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

៦-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៥ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៥ ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ហេតុដូច្នេះ ដើម្បីអនុវត្តស្របតាមខ្លឹមសារនៃការសម្រេចសេចក្តីបញ្ចប់ត្រង់ចំណុចទី ១ ពាក់ព័ន្ធនិងការបង្គាប់ឱ្យចុងចម្លើយឈ្មោះ .................. និងឈ្មោះ .................. សងប្រាក់ដើមទៅដើមចោទឈ្មោះ .................. តំណាងសហគមន៍ពលករកម្ពុជាចំនួន **១១.៤០០$ (ដប់មួយពាន់បួនរយ) ដុល្លាអាមេរិក** ខ្ញុំបាទ សូម **លោកប្រធាន** អនុវត្តតាមការស្នើសុំដូចមានក្នុងកម្មវត្ថុ ដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** ទទួលយកនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី.........ខែមិថុនា ឆ្នាំ២០១៥

**ហត្ថលេខា និងត្រា**

ឧបសម្ព័ន្ធទី៧

**<u>ពាក្យបណ្តឹងសុំជំនុំជម្រះសាជាថ្មីបន្ថែម</u>**

**<u>ដើមបណ្តឹងសុំទាមទារឲ្យជំនុំជម្រះសាជាថ្មី(ដើមចោទនៃសំណុំរឿងដើម)</u>**

-ឈ្មោះ .................., ឈ្មោះ ..................និង ឈ្មោះ.................. ទីលំនៅភូមិព្រៃក២ ឃុំឫស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល ភាគីដើមចោទនិងជាដើមបណ្តឹងជំនុំជម្រះសាជាថ្មីក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: ៩៩ សថ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់តុលាការកំពូល។

មេធាវីតំណាងដោយអាណត្តិលោក ..................អត្តលេខ............... ជាមេធាវីនៃ ....................... ...................................មានការិយាល័យតាំងនៅអគារ..................................សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

<u>ចុងបណ្តឹងសុំទាមទារឲ្យជុំជម្រះសាជាថ្មី</u>( ចុងចម្លើយនៃសំណុំរឿង )

-ឈ្មោះ .................. ភេទស្រី អាយុ ៤៨ឆ្នាំ ជនជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ភូមិព្រៃកតាសោម ឃុំឫស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល។

**<u>សូមគោរពចូលមក</u>**

**ឯកឧត្តមប្រធានតុលាការកំពូល**

ខ្លឹមសារនៃសាលដីកាទាមទារសុំឲ្យតុលាការកំពូលធ្វើការជំនុំជម្រះនិងសម្រេចជាថ្មី

១-សូមធ្វើការជំនុំជម្រះសាជាថ្មីសំណុំរឿងរដ្ឋប្បវេណីលេខ: .......... ចុះថ្ងៃទី..... ខែវិច្ឆិកា ឆ្នាំ២០២០ របស់តុលាការកំពូល។

២-សុំបដិសេធសាលដីការដ្ឋប្បវេណីលេខ: ..............ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០របស់តុលាការកំពូលត្រង់ចំណុចទី១ ទី២ ទី៣ ទី៥ នៃវិនិច្ឆ័យសេចក្តី។

3-ទទួលស្គាល់ឈ្មោះ ................ឈ្មោះ ..................និងឈ្មោះ ..................មានសិទ្ធិលើដីផ្ទេរសព ឳពុកម្តាយ ទំហំ.................មានក្នុងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី.................ចុះថ្ងៃទី២៧ តុលា ១៩៩២ មានទីតាំងនៅភូមិព្រៃកតាសោម ឃុំឫស្សីជ្រោយ ស្រុកមុខកំពូលខេត្តកណ្តាល។

៤-ប្រាប់ប្រដាប់ក្ដីជាបន្ទុករបស់ចុងបណ្ដឹង សុំទាមទារឲ្យជំនុំជម្រះសាជាថ្មី។

អង្គហេតុចាំបាច់បញ្ជាក់នូវការទាមទារសុំជំនុំជម្រះសាជាថ្មី:

- នៅលើដីទំហំ១០អា នេះមានផ្នូរឪពុកម្ដាយរបស់ម្ចាស់បណ្ដឹង ដែលម្ដាយបង្កើតរបស់ម្ចាស់បណ្ដឹងបានស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍តាំងពីកូនបង.................ទើបមានអាយុ៧ឆ្នាំមកម្ល៉េះ ហើយបញ្ចុះសពលើទីតាំងដីនេះតាំងពីឆ្នាំ១៩៩៧ រហូតមកដល់ពេលបច្ចុប្បន្នមានរយៈពេលជិត២០ឆ្នាំមកហើយ និងពេលឪពុកបង្កើតរបស់ម្ចាស់បណ្ដឹងស្លាប់ ក៏បានបញ្ចុះលើដី១០អានេះ តាំងពីឆ្នាំ២០១២ដែលគិតមកដល់ពេលបច្ចុប្បន្នមានរយៈពេលជិត១០ឆ្នាំផ្លាយដែរហើយ។
- ការបញ្ចុះសព និងមានជាផ្នូររបស់ឪពុកម្ដាយម្ចាស់បណ្ដឹងលើដីនេះ គឺមានរយៈពេលយូរយារណាស់មកហើយក្លាយជា ទីតាំងគោរពបូជាប្រចាំឆ្នាំ ជាប្រពៃណី និងជាទីសក្ការៈគោរពដឹងគុណ អ្នកមានគុណនិងមិនមានការតវ៉ា និងការជំទាស់ណាមួយពីចុងបណ្ដឹងសុំជំនុំជម្រះសាជាថ្មីឈ្មោះ .................នោះទេ។ ការបញ្ចុះសពលើដីនេះ ដោយគ្មានការជំទាស់បែបនេះ គឺជាភស្តុតាងបញ្ជាក់យ៉ាងច្បាស់នូវការទទួលស្គាល់ថាដីទំហំ១០អានេះ ជារបស់ឪពុកដើមបណ្ដឹងសុំជំនុំជម្រះសាជាថ្មីឈ្មោះ .................ពិតប្រាកដមែន។ ហើយភស្តុតាងមានភាពសុីសង្វាក់មួយទៀតគឺចម្លើយរបស់សាក្សីឈ្មោះ .................បានបញ្ជាក់ថាពេលនៅរស់ យាយ.................បានបែងចែកដីទំហំ៣០អាឲ្យទៅកូនបីនាក់ ដែលក្នុងនោះឪពុករបស់ម្ចាស់ដើមបណ្ដឹងឈ្មោះ .................ក៏បានទទួលមួយចំណែកផងដែរ។ ហេតុនេះហើយ បានជាពេលប្រពន្ធរបស់ ................. (ម្ដាយបង្កើតរបស់ដើមបណ្ដឹងសុំជំនុំជម្រះសាជាថ្មី) ស្លាប់ក៏បានយកមកបញ្ចុះនៅលើដីទំហំ១០អា (ឪពុកបង្កើតរបស់ដើមបណ្ដឹងសុំជំនុំជម្រះសាជាថ្មី)ស្លាប់ក៏បានយកមកបញ្ចុះនៅលើដីទំហំ១០អានេះដែរ គឺបញ្ចុះជាមួយគ្នាផ្នូរជាប់គ្នាលើទីតាំងដី១០អាតែមួយ។ បើសិនដីទំហំ១០អា ជាដីរបស់ចុងបណ្ដឹងដូចការអះអាងរបស់ចុងបណ្ដឹងតែម្នាក់មែននោះ ម្ល៉េះចុងបណ្ដឹងឈ្មោះ.................ប្រាកដជាមិនអនុញ្ញាតឲ្យបញ្ចុះសព និងពូនផ្នូរ របស់ឪពុកម្ដាយដើម បណ្ដឹងលើដីនេះឡើយដោយហេតុថាផ្នូរសពនោះនិងប៉ះពាល់ដល់ការប្រើប្រាស់ កាន់កាប់ និងប៉ះពាល់ដល់បូរណភាពនៃសាកសពផ្នូរបានឡើយ ដែលសកម្មភាពទាំងអស់នេះ ការពារមាត្រា ២៦១ និង ២៦២ នៃក្រមព្រហ្មទណ្ឌ។
- ដើមបណ្ដឹងសុំជំនុំជម្រះសាជាថ្មី បានចេញចូលប្រើប្រាស់ និងអាស្រ័យលើដីនេះ មានរយៈពេលជាង២០ឆ្នាំមកហើយ ហើយកាលឪពុក.................នៅរស់ក៏បានបង្កបង្កើនផលលើចំណែកដី៣០អានេះ ចិញ្ចឹមម្ដាយឈ្មោះ.................ដែរ។

- ក្រុមប្រឹក្សាជំនុំជម្រះតុលាការកំពូល បានសម្រេចតាមសាលដីកាលេខ:២៥១(ដ) ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ ដែលមិនទទួលស្គាល់ការទាមទារដើសំុជំនុំជម្រះសាជាថ្មី មិនបានពិចារណាលើសិទ្ធិរបស់ដើមបណ្ដឹង និងអាចធ្វើឲ្យប៉ះពាល់ដល់បូរណភាពនៃទីបញ្ចុះសព ដែលអាចឲ្យគូភាគីបន្តមានទំនាស់រ៉ាំរ៉ៃ គូភាគីធ្លាប់មានទំនាស់រួចមកហើយ ជាក់ស្ដែងរាល់ពេលម្ចាស់បណ្ដឹងចូលពូន និងសែនផ្នូរម្ដងៗវាពិបាកក្នុងការចេះចូលរួចទៅហើយ ដូចជាចុងបណ្ដឹងឈ្មោះ.................និងប្ដីបានយកកូនឈើមកដាំ លើទីតាំងជាប់ផ្នូរតែម្ដង ជាហេតុធ្វើឲ្យពិបាកដល់ផ្លូវចិត្ត ចុះទំរាំតែ តុលាការសម្រេចដូចសាលដីកាខាងលើ មិនយូរមិនឆាប់ ច្បាស់ជាចុងបណ្ដឹង ឈ្មោះ.................មិនអនុញ្ញាត ឲ្យម្ចាស់បណ្ដឹងចូលទៅកាន់កាប់ ឬប្រើប្រាស់ សែនផ្នូរលើដីនេះទៀតឡើយ ហើយនឹងអាចឈានទៅកំទេច និងរំលាយផ្នូរសពរបស់ឪពុកម្ដាយម្ចាស់បណ្ដឹងថែមទៀតផងក៏ថាបាន។
- ក្នុងទំព័រទី៤ បន្ទាត់ទី២៤ និង២៥តំណាងអាណត្តិចុងបណ្ដឹងសុំជំនុំជម្រះសាជាថ្មី បានបញ្ជាក់ក្នុងពេលទាញហេតុផលដោយផ្ទាល់មាត់ថា ចំពោះដី៣០អា កូនក្ដីខ្លួនយល់ព្រមប្រគល់ឲ្យ១០អាទៅដើមចោទ ចំណែក១២អាកូនក្ដីខ្លួនយល់ព្រមបែងចែកជាពីរចំណែកស្មើគ្នា ប៉ុន្តែក្រុមប្រឹក្សាជំនុំជម្រះតុលាការកំពូលបានសម្រេចផ្ទុយពីឆន្ទៈរបស់ភាគី។

អាស្រ័យហេតុនេះសូម **ឯកឧត្តមប្រធាន** មេត្តាទទួលយកបណ្ដឹងនេះ និងចាប់ផ្ដើមធ្វើការជំនុំជម្រះសារជាថ្មីឡើងវិញ សុំសម្រេចទទួលស្គាល់ឈ្មោះ ............មានសិទ្ធិលើទីតាំងដីផ្នូរទំហំ១០អា ដោយក្ដីអនុគ្រោះ។

សូម **ឯកត្តមប្រធាន** មេត្តាទទួលយកនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃអង្គារ ៧រោច ខែបុស្ស ឆ្នាំជូត ទោស័ក ពស២៥៦៤

រាជធានីភ្នំពេញថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១

ហត្ថលេខា និងត្រា

ឧបសម្ព័ន្ធទី៨

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>កិច្ចសន្យាលក់-ទិញដី</u>

*កិច្ចសន្យានេះ ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី.........ខែ........ឆ្នាំ២០២១*

រវាង

លោកស្រី ................................................ លោក ................................................**ជាភាគីអ្នកលក់ដី** ចាប់ពីពេលនេះតទៅហៅកាត់ថា ភាគី “លក់”។

និង

លោកស្រី ....................................... **ជាភាគីអ្នកទិញដី** ចាប់ពីពេលនេះតទៅហៅកាត់ថា ភាគី«ទិញ»។

**<u>យោង៖</u>** លិខិតប្រគល់ និងទទួលប្រាក់កក់ថ្លៃទិញលក់ដី ចុះថ្ងៃទី.......... ខែ...............ឆ្នាំ២០២២ ។

<u>ភាគីទាំងពីរបានព្រមព្រៀងគ្នាតាមលក្ខខណ្ឌ និងប្រការដូចខាងក្រោម៖</u>

ប្រការ ១ ៖ កម្មវត្ថុ នៃកិច្ចសន្យា

១.១ ភាគី “លក់” យល់ព្រមលក់ដីចំនួន ០១(មួយ) កន្លែងដែលមានទីតាំងស្ថិតនៅ ភូមិធ្លក ឃុំគោករការ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ទៅឲ្យ ភាគី «ទិញ» ដោយ៖ ដី០១ កន្លែង មានទំហំ ៦០៦ ម៉ែត្រការ៉េ មានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖ ១២១២០១១២-០២៣៥ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ដែលចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីរាជធានីភ្នំពេញ។

១.២ ភាគី “ទិញ” យល់ព្រមទិញដី ដូចមានចែងក្នុងចំណុច ១.១ ខាងលើ ពី ភាគី “លក់” ។

ប្រការ ២ ៖ អំពីតម្លៃដី

ភាគី “លក់” និង ភាគី “ទិញ” បានព្រមព្រៀងគ្នាទិញលក់ដី ដូចមានក្នុងប្រការ ១ ខាងលើក្នុងតម្លៃសរុប **USD ១៧៥,០០០ (ដប់ប្រាំពីម៉ឺនប្រាំពាន់) ដុល្លាអាមេរិកគត់។**

ប្រការ ៣ ៖ ការទូទាត់ប្រាក់

ភាគីទាំងពីរ បានព្រមព្រៀងគ្នាក្នុងការទូទាត់ប្រាក់ថ្លៃទិញលក់ដី ដូចមានចែងក្នុងកម្មវត្ថុខាងលើ ជា ០៣ (បី) ដំណាក់កាល ដូចខាងក្រោម៖

**<u>ដំណាក់កាលទី១៖</u>**

1. កាលពីថ្ងៃទី.........ខែ............ឆ្នាំ២០....... ភាគី "ទិញ" បានកក់ប្រាក់ចំនួន USD **៥០,០០០ (ប្រាំម៉ឺន) ដុល្លាអាមេរិកគត់** មកឲ្យ ភាគី "លក់" តាមរយៈមូលប្បទានប័ត្រលេខ៖ ............................ របស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) ។
2. បន្ទាប់ពី ភាគី "លក់" បានទទួលប្រាក់កក់ដំណាក់កាលទី១ គ្រប់ចំនួននៅថ្ងៃចុះកិច្ចសន្យា ភាគីទាំងពីរគឺ ភាគី "លក់" និង ភាគី "ទិញ" យល់ព្រមផ្តិតមេដៃលើលិខិតលក់ផ្តាច់ចំពោះមុខមន្ត្រីសុរិយោដី ដើម្បីរៀបចំទម្រង់បែបបទផ្ទេរកម្មសិទ្ធិទៅឲ្យ ភាគី "ទិញ"។
3. ហើយ ភាគី "ទិញ" ក៏យល់ព្រមផ្តិតមេដៃលើលិខិតលក់ផ្តាច់ត្រឡប់ទៅ ភាគី "លក់" ដោយតម្កល់ទុកនៅមេធាវី ហើយលិខិតនេះ ត្រូវទុកជាមោឃៈ ឬត្រូវហែកចោលនៅពេល ភាគី« ទិញ» បានទូទាត់ប្រាក់គ្រប់ចំនួន និង ភាគី«លក់» បានប្រគល់វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ (ច្បាប់ដើម) ទាំងពីរប័ណ្ណ ទៅឲ្យ ភាគី«ទិញ»។

**<u>ដំណាក់កាលទី២៖</u>**

នៅថ្ងៃចុះកិច្ចសន្យា ភាគី "ទិញ" យល់ព្រមចេញមូលប្បទានប័ត្រលេខ៖................... របស់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) ចំនួន ០១ សន្លឹកបន្ថែមទៀត ដែលស្មើនឹង **៣៥ %** នៃតម្លៃទិញលក់ដីសរុប តម្កល់ឲ្យ ភាគី "លក់" ដើម្បីទូទាត់ប្រាក់ដំណាក់កាលទី២ ដែលមានទឹកប្រាក់ USD **៤៨៣,០០០ (បួនសែនប្រាំបីម៉ឺនបីពាន់) ដុល្លារអាមេរិក** ទៅឲ្យ ភាគី "លក់" ដោយមាន រយៈពេលកំណត់ **០២ (ពីរ) ខែ និង ១៥ (ដប់ប្រាំ) ថ្ងៃ** គិតចាប់ពីថ្ងៃចុះកិច្ចសន្យាដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។ ប៉ុន្តែ មូលប្បទានប័ត្រតម្កល់នេះអាចបើកបាន លុះត្រា ភាគី "ទិញ" បានទទួលវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលបានផ្ទេរកម្មសិទ្ធិ (ថតចម្លង) ទាំង ០២ ប័ណ្ណ ដោយពិនិត្យ និងផ្ទៀងផ្ទាត់រួចរាល់ ឃើញថាត្រឹមត្រូវតាមនីតិវិធីច្បាប់។

**<u>ដំណាក់កាលទី៣៖</u>**

1. បន្ទាប់ពីទូទាត់ប្រាក់ដំណាក់កាលទី២ បានរយៈពេល **៣០ (សាបសិប) ថ្ងៃ** នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ភាគី "ទិញ" យល់ព្រមបង់ប្រាក់ចំនួន **៣៥%** បន្ថែម ដែលស្មើនឹង USD

**៤៨៣,០០០ (បួនសែនប្រាំបីម៉ឺនបីពាន់) ដុល្លាអាមេរិក** ដើម្បីបង្គ្រប់ចំនួន **១០០%** នៃតម្លៃទិញលក់ដីសរុប។

2. បន្ទាប់ពីបានទទួលប្រាក់គ្រប់ចំនួន **១០០%** ភាគី "ទិញ" ត្រូវប្រគល់វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលបានផ្ទេរកម្មសិទ្ធិរួច (ច្បាប់ដើម) ទាំង ០២ ប័ណ្ណ មកឲ្យ ភាគី "ទិញ" នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ។

ប្រការ ៤ ៖ សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់ភាគី«លក់»

៤.១. ភាគី«លក់» ធានាអះអាងថាដី ដែលខ្លួនលក់មកឱ្យ ភាគី«ទិញ» ជាកម្មសិទ្ធិស្របច្បាប់របស់ខ្លួន ដោយមិនមានជាប់ពាក់ព័ន្ធនឹងកម្មសិទ្ធិរបស់អ្នកដទៃ ឬជាប់បណ្តឹងនៅតុលាការឡើយ។ ក្នុងករណីមាន ជនណាមួយចេញមកធ្វើការតវ៉ាចំពោះដីនេះ ភាគី«លក់» យល់ព្រមចេញមុខដោះស្រាយដោយផ្ទាល់ និងទទួលខុសត្រូវរាល់ការចំណាយទាំងអស់ ដោយមិនឲ្យជាប់ពាក់ព័ន្ធជាមួយ ភាគី«ទិញ» ឡើយ។

៤.២. ភាគី«លក់» ធានារៀបចំ និងបំពេញបែបបទផ្ទេរកម្មសិទ្ធិដី (ប្លង់រឹង) មកដាក់ឈ្មោះ ភាគី«ទិញ» ឱ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់ និងឲ្យបានរួចរាល់ជាស្ថាពរក្នុងរយៈពេល **៧៥ (ចិតសិបប្រាំ) ថ្ងៃ** ។ រាល់ការចំណាយក្នុងដំណើរការ នៃការផ្ទេរកម្មសិទ្ធិដូចជា៖ ការបង់ពន្ធប្រថាប់ត្រា និងចំណាយលើសេវាផ្សេងៗ ដែលទាក់ទងនឹងដីទាំងពីរខាងលើនេះ ជាបន្ទុករបស់ ភាគី "លក់"។

៤.៣. ភាគី«លក់» ធានាថាខ្លួនមានសិទ្ធិលក់ដីនេះ និងកាត់ផ្ទេរឈ្មោះទៅឲ្យ ភាគី«ទិញ» និងធានាថាដីខាងលើនេះ មិនមានជាប់បន្ទុក សេវភាព រួមទាំងការដាក់បញ្ចាំ ហ៊ីប៉ូតែក គំហាត់របស់តុលាការ ឬស្ថាប័នណាមួយ និងមិនមានជាប់ពាក់ព័ន្ធនឹងជនណាមួយ ឬនីតិបុគ្គលណាមួយឡើយ។

៤.៤. ភាគី«លក់» ធានាថាគ្មានការពិន័យណាមួយ ដែលមិនទាន់បានបង់ទាក់ទងនឹងដីខាងលើនេះទេ។ ការចំណាយដទៃទៀតទាក់ទងនឹងការផ្ទេរកម្មសិទ្ធិលើដីនេះ ជាបន្ទុករបស់ ភាគី«លក់» ទាំងស្រុង។

៤.៥. ភាគី«លក់» មិនអាចយកដីនេះទៅលក់ ដាក់បញ្ចាំ ធ្វើអច្ច័យទាន ប្រទានកម្ម ឬធ្វើការផ្ទេរកម្មសិទ្ធិទៅឲ្យតតិយជនណាមួយផ្សេងទៀតបានឡើយ។

៤.៦. ក្នុងករណី ភាគី "លក់" កែប្រែ ឬផ្លាស់ប្តូរចិត្តឈប់លក់ដីខាងលើ ក្នុងដំណាក់កាលណាមួយ ឬមិនអាចធ្វើការផ្ទេរកម្មសិទ្ធិមកឲ្យ ភាគី«ទិញ» តាមកាលកំណត់ ដូចមានក្នុងចំណុច ៤.២ ខាងលើទេ ភាគី "លក់" ត្រូវប្រគល់ប្រាក់ទាំងអស់ ដែលខ្លួនបានទទួលមកឲ្យ ភាគី "ទិញ" វិញ និងយល់

ព្រមសងសំណងជម្ងឺចិត្ត រួមទាំងប្រាក់ពិន័យសរុបស្មើនឹង **០២ (ពីរ) ដង** នៃប្រាក់ដែលបានទទួល មកឲ្យ ភាគី«ទិញ»។

ប្រការ ៥ ៖ សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់ ភាគី “ទិញ"

៥.១. ភាគី "ទិញ" ត្រូវធ្វើការទូទាត់ប្រាក់ជូន ភាគី "លក់" ឲ្យបានទៀងទាត់ តាមកាលកំណត់ ដូចមានចែងក្នុងប្រការ ៣ ខាងលើ និងយល់ព្រមផ្តិតមេដៃលើទម្រង់លិខិតលក់ផ្តាច់ត្រឡប់ ដោយលិខិតនេះត្រូវចាត់ទុកជា មោឃៈ ឬហែកចោលជាអសារបង់ នៅពេល ភាគី "ទិញ" បានធ្វើការទូទាត់ និងបង់ប្រាក់គ្រប់ចំនួន **១០០ (មួយរយ) %** ទៅឲ្យ ភាគី "លក់" ។

៥.២. ភាគី "ទិញ" ត្រូវចូលរួម និងសហការណ៍ផ្តល់ឯកសារពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិដីខាងលើ ប្រសិនបើមានការស្នើសុំពី ភាគី "លក់" ឬតាមស្នើសុំរបស់មន្ត្រីសុរិយោដី។

៥.៣. ក្នុងករណី ភាគី "ទិញ" កែប្រែ ឬផ្លាស់ប្តូរចិត្តឈប់ទិញដីណាមួយ ឬដីទាំងពីរកន្លែងខាងលើ ឬមិនអាចអនុវត្តចំណុចណាមួយ នៃប្រការ ៣ និងប្រការ ៥ នេះបានទេ នោះចំនួនទឹកប្រាក់ទាំងអស់ ដែល ភាគី "ទិញ" បានបង់រួចត្រូវចាត់ទុកជាប្រយោជន៍ស្របច្បាប់របស់ ភាគី "លក់" ដោយ ភាគី "ទិញ" ពុំមានសិទ្ធិតវ៉ា ឬទាមទារអ្វីបន្ថែមឡើយ។

៥.៤. ភាគី»ទិញ« ត្រូវមានសិទ្ធិកាន់កាប់ដោយផ្តាច់មុខលើដីនេះក្នុងឋានៈជាម្ចាស់កម្មសិទ្ធិស្របច្បាប់ភ្លាម បន្ទាប់ពីដីនេះត្រូវបានផ្ទេរកម្មសិទ្ធិចប់សព្វគ្រប់ និងបានប្រគល់ប្រាក់គ្រប់ចំនួនទៅឲ្យ ភាគី»លក់«។

ប្រការ ៦ ៖ ការអនុវត្តកិច្ចសន្យា

៦.១. ភាគីទាំងពីរបានអាន និងយល់ព្រមតាមខ្លឹមសារទាំងអស់ នៃកិច្ចសន្យានេះ ហើយសន្យានឹងអនុវត្តឲ្យបានត្រឹមត្រូវតាមលក្ខខណ្ឌ និងតាមប្រការទាំងឡាយ ដូចមានចែងក្នុងកិច្ចសន្យានេះ។

៦.២. ក្នុងករណីភាគីណាមួយមិនអនុវត្ត ឬបំពាននូវលក្ខខណ្ឌណាមួយនៃកិច្ចសន្យានេះ នោះភាគីម្ខាងទៀត នៃកិច្ចសន្យា មានសិទ្ធិចាត់វិធានការតាមផ្លូវច្បាប់។

ប្រការ ៧ ៖ ទាយាទ

ករណីភាគីណាមួយមិនអាចអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនបាន ដោយមូលហេតុបណ្តាលមកពី មរណភាព ឬពិការភាព ឬអវត្តមានអំឡុងពេលកិច្ចសន្យានេះ នោះសិទ្ធិ និងកាតព្វកិច្ចទាំងអស់របស់គូភាគីត្រូវប្រគល់ជូនទាយាទរបស់ភាគីនោះ ឬអ្នកតំណាងស្របច្បាប់របស់ភាគីនោះ ដោយស្វ័យប្រវត្តិ។

ប្រការ ៨ ៖ ការកែប្រែ

រាល់ការកែប្រែចំណុចណាមួយ នៃកិច្ចសន្យានេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងដោយ មានការយល់ព្រមពីភាគីទាំងពីរ ដោយមានការផ្តិតមេដៃ ឬចុះហត្ថលេខារបស់ភាគីទាំងពីរ។

ប្រការ ៩. ច្បាប់គ្រប់គ្រង និងការដោះស្រាយវិវាទ

**៩.១** កិច្ចសន្យានេះ ត្រូវគ្រប់គ្រងដោយច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

**៩.២** ក្នុងករណីមានវិវាទពាក់ព័ន្ធនឹងការបកស្រាយ និងការអនុវត្តនូវកិច្ចសន្យានេះ ភាគីទាំងពីរយល់ព្រមដោះស្រាយវិវាទនេះដោយស្មារតីមិត្តភាព សន្តិវិធី និងយោគយល់គ្នា ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**៩.៣** ក្នុងករណីបរាជ័យ ភាគីទាំងពីរយល់ព្រមក្នុងការបញ្ជូនវិវាទទាំងឡាយ ដែលកើតឡើងចេញពីកិច្ចសន្យានេះទៅកាន់តុលាការមានសមត្ថកិច្ច និងមានយុត្តាធិការក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ១០ ៖ កិច្ចសន្យាទាំងមូល ភាសា និងចំនួន

កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរចំនួន ០៣ (បី) ច្បាប់ដើម និងមានតម្លៃស្មើគ្នា ដោយរក្សាទុកនៅ៖

- ភាគី«ក» ចំនួន ០១ (មួយ) ច្បាប់ដើម ។
- ភាគី«ខ» ចំនួន ០១ (មួយ) ច្បាប់ដើម ។
- តម្កល់ទុកនៅមេធាវីចំនួន ០២ (ពីរ) ច្បាប់ដើម។

***ដើម្បីជាសក្ខីភាព*** ភាគី«លក់» និង ភាគី«ទិញ» បានផ្តិតស្នាមមេដៃទទួលស្គាល់ និងយល់ព្រមទៅលើប្រការទាំងអស់នៃកិច្ចសន្យានេះ។ ប្រសិនបើភាគីណាមួយមិនបំពេញកាតព្វកិច្ច នៃកិច្ចសន្យាខាងលើនេះនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។ កិច្ចសន្យានេះនឹងចូលជាធរមានភ្លាមៗ ចាប់ពីថ្ងៃដែលគូភាគីបានផ្តិតស្នាមមេដៃនេះតទៅ។

**ស្នាមមេដៃស្តាំ**

**ភាគី«លក់»** **ភាគី«ទិញ**

**បានឃើញ និងបញ្ជាក់ថា**

ភាគីទាំងអស់ខាងលើពិតជាបានផ្តិតស្នាមមេដៃស្តាំ

ចំពោះមុខមេធាវីប្រាកដមែន។

រាជធានីភ្នំពេញ, ថ្ងៃទី.......... ខែ............... ឆ្នាំ២០២១

**ហត្ថលេខា និងត្រា**

ឧបសម្ព័ន្ធទី៩

## កិច្ចសន្យាខ្ចីបរិភោគ

*កិច្ចសន្យានេះ ធ្វើឡើងនៅភ្នំពេញ ថ្ងៃទី........ខែ.......ឆ្នាំ........*

រវាង

**អ្នកអោយខ្ចី៖** ឈ្មោះ.....................ភេទ..........កើតឆ្នាំ............សញ្ជាតិ...........កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ...........................ដែលមានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅភូមិ......................ឃុំ.....................ស្រុក..................ខេត្ត...................ជាអ្នកអោយខ្ចីប្រាក់ ឬម្ចាស់បំណុល តទៅហៅកាត់ថាភាគី "ក" ។

និង

**អ្នកខ្ចី៖** (១) ឈ្មោះ.....................ភេទ..........កើតឆ្នាំ............សញ្ជាតិ...........កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ...........................ដែលមានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅភូមិ......................ឃុំ.....................ស្រុក..................ខេត្ត...................ជាអ្នកអោយខ្ចីប្រាក់ ឬម្ចាស់បំណុល តទៅហៅកាត់ថាភាគី "ខ" ។

(២) **អ្នកធានាបំណុល៖** ឈ្មោះ.....................ភេទ..........កើតឆ្នាំ............សញ្ជាតិ...........កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ...........................ដែលមានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅភូមិ......................ឃុំ.....................ស្រុក..................ខេត្ត...................ជាអ្នកអោយខ្ចីប្រាក់ ឬម្ចាស់បំណុល តទៅហៅកាត់ថា ភាគី "ខ" ។

### ភាគីទាំងពីរបានព្រមព្រៀងគ្នាខ្ចីការប្រាក់តាមប្រការដូចមានចែងខាងក្រោម៖

ប្រការ ១៖ ***ភាគី "ខ"*** បានស្នើសុំខ្ចីប្រាក់ពី ***ភាគី "ក"*** ចំនួន USD ៥៥០.០០០ (ហាសិបប្រាំម៉ឺនដុល្លារអាមេរិក) ដោយកំណត់អត្រាការប្រាក់ ០២% (ពីរភាគរយ)ក្នុង ០១(មួយ)ខែ នៃប្រាក់កម្ចីសរុបសម្រាប់រយៈពេល ០១(មួយ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី១៩ ខែមេសាឆ្នាំ២០២២ ដល់ថ្ងៃទី១៩ ខែមេសាឆ្នាំ២០២៣។ ចំពោះការខ្ចីប្រាក់ខាងលើនេះ ភាគី "ខ" យល់ព្រមដាក់ធានានូវទ្រព្យសម្បត្តិជា វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖................ចុះថ្ងៃទី១៤ ខែ វិច្ឆិកា ឆ្នាំ ២០២១ ឲ្យទៅភាគី***"ក"*** ដើម្បីជាថ្នូរការខ្ចីប្រាក់ ។

ប្រការ ២៖ ***ភាគី "ក"*** យល់ព្រមឲ្យ***ភាគី "ខ"*** ខ្ចីប្រាក់តាមប្រការ១ ខាងលើចំនួន USD ៥៥០.០០០ (ហាសិបប្រាំម៉ឺនដុល្លារអាមេរិក) ដោយគិតអត្រាការប្រាក់ ០២% (ពីរភាគរយ) ក្នុង ០១(មួយ)ខែ នៃ

ប្រាក់កម្ចីសរុបសម្រាប់រយៈពេល ០១(មួយ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី១៩ ខែមេសាឆ្នាំ២០២២ ដល់ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ ដើម្បីឲ្យ**ភាគី "ខ"** យកទៅលោះប្លង់ដី ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖................ចុះថ្ងៃទី.........ខែ...........ឆ្នាំ............ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី (ឆាយ ឫទ្ធិសែន)ពីធនាគារអេស៊ីលីដា ភីអិលស៊ី (ACLEDA Bank)សាខាពោធិ៍ចិនតុង ។

ប្រការ ៣៖ **ការទូទាត់ប្រាក់**

ភាគីទាំងពីរបានឯកភាពគ្នាក្នុងការទូទាត់ប្រាក់ជា ០២ដំណាក់កាលដូចខាងក្រោម៖

៣.១ **ដំណាក់ការទីមួយ ភាគី "ក"** ត្រូវបង់ប្រាក់ចំនួន **USD ១០៤.០០០** (ដប់ម៉ឺនបួនពាន់ដុល្លារអាមេរិក)នៅថ្ងៃកិច្ចសន្យាឲ្យ **ភាគី"ខ"** ដើម្បីឲ្យ **ភាគី"ខ"** យកទៅលោះប្លង់ដី ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖............ចុះថ្ងៃទី......ខែ........ឆ្នាំ.......ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី (ឆាយ ឫទ្ធិសែន)ពីធនាគារអេស៊ីលីដា ភីអិលស៊ី (ACLEDA Bank)សាខាពោធិ៍ចិនតុង។

៣.២ **ដំណាក់កាលទី២ ៖ ភាគី "ក"** ត្រូវបង់ប្រាក់លើកទី២ ចំនួន USD ៤៤៦.០០០ (សែសិបបួនម៉ឺនប្រាំមួយពាន់ដុល្លារអាមេរិក) ឲ្យទៅ **ភាគី"ខ"** បន្ទាប់ពីបានការរត់ការ ចុះបញ្ជីដោះបន្ទុកហ៊ីប៉ូតែកពីធនាគារអេស៊ីលីដា ភីអិលស៊ី (ACLEDA Bank) មកចុះបញ្ជីដាក់បន្ទុកហ៊ីប៉ូតែក ជាមួយនឹង**ភាគី "ក"** រួចរាល់។

ប្រការ ៤៖ **របៀបប្រគល់ការប្រាក់ និងប្រាក់ដើម**

៤.១. **ភាគី "ខ"** ត្រូវបង់ការប្រាក់ចំនួន ០២% (ពីរភាគរយ) នៃប្រាក់កម្ចីសរុប ស្មើទឹកប្រាក់ USD ១១.០០០ (មួយម៉ឺនមួយពាន់ដុល្លារអាមេរិក)ទៅឱ្យ**ភាគី "ក"** ជារៀងរាល់ខែគឺនៅថ្ងៃទី....នៃខែនីមួយៗតាមរយៈ មូលប្បទានប័ត្ររបស់ធនាគារ....................ដូចខាងក្រោម៖

- មូលប្បទានប័ត្រលេខ៖.......................ចុះថ្ងៃទី.........ខែ..............ឆ្នាំ..........ចំនួន USD ១១.០០០ (មួយម៉ឺនមួយពាន់ដុល្លារអាមេរិក) ។
- មូលប្បទានប័ត្រលេខ៖.......................ចុះថ្ងៃទី.........ខែ..............ឆ្នាំ..........ចំនួន USD ១១.០០០ (មួយម៉ឺនមួយពាន់ដុល្លារអាមេរិក) ។
- មូលប្បទានប័ត្រលេខ៖.......................ចុះថ្ងៃទី.........ខែ..............ឆ្នាំ..........ចំនួន USD ១១.០០០ (មួយម៉ឺនមួយពាន់ដុល្លារអាមេរិក) ។

- មូលប្បទានប័ត្រលេខ៖......................ចុះថ្ងៃទី.........ខែ.............ឆ្នាំ..........ចំនួន USD ១១.០០០ (មួយម៉ឺនមួយពាន់ដុល្លារអាមេរិក) ។
- មូលប្បទានប័ត្រលេខ៖......................ចុះថ្ងៃទី.........ខែ.............ឆ្នាំ..........ចំនួន USD ១១.០០០ (មួយម៉ឺនមួយពាន់ដុល្លារអាមេរិក) ។
- មូលប្បទានប័ត្រលេខ៖......................ចុះថ្ងៃទី.........ខែ.............ឆ្នាំ..........ចំនួន USD ១១.០០០ (មួយម៉ឺនមួយពាន់ដុល្លារអាមេរិក) ។
- មូលប្បទានប័ត្រលេខ៖......................ចុះថ្ងៃទី.........ខែ.............ឆ្នាំ..........ចំនួន USD ១១.០០០ (មួយម៉ឺនមួយពាន់ដុល្លារអាមេរិក) ។
- មូលប្បទានប័ត្រលេខ៖......................ចុះថ្ងៃទី.........ខែ.............ឆ្នាំ..........ចំនួន USD ១១.០០០ (មួយម៉ឺនមួយពាន់ដុល្លារអាមេរិក) ។
- មូលប្បទានប័ត្រលេខ៖......................ចុះថ្ងៃទី.........ខែ.............ឆ្នាំ..........ចំនួន USD ១១.០០០ (មួយម៉ឺនមួយពាន់ដុល្លារអាមេរិក) ។

**៤.២.** **ភាគី "ខ"** យល់ព្រមប្រគល់មូលប្បទានប័ត្រលេខ៖....................ចុះថ្ងៃទី.......ខែ...............ឆ្នាំ ..............ដែលមានទឹកប្រាក់ចំនួនUSD ៥៥០.០០០ (ហាសិបប្រាំមឺុនដុល្លាអាមេរិក) របស់ធនាគារ................មកឲ្យ **ភាគី "ក"** រក្សាទុកដើម្បីសងប្រាក់ដើមជូន **ភាគី "ក"** នៅពេលដល់ថ្ងៃកំណត់សង់ប្រាក់។

**៤.៣.** **ភាគី "ខ"** ត្រូវទូទាត់សងប្រាក់ដើមចំនួន ...................................... ជូន**ភាគី "ក"** វិញតាមពេលកំណត់ក្នុងប្រការ១ និងប្រការ២ ខាងលើគឺនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣។ ក្នុងករណីដល់ពេលកំណត់**ភាគី "ខ"** ចង់បន្តកិច្ចសន្យានេះបន្តទៀតនោះ**ភាគី "ខ"** ត្រូវជួបគ្នាសារជាថ្មីជាមួយនឹង**ភាគី "ក"** ។

**៤.៤.** ករណី **ភាគី "ខ"** អនុវត្តកាតព្វកិច្ចសងការប្រាក់តាមប្រការ៤.១.២ ជូន**ភាគី "ក"** បានរយៈពេល ០៦ខែ **ភាគី "ខ"** អាចស្នើសុំសងរំលស់ប្រាក់ដើមជូន**ភាគី "ក"** តាមចំនួនជាក់ស្តែង។

**៤.៥.** **ភាគី "ខ"** ធានាអះអាងខ្លួនជាម្ចាស់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖........ ចុះថ្ងៃទី .......ខែ..............ឆ្នាំ..........ចេញដោយមន្ទីរនគររូបនីយកម្ម សំណង់ និងសុរិយោដី (ឆាយ ឬទ្ធិសែន)ពិតប្រាកដមែន ដោយមិនមានជាន់ពាក់ពន្ធ័នៅក្នុងការលក់-ដូរ-ជួល ប្រាតិភោគ ឬជាប់បន្ទុកបញ្ចាំឬវិវាទផ្សេងៗជាមួយភាគី ឬក្រុមហ៊ុន ឬធានាគារណាមួយ

ប្រការ ៥៖ ប្រាក់ពិន័យចំពោះការយឺតយ៉ាវ

បើមានការយឺតយ៉ាវក្នុងការបង់ការប្រាក់**ភាគី "ខ"** យល់ព្រមឲ្យ**ភាគី "ក"** ពិន័យដូចខាងក្រោម៖

១-លើសកំណត់ ៥ថ្ងៃ ត្រូវពិន័យ៥% ក្នុងមួយថ្ងៃនៃប្រាក់ត្រូវបង់ប្រចាំខែនីមួយៗ។

២-លើសកំណត់ ១០ថ្ងៃ ត្រូវពិន័យ១០% ក្នុងមួយថ្ងៃនៃប្រាក់ត្រូវបង់ប្រចាំខែនីមួយៗ។

៣-ក្នុងករណីលើសកំណត់ ៦០ថ្ងៃ ភាគី ក សុខចិត្តឲ្យភាគី ខ ដាក់ប្រកាសលក់ឡៃឡុងនូវអចលនវត្ថុដែលមានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ៖.......................ចុះថ្ងៃទី.........ខែ.............ឆ្នាំ............ ក្នុងរយៈពេល ៣០ថ្ងៃតែប៉ុណ្ណោះហើយ ភាគី ក យល់ព្រមជួយសម្រួលនូវឯកសារពាក់ព័ន្ធក្នុងការផ្ទេរកម្មសិទ្ធិជូន ភាគី ក ។

៤-ករណី **ភាគី "ខ"** មិនអាចលក់ឡៃឡុងនូវអចលនវត្ថុដែលមានអចលនវត្ថុលេខ៖.......................ចុះថ្ងៃទី.........ខែ.............ឆ្នាំ............ ក្នុងរយៈពេល ៣០ថ្ងៃ ដូចមាននៅក្នុងចំណុចទី៣ ប្រការ៥ នោះភាគី "ខ" បេក្ខភាពយល់ព្រមផ្ទេរកម្មសិទ្ធិអចលនវត្ថុនេះមកឲ្យភាគី "ក" ជាម្ចាស់កម្មសិទ្ធិ ដោយគ្មានការជំទាស់ ឬតវ៉ាឡើយ។

ប្រការ ៦ ៖ **កាតព្វកិច្ចរបស់អ្នកធានាបំណុល**

អ្នកធានាបំណុល ឈ្មោះ.......................ត្រូវជាកូនបង្កើតរបស់ អ្នកខ្ចីប្រាក់ ឈ្មោះ...................ត្រូវជាប់កាតព្វកិច្ចដោយសាមគ្គីជាមួយអ្នកខ្ចី ឬអ្នកធានា រាល់បំណុលទាំងអស់របស់ឪពុកខ្លួន តាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់នេះ។

ប្រការ ៧ ៖ **កំហុស**

ក្នុងករណី កូនបំណុលអាក់ខានក្នុងការអនុវត្តកាតព្វកិច្ច នៃកិច្ចសន្យានេះ ត្រូវចាត់ទុកជាកំហុសរបស់ កូនបំណុល ដែលនាំឲ្យ ម្ចាស់បំណុល ប្ដឹងតាមផ្លូវតុលាការនោះ រាល់ការចំណាយលើកាតបង់ពន្ធ សេវាមេធាវី និងចំណាយផ្សេងៗលើផ្នែករដ្ឋបាល គឺជាបន្ទុករបស់កូនបំណុលទាំងស្រុង។

ប្រការ ៨ ៖ **ទាយាទ អ្នកស្នងមរតក និងអ្នកទទួលសិទ្ធិដោយស្របច្បាប់**

ក្នុងករណីដែលភាគីណាមួយអវត្តមាន ដោយមានឧបទ្ទវហេតុកើតឡើងដោយចៃដន្យជាយថាហេតុ ក្នុងប្រការណាមួយ ឬមិនអាចមកបំពេញកាតព្វកិច្ច នៃកិច្ចសន្យានេះបានទេនោះ ទាយាទស្របច្បាប់ត្រូវតែមានការទទួលស្គាល់ពីអាជ្ញាធរសាធារណៈហើយទាយាទនោះ អាចចូលមកបំពេញកាតព្វកិច្ច នៃកិច្ចសន្យាប្រាក់នេះជំនួសភាគីណាដែលស្លាប់ ឬបាត់ខ្លួនបានគ្រប់ពេល។

ប្រការ ៩ ៖ ភាគីទាំងពីរត្រូវគោរពកិច្ចសន្យាឲ្យបានមឹ ុងម៉ាត់ បើភាគីណាមួយបំពានលើកិច្ចសន្យា នោះភាគីត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះមុខច្បាប់ ។ រាល់សោហ៊ុយចំណាយក្នុងការដោះស្រាយវិវាទ គឺជាបន្ទុករបស់ភាគីដែលរំលោភបំពានលើកិច្ចសន្យា។

ប្រការ ១០ ៖ កិច្ចសន្យានេះត្រូវធ្វើឡើងជាភាសាខ្មែរចំនួន០៣ច្បាប់ ហើយគ្រប់ច្បាប់ទាំងអស់ គឺមានអត្ថន័យ និងខ្លឹមសារដូចគ្នា។ ហើយ**ភាគី "ក"** និង**ភាគី "ខ"** រក្សាទុក០១ច្បាប់ និងមេធាវីរក្សាទុក០១ច្បាប់។

ភាគីទាំងពីរបានយល់ច្បាស់ពីខ្លឹមសារទាំងអស់ នៃកិច្ចសន្យានេះ ហើយបានចុះហត្ថលេខា និងផ្តិតស្នាមមេដៃ ដើម្បីយាសាក្ខីភាព នៃការព្រមព្រៀងរបស់ខ្លួនដោយពុំមានការបង្ខិតបង្ខំពីភាគីណាមួយឡើយ។ កិច្ចព្រមព្រៀងនេះ មានសុពលភាព និងប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃផ្តិតស្នាមមេដៃ ឬចុះហត្ថលេខានេះតទៅ។

**ស្នាមមេដៃស្តាំអ្នកឲ្យខ្ចី** **ស្នាមមេដៃស្តាំអ្នកធានាបំណុល** **ស្នាមមេដៃស្តាំអ្នកខ្ចី**

................................ ........................................ .........................

បានឃើញ

**រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២**

ហត្ថលេខា និងត្រា

ឧបសម្ព័ន្ធទី១០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## កិច្ចសន្យាម៉ៅការចាក់ថ្ម

កិច្ចសន្យានេះត្រូវបានធ្វើឡើងនៅថ្ងៃទី....... ខែ.......... ឆ្នាំ.............

**រវាងៈ**

-លោក.......................អាយុ.......ឆ្នាំ សញ្ជាតិ.............ជនជាតិ...........កាន់លិខិតឆ្លងដែនលេខ................ចុះថ្ងៃទី....... ខែ.......... ឆ្នាំ........... ជនជាតិ....... មានអាសយដ្ឋាននៅផ្ទះលេខ........ សង្កាត់............ ខណ្ឌ............. រាជធានីភ្នំពេញ ជា ដែលចាប់ពីពេលនេះតទៅហៅកាត់ថា **ភាគី** "**ក**" ។

**និង**

-លោក.......................... អាយុ.......ឆ្នាំ សញ្ជាតិ.............ជនជាតិ...........កាន់លិខិតឆ្លងដែនលេខ................ចុះថ្ងៃទី....... ខែ.......... ឆ្នាំ........... ជនជាតិ....... មានអាសយដ្ឋាននៅផ្ទះលេខ........ សង្កាត់............ ខណ្ឌ............... រាជធានីភ្នំពេញ និងលោក.......................... អាយុ.......ឆ្នាំ សញ្ជាតិ.............ជនជាតិ...........កាន់លិខិតឆ្លងដែនលេខ................ចុះថ្ងៃទី....... ខែ.......... ឆ្នាំ........... ជនជាតិ....... មានអាសយដ្ឋាននៅផ្ទះលេខ........ សង្កាត់............ ខណ្ឌ............... រាជធានីភ្នំពេញ ជាតំណាងអោយក្រុមហ៊ុន ដែលចាប់ពីពេលនេះតទៅហៅកាត់ថា **ភាគី** "**ខ**"។

**បុព្វកថាៈ**

ដោយហេតុថា **ភាគី** "**ក**" ជាម្ចាស់ការដ្ឋានថ្មស្ថិតនៅ..........ស្រុក.........ខេត្ត................និងបានទទួលអាជ្ញាប័ណ្ណក្នុងការធ្វើអាជីវកម្មជីកថ្ម ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា សន្យាថានឹងផ្គត់ផ្គង់ថ្ម គ្រប់ប្រភេទ.....................ដែលចាប់ពីពេលនេះតទៅហៅកាត់ថា ថ្ម ឲ្យដើរភាគីខ ហើយភាគីខ

មានបំណងក្នុងការទិញថ្មពីភាគីក ដើម្បីចាក់បំពេញផ្លូវស្ថិតនៅភូមិ...............សង្កាត់............ក្រុង ............ខេត្ត...........................។

<u>**ក្រោយពីបានពិភាក្សាគ្នា ភាគីទាំងពីរ បានដោយស្ម័គ្រចិត្តទទួលរាល់លក្ខខណ្ឌ និងខ សន្យាទាំងឡាយដែលចែងដូចខាងក្រោម៖**</u>

## ផ្នែក ១

## គោលបំណងនៃកិច្ចសន្យា

**ប្រការ ១ ៖** កិច្ចសន្យាម៉ៅការនេះ ធ្វើឡើងក្នុងគោលបំណងសាងសង់ទីលាន ........... (មួយ) កន្លែង ទំហំ.......ម៉ែត្រ គុណនឹង........ម៉ែត្រ មានទីតាំងនៅភូមិ........ សង្កាត់............ ខណ្ឌ ............... ខេត្ត/ក្រុង............. តទៅនេះហៅថា "កម្មវត្ថុនៃកិច្ចសន្យាម៉ៅការ"។

**ប្រការ ២ ៖** **ភាគី "ក"** យល់ព្រមព្រគល់កិច្ចការទាំងឡាយដូចមានណៅក្នុងប្រការ ១ នៃកិច្ចសន្យានេះ ឲ្យ **ភាគី "ខ"** ដោយផ្តល់ប្រាក់ឈ្នួលម៉ៅការចំនួន................... (................ ដុល្លារអាមេរិក) ។ **ភាគី "ខ"** បានព្រមព្រៀងប្រគល់ធ្វើកិច្ចការដូចចែងក្នុងប្រការ ១ នៃកិច្ចសន្យានេះពី **ភាគី "ក"** ដោយយកប្រាក់ឈ្នួលម៉ៅការដូចចែងក្នុងប្រការ ២។

## ផ្នែក ២

## ការទូទាត់ប្រាក់ឈ្នួលម៉ៅការ

**ប្រការ ៣ ៖** **ភាគី "ក"** និង **ភាគី "ខ"** ព្រមព្រៀងធ្វើការទូទាត់ប្រាក់ឈ្នួលម៉ៅការជាបីដំណាក់កាលដូចតទៅ៖

-ទី១ **ភាគី "ក"** សន្យាផ្តល់ប្រាក់ឈ្នួលម៉ៅការចំនួន................... (................ដុល្លារអាមេរិក) ឲ្យ **ភាគី "ខ"** នៅពេលដាក់កម្មករ និងគ្រឿងចក្រឈូសឆាយដីឲ្យរាប ដាក់ប្រព័ន្ធលូ រត់ជុំវិញតារាងបាល់ ជាកម្មវត្ថុនៃកិច្ចសន្យា។

-ទី២ **ភាគី "ក"** សន្យាផ្តល់ប្រាក់ឈ្នួលម៉ោការចំនួន................... (................ដុល្លារអាមេរិក) ឲ្យ **ភាគី "ខ"** នៅពេលតម្លើងបង្គោលភ្លើងរួច បញ្ចូលថ្ម (Mix) ផេះ និងចាប់ផ្តើមក្រាលស្មៅសិប្បនិម្មិត។

-ទី៣ **ភាគី "ក"** សន្យាផ្តល់ប្រាក់ឈ្នួលម៉ោការដែលនៅសល់ចំនួន................... (................ដុល្លារអាមេរិក) ឲ្យ **ភាគី "ខ"** នៅពេលកម្មវត្ថុនៃកិច្ចម៉ោការចប់ជាស្ថាពរ។

**ប្រការ ៤ ៖** **ភាគី "ខ"** សន្យាបំពេញកម្មវត្ថុនៃកិច្ចសន្យានេះ ឲ្យបានសម្រេចមិនលើសពីរយៈពេល ....... ខែ ចាប់គិតពីថ្ងៃទី....... ខែ....... ឆ្នាំ.......... រហូតដល់ថ្ងៃទី....... ខែ....... ឆ្នាំ..........។ ករណីមានការយឺតយ៉ាវ **ភាគី "ខ"** យល់ព្រមបង់ប្រាក់ពិន័យចំនួន................... (................ដុល្លារអាមេរិក)ក្នុងមួយថ្ងៃនៃការយឺតយ៉ាវទៅឲ្យ **ភាគី "ក"** ។

## ផ្នែក ៣

## សិទ្ធិ និងភារកិច្ចរបស់គូភាគី

**ប្រការ ៥ ៖** **ភាគី "ក"** មានកាតព្វកិច្ចបង់ប្រាក់ឲ្យបានទៀងទាត់តាមប្រការ៣។ ករណីមានការយឺតយ៉ាវ **ភាគី "ក"** យល់ព្រមបង់ប្រាក់ពិន័យចំនួន................... (................ដុល្លារអាមេរិក)ក្នុងមួយថ្ងៃនៃការយឺតយ៉ាវទៅឲ្យ **ភាគី "ខ"** ។

**ប្រការ ៦ ៖** ករណី **ភាគី "ក"** មានចេតនាបញ្ឈប់ ឬរំលាយកិច្ចសន្យានេះ **ភាគី "ក"** យល់ព្រមប្រគល់ប្រាក់ដែលបានប្រគល់ឲ្យ **ភាគី "ខ"** រួចដោយគ្មានការតវ៉ា។

**ប្រការ ៧ ៖** **ភាគី "ក"** មានកាតព្វកិច្ចសម្របសម្រួលលើបញ្ហាផ្លូវច្បាប់ទាំងឡាយណា បូករួមទាំងប្រាក់ពន្ធដែលកើតចេញពីកម្មវត្ថុនៃកិច្ចសន្យានេះ តាមតម្រូវការដាក់ស្នែងពីអាជ្ញាធរពាក់ព័ន្ធ។

**ប្រការ ៨ ៖** **ភាគី "ក"** មានកាតព្វកិច្ចធានាផ្គត់ផ្គង់សម្ភារៈប្រព័ន្ធលូទឹក និងភ្លើង តាមសំណើរបស់ **ភាគី "ខ"** ដូចមានជូនក្នុងឧបសម្ព័ន្ធស្តីពីតារាងតម្លៃស្មៅសិប្បនិម្មិត។ ក្នុងករណីការផ្គត់ផ្គង់សម្ភារៈមិនទាន់ពេលវេលា **ភាគី "ក"** ត្រូវទទួលខុសត្រូវលើការយឺតយ៉ាវដែលផ្ទុយនឹងបញ្ញត្តិនៃប្រការ៤។

**ប្រការ ៩ ៖** **ភាគី "ខ"** ទទួលខុសត្រូវនូវរាល់ទង្វើ និងសកម្មភាពបំពេញការងារម៉ៅការរបស់ខ្លួន ដោយគោរពទៅតាមច្បាប់ និងទំនៀមទំលាប់ល្អនៃព្រះរាជាណាចក្រកម្ពុជា ពិសេសត្រូវសម្របសម្រួល និងដោះស្រាយនូវរាល់ការរំខានដល់អ្នកជិតខាងនសទីតាំងការដ្ឋានម៉ៅការ។

**ប្រការ ១០ ៖** **ភាគី "ខ"** ធានាគុណភាពសំណង់ដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការរយៈពេល ១២ (ដប់ពីរ)ខែ និងរយៈពេលប្រាំឆ្នាំ សម្រាប់ស្មោសិប្បនិម្មិតដែលបានក្រាលរួច។ **ភាគី "ខ"** យល់ព្រមផ្តល់ការថែទាំលើទីលាន និងសំណង់តារាងបាល់ទាត់នៃកិច្ចម៉ៅការសម្រាប់រយៈពេលមួយឆ្នាំពេញ។

**ប្រការ ១១ ៖** ករណី **ភាគី "ខ"** មានចេតនាបញ្ឈប់កិច្ចការម៉ៅការ ឬរំលាយកិច្ចសន្យានេះ **ភាគី "ខ"** ត្រូវសងប្រាក់ដែលទទួលពី **ភាគី "ក"** ត្រឡប់ឲ្យ **ភាគី "ក"** វិញនូវប្រាក់ដែលបានទទួលគុណនឹង០២ (ពីរ) ដង ក្នុងរយៈពេលមិនលើសពី ០២ (ពីរ) សប្តាហ៍បន្ទាប់ពីការបញ្ឈប់។

## ផ្នែក ៤
## ការបញ្ចប់កិច្ចសន្យា

**ប្រការ ១២ ៖** កិច្ចសន្យានេះអាចបញ្ចប់ក្រោយពេលដែល **ភាគី "ក"** បានប្រគល់ប្រាក់គ្រប់ចំនួន ដូចចែងក្នុងប្រការ៤ ហើយ **ភាគី "ខ"** បានបញ្ចប់កិច្ច ការម៉ៅការដោយជោគជ័យ។ ក្នុងករណីភាគីណាមួយពុំបានបំពេញកាតព្វកិច្ចទៅតាមលក្ខខណ្ឌ និងខចែងទាំងឡាយក្នុងកិច្ចសន្យានេះ នឹងត្រូវចាត់ទុកជាការរំលោភលើកិច្ចសន្យា ហើយភាគីនោះត្រូវទទួកខុសត្រូវចំពោះមុខច្បាប់។

## ផ្នែក ៥
## វិវាទ និងដំណោះស្រាយ

**ប្រការ ១៣ ៖** ក្នុងករណីមានប្រធានស័ក្ក ឬហេតុការណ៍ណាមួយកើតឡើងក្រៅឆន្ទៈរបស់គូភាគី ហើយរារាំងដល់ការអនុវត្តតាវកាលិកនៃកិច្ចសន្យានេះ ឬវិវាទដែលកើតឡើងទាក់ទងនឹងកិច្ច

សន្យានេះ គូភាគីត្រូវសហការគ្នាដោះស្រាយបញ្ហាដោយសន្តិវិធីឲ្យអស់លទ្ធភាព មុននឹងអាចដល់តុលាការមានសមត្ថកិច្ច។

**ប្រការ ១៣ ៖** កិច្ចសន្យានេះត្រូវធ្វើឡើងចំនួន ០៣ (បី) ច្បាប់ដើម ច្បាបនីមួយៗមានសុពលភាពដូចគ្នាគូភាគីរក្សាទុកមួយច្បាប់ និងមួយច្បាប់ទៀតរក្សាទុកនៅមេធាវី។ កិច្ចសន្យានេះមានអានុភាពអនុវត្ត ចាប់ពីគូភាគីទាំងពីរអាន ពិនិត្យ និងយល់ព្រមលើគ្រប់បញ្ញត្តិប្រការ ទាំងអស់មុននឹងចុះហត្ថលេខា ឬផ្តិតមេដៃលើគ្រប់ទំព័រនៃអត្ថបទកិច្ចសន្យានៅចំពោះមុខមេធាវីជាកសិណសាក្សី។

រាជធានីភ្នំពេញ ថ្ងៃទី........ខែ..........ឆ្នាំ...............

**ស្នាមមេដៃស្តាំ**

**ភាគី "ក"** **ភាគី "ខ"**

**បានឃើញ និងបញ្ជាក់ថា**

ភាគីទាំងពីរខាងលើពិតជាបានផ្តិតមេដៃ

នៅចំពោះមុខមេធាវីប្រាកដមែន។

រាជធានីភ្នំពេញ ថ្ងៃទី.... ខែ.........ឆ្នាំ.........

**ហត្ថលេខា និងត្រា**

ឧបសម្ព័ន្ធទី១១

# កិច្ចសន្យាខ្ចីចងការប្រាក់

*កិច្ចសន្យានេះ ធ្វើឡើងនៅភ្នំពេញ ថ្ងៃទី........ខែ.......ឆ្នាំ........*

**រវាង**

លោក/លោកស្រី.....................ឆ្នាំកំណើត............កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ......................មានអាសយដ្ឋានផ្ទះលេខ...........ផ្លូវ.........សង្កាត់................ខ័ណ្ឌ.................... រាជធានីភ្នំពេញ តទៅនេះក្នុងកិច្ចសន្យាហៅថា ម្ចាស់បំណុល ឬ ភាគី "ក" ។

**និង**

លោក/លោកស្រី.....................ឆ្នាំកំណើត............កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ......................មានទីលំនៅសព្វថ្ងៃ...................................................................................... តទៅនេះក្នុងកិច្ចសន្យាហៅថា **កូនបំណុល ឬ ភាគី "ខ"** ។

**ភាគីទាំងពីរបានព្រមព្រៀងគ្នាតាមលក្ខខណ្ឌនៃកិច្ចសន្យាដូចខាងក្រោម៖**

**ប្រការ ១៖** ចំនួនទឹកប្រាក់កម្ចី និងអាត្រាការប្រាក់

១.១ ភាគី "ក" យល់ព្រមផ្តល់ប្រាក់កម្ចីចំនួន USD............(.............ដុល្លាអាមេរិក) ទៅអោយភាគី "ខ" ដើម្បីប្រើប្រាស់ប្រកបអាជីវកម្ម និងប្រើប្រាស់ សម្រាប់ជីវភាពប្រចាំថ្ងៃ។ ហើយភាគី "ខ" យល់ព្រមខ្ចីប្រាក់ដូចមានចំនួនខាងលើ ពីភាគី "ក"។

**ប្រការ ២៖** រយៈពេលខ្ចី និងលក្ខខណ្ឌផ្សេង

២.១ កិច្ចសន្យាខ្ចីចងការប្រាក់នេះ មានរយៈពេល.........ខែ គិតចាប់ពីថ្ងៃទី........ខែ..........ឆ្នាំ ............ថ្ងៃទី........ខែ..........ឆ្នាំ...........។ភាគី "ខ"ត្រូវសងប្រាក់ដើមនេះជូនគ្រប់ចំនួន នៅពេលដែលកំណត់សងគឺថ្ងៃទី........ខែ..........ឆ្នាំ..........។

២.២ ភាគី "ខ" យល់ព្រមចេញមូលប្បទានប័ត្រមួយសន្លឹកចំនួន USD...........(................ ដុល្លាអាមេរិក) ដើម្បីឲ្យភាគី "ក"បើកប្រាក់ជំពាក់ ខាងលើតាម ការកំណត់ ដូចមានក្នុង មូលប្បទានប័ត្រ ដែលភាគី "ខ" បានចេញ។ ទោះបីជាក្នុងករណីណាក៏ដោយ ឬ ប្រើ

មធ្យោបាយណាមួយភាគី “ខ” ធានា និងសន្យាថា មិនធ្វើការពន្យាពេល ឬប្រើលក្ខខណ្ឌណាមួយដើម្បីបញ្ឈប់ការបើកការប្រាក់។

២.៣ ក្នុងករណីភាគី “ខ” បិទគណនីរបស់ខ្លួន ដែលបានចេញមូលប្បទានប័ត្រនេះ នោះភាគី “ខ”យល់ព្រមទទួលស្គាល់ថា ជាបទល្មើសឆបោក ហើយភាគី “ខ”យល់ព្រមសងប្រាក់មួយគុណនឹងពីរដង នៃប្រាក់ដើម ចំនួន USD...........(............ដុល្លាអាមេរិក) ជូនភាគីភាគី “ក”។

**ប្រការ ៣៖** កាតព្វកិច្ចរបស់ភាគី “ក”

៣.១ ភាគី “ក” បានប្រគល់ប្រាក់កម្ចីចំនួន USD...........(............ដុល្លាអាមេរិក) ជូនភាគីភាគី“ខ”នៅថ្ងៃចុះកិច្ចសន្យានេះ រួចហើយ ។

៣.២ ភាគី “ក” យល់ព្រមបញ្ចប់កិច្ចសន្យាមុនកាលកំណត់ ក្នុងករណីភាគី “ខ” បានសងប្រាក់ដើម និងបង់ការប្រាក់ បានចប់ស្អាត។

**ប្រការ ៤៖** កាតព្វកិច្ចរបស់ភាគី “ខ”

៤.១ ភាគី “ខ” ត្រូវបង់ការប្រាក់ តាមការព្រមព្រៀង (ប្រការ១)នៅថ្ងៃចុះ កិច្ចសន្យានេះ។

៤.២ ភាគី “ខ” អាចសងប្រាក់ទៅភាគី “ក” មុនកាលកំណត់បាន។ ភាគី “ខ” អាចពន្យាពេលសងបានក្នុងករណីមានការយល់ព្រមពីភាគី “ក” ។

**ប្រការ ៥៖** ដំណោះស្រាយ

៥.១ ក្នុងករណីមានវិវាទកើតឡើង គូភាគីឯកភាពគ្នាដោះស្រាយវិវាទនេះ ដោយការចរចាសំរុះសម្រួលគ្នាជាមុនសិន។

៥.២ ក្នុងករណីវិវាទនេះ មិនត្រូវដោះស្រាយរួច គូភាគិត្រូវសំរេចយកការដោះស្រាយវិវាទ តាមអំណាចតុលាការនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៦៖** ទាយាទ ឬ អ្នកស្នងមរតក ឬ អ្នកអនុវត្តសិទ្ធិប្រទាន

ក្នុងករណីដែលមានភាគីណាមួយមិនអាចអនិវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនបាន ដោយមូលហេតុ មរណភាព ពិការភាព ឬ អវត្តមាននៅក្នុងប្រទេស រាល់សិទ្ធ ិ និងកាតព្វកិច្ចទាំងអស់របស់ភាគីនោះ ឬ តំណាងស្របច្បាប់របស់ភាគីនោះ ដោយស្វ័យប្រវត្តិ។

**ប្រការ ៧៖** វិសោធនកម្ម

កិច្ចសន្យានេះ អាចកែប្រែ ឬ ផ្លាស់ប្តូរ ឬ បន្ថែមបាន បើសិនជាគូភាគីឯកភាពទាំងសងខាង។រាល់ការកែប្រែ ឬ បន្ថែម ឬផ្លាស់ប្តូរ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរទុកជាឧបសម្ព័ន្ធ មួយផ្នែកនៃកិច្ចសន្យានេះ។

**ប្រការ ៨៖** អវសាន

កិច្ចសន្យានេះ ធ្វើឡើងជាភាសាខ្មែរចំនួន ០៣ ច្បាប់ មានតំលៃ ដូចគ្នា ដោយរក្សាទុកនៅគូភាគីម្នាក់ៗចំនួន០១ច្បាប់ និងតម្កល់ទុកការិយាល័យមេធាវី ចំនួន០១ច្បាប់មានសុពលភាព និងប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះកិច្ចសន្យា ដោយផ្តិតស្នាមមេដៃនេះ តទៅ។ក្នុងករណី មានប្រការណាមួយផ្ទុយអំពីខ្លឹមសារនៃច្បាប់ ប្រការនោះត្រូវចាត់ទុកជាមោឃៈ ឯប្រការ ផ្សេងទៀតនៅតែមានប្រសិទ្ធិភាពអនុវត្ត។

ភាគីទាំងសងខាង បានអាន និងយល់រាល់ខ្លឹមសារទាំងឡាយនៃកិច្ចសន្យានេះ ហើយយល់ព្រមចុះកិច្ចសន្យា ដោយផ្តិតស្នាមមេដៃស្តាំ ដើម្បីទុកជាសក្ខីភាពចំពោះមុខច្បាប់។

**ស្នាមមេដៃស្តាំ**

**ម្ចាស់បំណុល** **កូនបំណុល**

**បានឃើញ**

**គូភាគពិតជាបានផ្តិតមេដៃចំពោះមុខមេធាវ។**